## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥

*«ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព»*

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**

**នាថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១**

**ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨**

# បុព្វកថា

*«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»*, ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ, ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ។ ខ្ញុំបានសម្រេចឱ្យដាក់សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនេះ ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដោយមានគោលបំណងសំខាន់គឺ ចង់ឱ្យមានការយល់ដឹងទូលំទូលាយអំពីប្រព័ន្ធថវិការបស់កម្ពុជា នៅផ្ទៃក្នុងរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការចូលរួម និងភាពម្ចាស់ការក្នុងការអនុវត្តការកែទម្រង់ពីសំណាក់គ្រប់ក្រសួង ស្ថាប័ន។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានធ្វើការរំលឹកឡើងវិញនូវបទពិសោធន៍អំពីឧបសគ្គ បញ្ហាប្រឈម និងហានិភ័យធំៗច្រើនរាប់មិនអស់ ដែលកម្ពុជាបានធ្វើដំណើរឆ្លងកាត់ក្នុងរយៈពេល ៣៩ឆ្នាំកន្លងមកនេះ ចាប់តាំងពីក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ដែលចេញពីបាតដៃទទេសុទ្ធសាធ ។ ការរស់រាន និងការសម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រច្រើនរាប់មិនអស់មកទល់នឹងថ្ងៃនេះ គឺដោយសារតែយើងបានកសាង និងពង្រឹងបាននូវភាពជាម្ចាស់ពិតប្រាកដ លើជោគវាសនារបស់ខ្លួន និងបានប្រកាន់យកទស្សនាទានដឹកនាំតាមអភិក្រមបត់បែនប្រកបដោយភាពជាក់ស្តែងនិយម និងធ្វើការកែទម្រង់ទៅតាមភាពចាំបាច់ ។ នៅក្នុងការដឹកនាំប្រទេស, ខ្ញុំតែងគូសបញ្ជាក់ថា ***«បើកែទម្រង់ យើងមានសង្ឃឹមរស់ដល់ទៅ ៩៩%, តែបើមិនកែទម្រង់ យើងមានសង្ឃឹមរស់តែ ១% ប៉ុណ្ណោះ»*** ។ ដូច្នេះ ដោយសារតែការកែ-ទម្រង់នេះហើយ ទើបយើងអាចរស់រានបានមកទល់នឹងពេលនេះ, ហើយប្រសិនបើគ្មានការកែទម្រង់ប្រកបដោយបុរេសកម្ម សកម្ម និងត្រឹមត្រូវនោះទេ, រាជរដ្ឋាភិបាលមិនអាចដឹកនាំប្រទេសចេញពីស្ថានភាពក្រីក្រតោកយ៉ាក រហូតបានឈានមកដល់ស្ថានភាពជាប្រទេសមានចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្នឡើយ ។

ជាក់ស្តែង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានចាប់ផ្តើមអនុវត្តចាប់តាំងពីឆ្នាំ ២០០៤ គឺជាការដ្ឋានកែទម្រង់ស្នូលមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ គំនិតផ្តួចផ្តើមចម្បងនៃការកែទម្រង់នេះ គឺជាការចិញ្ចឹមចិត្តក្នុងចក្ខុវិស័យដ៏វែងឆ្ងាយមួយ ដែលព្រះរាជាណាចក្រកម្ពុជានឹងអាស្រ័យកាន់តែតិចតួចទៅៗលើជំនួយពីដៃគូអភិវឌ្ឍន៍ ។ មកទល់នឹងពេលនេះ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដើរលើផ្លូវត្រូវ និងសម្រេចបាននូវជោគជ័យគួរជាទីមោទនៈ ដោយបានរួមចំណែកយ៉ាងសំខាន់ក្នុងការធានាស្ថិរភាពរបស់ប្រទេស, ការធានាបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង, ការចាកចេញរួចពីស្ថានភាពជាប្រទេសក្រីក្រតោកយ៉ាក ដែលមានអត្រានៃភាពក្រីក្រ ១០០% នៅក្រោយរបបប្រល័យពូជសាសន៍ ឱ្យមកនៅត្រឹម ១៣,៥% នាឆ្នាំ២០១៤ និងរំពឹងថាមានការថយចុះជាបន្តបន្ទាប់ទៀត ។

ស្ថិតក្នុងមុខតំណែងផ្លូវការ ជានាយករដ្ឋមន្ត្រី រយៈពេល ៣៣ឆ្នាំកន្លងមកនេះ, ខ្ញុំអាចគូសបញ្ជាក់បានថា មិនដែលមានពេលណាដែលសម្ពាធថវិកា ក៏ដូចជាហិរញ្ញវត្ថុសាធារណៈរបស់យើង មានសភាពធូរស្រាលដូចក្នុងពេលបច្ចុប្បន្នឡើយ ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលមិនអាចស្កប់ស្កល់នឹងសមិទ្ធផលដែលសម្រេចបាន ឬធ្វេសប្រហែស ឬភ្លេចខ្លួននោះឡើយ ។ រាជរដ្ឋាភិបាលប្តេជ្ញាបន្តជំរុញការកែទម្រង់លើគ្រប់វិស័យ ពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែសកម្មថែមទៀត ដើម្បីឈានទៅសម្រេចគោលដៅដែលបានគ្រោង

ទុក ។ នៅក្នុងន័យនេះ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»* ដែលជាឯកសារតម្រង់ទិសនៃការកែទម្រង់គ្រប់ជ្រុងជ្រោយរយៈពេលវែង គឺបង្ហាញពីការបោះជំហានថ្មីមួយទៀត និងជាសក្ខីកម្មនៃកិច្ចខិតខំប្រឹង-ប្រែងរបស់រាជរដ្ឋាភិបាល ក្នុងដំណើរនៃការគ្រប់គ្រងការអភិវឌ្ឍប្រទេសកម្ពុជា ឆ្ពោះទៅប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ។

ខ្ញុំចង់គូសបញ្ជាក់ថា *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»* គឺជាចំណុចចាប់ផ្តើមនៃដំណើរវែងឆ្ងាយបន្តទៀត នៅក្នុងការប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិកាកម្ពុជា ឱ្យក្លាយទៅជាប្រព័ន្ធមួយដែលមាន ***ប្រសិទ្ធភាព គណនេយ្យភាព*** និង ***តម្លាភាព*** ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ។ លើសពីនេះ ការកែទម្រង់ប្រព័ន្ធថវិកាគឺមិនគ្រាន់តែជាការផ្លាស់ប្តូររបៀបរបបនៃការគ្រប់គ្រងថវិកាប៉ុណ្ណោះទេ, ការងារនេះ គឺជាអភិក្រមដ៏សំខាន់បំផុតមួយនៃការកែទម្រង់ការគ្រប់គ្រងប្រទេស ជាពិសេស ការកែទម្រង់អភិបាលកិច្ច ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាព នៃការដឹកនាំរាជរដ្ឋាភិបាល ដែលយើងចាំបាច់ត្រូវមានភាពម៉ឺងម៉ាត់ សកម្ម និងប្រាកដនិយម ក្នុងក្របខ័ណ្ឌនៃការធ្វើដំណើរ ។ ទោះបីជាយ៉ាងនេះក្តី, កិច្ចការនេះ យើងក៏ចាំបាច់ត្រូវអនុវត្តដោយប្រយ័ត្នប្រយែងសន្សឹមៗ ឈរលើតថភាពជាក់ស្តែង និងមិនអាចគម្ពីរនិយមឡើយ, ពោលគឺជៀសវាងការធ្វើឱ្យបាត់តុល្យភាព បាត់ភាពជាម្ចាស់ និង មិនអាចធានាបាននូវបរិយាប័ន្ន ទាំងក្នុងផ្នែកសេដ្ឋកិច្ច និងក្នុងផ្នែកនយោបាយ ។

ជាចុងក្រោយ, ខ្ញុំសូមថ្លែងអំណរគុណ ដល់សមាជិក សមាជិកា រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នទាំងអស់ដែលបានចូលរួមអនុវត្តការងារកែទម្រង់នានាទាំងឡាយរបស់រាជរដ្ឋាភិបាល និយាយជារួម និង កម្មវិធីកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និយាយដោយឡែក រហូតសម្រេចបានលទ្ធផល និងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ។ ពេលវេលានៅខាងមុខ គឺជាពេលវេលាកាន់តែសំខាន់ថែមទៀត ក្នុងការឆ្លើយតបទៅនឹងបំណងប្រាថ្នា, សំណូមពរ, ការរំពឹងចង់បាន និងតម្រូវការរបស់ប្រជាជនកម្ពុជា ដែលបន្តកើនឡើងតាមគន្លងស្វ័យគុណ, ខណៈដែលការងារកែទម្រង់របស់រាជរដ្ឋាភិបាលកាន់តែស្មុគស្មាញ និងលំបាកជាងមុន ។ អាស្រ័យហេតុនេះ, ការចូលរួមប្រកបដោយបុរេសកម្ម និងសកម្ម របស់ក្រសួង ស្ថាប័ន គឺជាកត្តាមិនអាចខ្វះបាន ដើម្បីធានាបានជោគជ័យបន្តទៀតនៅក្នុងការងារដោយប្រកាន់ខ្ជាប់នូវគោលការណ៍ និងស្មារតីភ្ញាក់រលឹក ធ្វើការកែទម្រង់ជាប្រចាំ ឬការកែលម្អការងារជាប្រចាំ តាមអភិក្រម ***«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល»*** ។

*ថ្ងៃ*អង្គារ ១៤កើត*ខែ*មាឃ *ឆ្នាំរកា នព្វស័ក ព.ស.២៥៦១*

*រាជធានីភ្នំពេញ, ថ្ងៃទី* ៣០ *ខែមករា ឆ្នាំ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៤ គឺមានគោលបំណងកែប្រែជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របទៅនឹងឧត្តមានុវត្តអន្តរជាតិ ។ ក្នុងរយៈពេល ១៣ ឆ្នាំកន្លងទៅ, រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើននៅក្នុងការងារនេះ, ជាពិសេសសម្រេចបានជាសារវ័ន្តនូវជំហានទី១ គឺ «**ភាពជឿទុកចិត្តបាននៃថវិកា**» និង ជំហានទី២ គឺ «**គណនេយ្យភាពហិរញ្ញវត្ថុ**» ។ បច្ចុប្បន្ននេះ ការអនុវត្តជំហានទី៣ គឺ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**»ក៏កំពុងមានវឌ្ឍនភាពល្អ ដោយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២០, មុននឹងឈានទៅអនុវត្តជំហានទី៤ គឺ «**គណនេយ្យភាពសមិទ្ធកម្ម**» ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ ។ សមិទ្ធផលដែលសម្រេចបានជាបណ្តើរៗ មកនេះ បាននិងកំពុងធ្វើឱ្យវិស័យហិរញ្ញវត្ថុសាធារណៈដើរតួនាទីកាន់តែសំខាន់ នៅក្នុងការចូលរួមធានាឱ្យប្រទេសជាតិមានស្ថិរភាព និងឯករាជ្យភាព ព្រមទាំងកាន់តែមានការអភិវឌ្ឍឈានឡើង ។

ក្នុងន័យនេះ ខ្ញុំសូមគោរពសម្តែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តល់ការណែនាំ និងចង្អុលបង្ហាញជាប្រចាំ និងផ្តល់ការគាំទ្រយ៉ាងមុតមាំដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណើរការកែទម្រង់ដ៏មានសារៈសំខាន់មួយនេះ ។ ជាមួយគ្នានេះដែរ, ខ្ញុំក៏សូមគោរពដឹងគុណចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** ដែលបានផ្ទេរនូវមរតកនៃការកែទម្រង់មួយ ដែលបានកសាងមូលដ្ឋានគ្រឹះរឹងមាំ និងគ្រប់គ្រាន់នៅក្នុងឆន្ទៈភាពជាម្ចាស់ខ្ពស់ ទន់ភ្លន់ និង ប្តូរផ្តាច់ ដើម្បីជាឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជន ។

គប្បីរំលឹកថា ក្នុងក្របខ័ណ្ឌនៃការត្រៀមលក្ខណៈសម្រាប់អនុវត្តជំហានទី ៣, ក្នុងឆ្នាំ២០០៨, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានអនុម័ត, ដែលបានបើកច្រកឱ្យរាជរដ្ឋាភិបាលអាចចាប់ផ្តើមអនុវត្តសាកល្បងដោយថេរៗនូវ *ថវិកាកម្មវិធី* ជាបណ្តើរៗ ។ បន្ទាប់មក, ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលក៏បានដាក់ចេញឯកសារទស្សនាទានស្តីពី *«ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០»*, ដែលតាមទស្សនាទាននេះ ប្រព័ន្ធថវិកានឹងត្រូវផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម និងវិមជ្ឈការ ក្នុងឆ្នាំ២០២០ ។ បន្ទាប់ពីបានចំណាយពេល ១ឆ្នាំ ក្នុងការរៀបចំបំពេញបង្គ្រប់នូវលក្ខខណ្ឌចាំបាច់ជាសារវ័ន្តនានាសម្រាប់អនុវត្ត, ដោយផ្អែកតាមទស្សនាទាននេះ, *ថវិកាកម្មវិធី* ត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងពេញលេញចាប់ពីឆ្នាំ២០១៥, និងឈានទៅអនុវត្តគ្រប់ក្រសួង ស្ថាប័នទាំងអស់ចាប់ពីឆ្នាំ២០១៨ តទៅ ។ ទោះជាយ៉ាងនេះក្តី ឯកសារទស្សនាទាននោះត្រូវបានរៀបចំឡើងក្នុងពេលដែលកម្ពុជាមិនទាន់មានលទ្ធភាពបានសិក្សាដកពិសោធន៍

បានស៊ីជម្រៅនៅឡើយអំពីប្រព័ន្ធថវិកាសមិទ្ធកម្ម, ក្នុងន័យនេះ ការកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកានាពេលនោះ ក៏មិនទាន់មានភាពប្រាកដនិយមទាំងស្រុងដែរ ។

ឆ្លងតាមបទពិសោធន៍នៃការអនុវត្តតាមទិសដៅនៃទស្សនាទានអស់រយៈពេលជាង ២ឆ្នាំ និងផ្អែកតាមលទ្ធផលនៃការវាយតម្លៃរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានកិច្ចសហការពីអ្នកជំនាញពាក់ព័ន្ធស្តីពីវឌ្ឍនភាពនៃការអនុវត្តថវិកាកម្មវិធី, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយល់ថា ការកំណត់គោលដៅឆ្នាំ ២០២០ ក្នុងការចាប់ផ្តើមអនុវត្ត **«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»** គឺមានមហិច្ឆតាខ្ពស់ពេក ។ ក្នុងន័យនេះ ក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, *កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦,* ខ្ញុំបានចាត់តាំងក្រុមការងារមួយ ដែលស្ថិតនៅក្រោមការដឹកនាំកម្រិតគោលនយោបាយដោយ **ឯកឧត្តមរដ្ឋលេខាធិការ ទេព្យី ទិស្សរុត** និងការដឹកនាំកម្រិតបច្ចេកទេសដោយ **ឯកឧត្តមអនុរដ្ឋលេខាធិការ ចាន់ សុធី** ឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែងគឺ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»*, ស្របទៅ តាមឧត្តមានុវត្តអន្តរជាតិ និងតាមតថភាពជាក់ស្តែងនៃកម្ពុជា ។ *គោលបំណងសំខាន់នៃយុទ្ធសាស្ត្រនេះ គឺកសាងប្រព័ន្ធថវិកាជាតិមួយប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព និង តម្លាភាព* ។

ដោយធានាបានទាំងស្រុងនូវភាពជាម្ចាស់របស់កម្ពុជា, ឯកសារ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»* ត្រូវបានរៀបចំដោយបានឆ្លងកាត់ការសិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និងពីប្រទេសមួយចំនួន, បទពិសោធន៍នៃការអនុវត្តការងារជាក់ស្តែងរយៈពេល ៣ឆ្នាំ របស់កម្ពុជាផ្ទាល់, ការចូលរួមជួយចែករំលែកជំនាញ និងបទពិសោធន៍ផ្ទាល់ពីអ្នកជំនាញបរទេសជាច្រើននាក់, ការផ្តល់មតិយោបល់ពីដៃគូអភិវឌ្ឍន៍សំខាន់ៗ, ព្រមទាំងបានឆ្លងកាត់ការពិភាក្សាជាច្រើនលើកច្រើនសារនៅក្នុងផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធគន្លឹះៗ ។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥,* ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គឺជាឯកសារតម្រង់ទិសដែលកំណត់អំពីទិសដៅ និងគោលដៅច្បាស់លាស់ ប្រកបដោយភាព-ប្រាកដនិយម និងជាក់ស្តែងនិយម ដោយមានផែនទីចង្អុលផ្លូវជាត្រីវិស័យ ក្នុងការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ដំណើរនៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែង ។ ដំណើរការនេះត្រូវរៀបចំ និងអនុវត្តតាមអភិក្រមប្រយ័ត្នប្រយែង ដោយជំហានព្យាសកម្ម, ប៉ុន្តែមានភាពច្បាស់លាស់ ហ្មត់ចត់ និងសកម្ម ដើម្បីធានាឱ្យបាននូវការធ្វើដំណើរពីមួយជំហាន ទៅមួយជំហាន ដោយសម្រេចបានជោគជ័យ និងទាន់ពេលវេលាដែលបានគ្រោងទុក ។

តាមការសិក្សាពីបទពិសោធន៍អន្តរជាតិបានបង្ហាញថា ប្រព័ន្ធថវិកាសមិទ្ធកម្មអាចអនុវត្តតាម៣ ម៉ូដែលគឺ ÷ *១). ប្រព័ន្ធថវិកាបង្ហាញសមិទ្ធកម្ម, ២). ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និង ៣). ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្មផ្ទាល់* ។ ម៉ូដែលទាំង៣ ខុសគ្នានៅត្រង់កម្រិតនៃការប្រើប្រាស់ព័ត៌មានសមិទ្ធកម្មតាមទម្ងន់ផ្សេងៗគ្នានៅក្នុង

ការវិភាជថវិកា ដោយម៉ូដែលទី២ មានលក្ខណៈកណ្តាល គឺផ្តល់នូវភាពបត់បែន និងទន់ភ្លន់ល្មម ក្នុងការប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម, ពោលគឺមិនធូរលុងពេក ដែលអាចនឹងនាំឱ្យការអនុវត្តថវិកាសមិទ្ធកម្មមិនសូវមានន័យ និងមិនរឹងត្អឹងពេក ដែលនាំឱ្យការអនុវត្តមានលក្ខណៈដូចជាគ្រឿងម៉ាស៊ីន (ឬគម្ពីរនិយម) ។ ដូចនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយល់ថា កម្ពុជាគួរជ្រើសរើសយកប្រព័ន្ធ **«ថវិកាព័ត៌មានសមិទ្ធកម្ម»** ជាទិសដៅជាក់លាក់នៃការកែទម្រង់ប្រព័ន្ធថវិកា ដោយកំណត់យកគោលដៅពេលវេលាដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ២០២៥ ស្របតាមគោលដៅនៃជំហានទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ដើម្បីសម្រេចនូវគោលបំណងនេះ កម្ពុជាចាំបាច់ត្រូវផ្លាស់ប្តូរសមាសធាតុសំខាន់ៗ នៃវដ្តថវិកា ដែលរួមមាន ការរៀបចំគម្រោងថវិកា (ថវិការយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ), ការអនុវត្តថវិកា (ការអនុវត្តថវិកា, ការត្រួតពិនិត្យការអនុវត្តថវិកា), ការតាមដាន និងវាយតម្លៃការអនុវត្តថវិកា (កិច្ចបញ្ជិកាគណនេយ្យ, ការធ្វើរបាយការណ៍, ការតាមដាន, និងសវនកម្ម) ។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាឆ្នាំ២០១៨-២០២៥* បានកំណត់គោលបំណង និងគូសវាសផ្លូវនៃការកែទម្រង់ប្រព័ន្ធថវិការបស់កម្ពុជាឈានឆ្ពោះទៅលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា តាមរយៈការប្រើប្រាស់សូចនាករសមិទ្ធកម្ម ឬហៅថាលទ្ធផលការងារជាមូលដ្ឋាន និង ប្រសិទ្ធភាពនៃការអនុវត្តថវិកា តាមរយៈការកាត់បន្ថយនីតិវិធីចំណាយ និងការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែធំ និងច្បាស់លាស់ដល់ក្រសួង ស្ថាប័នជំនាញជាពិសេស អង្គភាពប្រតិបត្តិផ្ទាល់ ជាមួយនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងថវិកា ។ ការកំណត់គោលបំណងនេះ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់គណនេយ្យភាពក្នុងការគ្រប់គ្រងថវិកាទាំងគណនេយ្យភាពហិរញ្ញវត្ថុ និង គណនេយ្យភាពសមិទ្ធកម្ម ឬលទ្ធផល ។ លើសពីនេះ តម្លាភាពក្នុងក្របខ័ណ្ឌនៃតួអង្គសាធារណៈ និងតម្លាភាពរវាងតួអង្គសាធារណៈ និងប្រជាជន ក៏ជាគោលបំណងសំខាន់របស់យុទ្ធសាស្ត្រនេះដែរ ។

ជារួម បើទោះបីជាទិសដៅ និងក្របខ័ណ្ឌពេលវេលាត្រូវបានកែសម្រួលមួយចំនួនហើយក្តី, *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»* នៅតែមានគោលដៅប្រកបដោយមហិច្ឆតាខ្ពស់ និងត្រូវបានប្រមើលឃើញនូវហានិភ័យសំខាន់ៗមួយចំនួន ដែលអាចជួបប្រទះនៅក្នុងពេលអនុវត្ត ។ ទោះជាយ៉ាងនេះក្តី, កម្ពុជាចាំបាច់ត្រូវពុះពារសម្រេចឱ្យបាននូវគោលដៅទាំងនោះជាសារវ័ន្ត ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍កម្ពុជាដែលកំពុងឈានដល់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ក៏ដូចជានិន្នាការថ្មីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអន្តរជាតិ ។

ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់នៃតួអង្គពាក់ព័ន្ធរបស់កម្ពុជា ក៏ដូចជាការរួមវិភាគទានផ្នែកចំណេះដឹងដ៏មានតម្លៃពីដៃគូអភិវឌ្ឍន៍ គឺជាកត្តាគន្លឹះក្នុងការធានាឱ្យបានជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា ។ លើសពីនេះ ការគាំទ្រយ៉ាងមុតមាំ និងការណែនាំជាប្រចាំ ពីសំណាក់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**,ដែលធ្លាប់បានធ្វើឱ្យការកែទម្រង់ហិរញ្ញវត្ថុសាធារណៈទទួលបានជោគជ័យគួរជាទីមោទនៈ និង កំពុងបន្តមានសន្ទុះទៅមុខ, គឺជាកត្តាមិនអាចខ្វះបាន ដើម្បីផ្តល់ក្តីសង្ឃឹមដល់កម្ពុជា ក្នុងការសម្រេចបាននូវ

មហិច្ឆតារបស់ខ្លួន តាមការកំណត់នៅក្នុងឯកសារយុទ្ធសាស្ត្រនេះ ។

ជាទីបញ្ចប់, ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង អង្គគណៈរដ្ឋមន្ត្រីទាំងមូល ដែលបានផ្តល់ការអនុម័តលើសេចក្តីព្រាង «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥» ដ៏មានសារៈសំខាន់នេះ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នទាំងអស់ នឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការកែទម្រង់ប្រព័ន្ធថវិកាឱ្យឈានទៅសម្រេចឱ្យបានលទ្ធផលដែលបានគ្រោងទុកនៅក្នុងដំណាក់កាលនីមួយៗ និងនៅក្នុងឆ្នាំ ២០២៥ ក្នុងបុព្វហេតុសំខាន់បំផុតគឺ កសាងប្រព័ន្ធថវិកាមួយដែលមាន *ប្រសិទ្ធភាព គណនេយ្យភាព* និង*តម្លាភាព* ស្របតាមឧត្តមានុវត្តអន្តរជាតិ និងតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា ។

*ថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៨*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


**បុព្វកថា** (i)-(ii)

**អារម្ភកថា** (I)-(IV)

**ជំពូកទី១ : សាវតានៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា** ១

១.១. យុទ្ធសាស្ត្រតាមជំហាននិងដំណាក់កាល និងវឌ្ឍនភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១

១.២. សមាសធាតុនិងគោលបំណងនៃកម្មវិធីកែទម្រង់ដំណាក់កាលទី៣និងទី៤ ៣

១.៣. ឧបសគ្គនៃការសម្រេចគោលបំណងនៃជំហានទី៣និងទី៤ ៤

១.៤. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌពេលវេលា ៥

**ជំពូកទី២ : ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា** ៧

២.១. ការពិនិត្យឡើងវិញលើឯកសារ «ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០» ៧

២.២. វឌ្ឍនភាពនិងបញ្ហាប្រឈមនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ៨

២.៣. គំរូនៃប្រព័ន្ធថវិកាសមិទ្ធកម្មនិងបទពិសោធអន្តរជាតិ ១០

២.៤. ជម្រើសសម្រាប់កម្ពុជា ១២

២.៥. ការកំណត់ទិសដៅនិងក្របខ័ណ្ឌពេលវេលាថ្មីនៃការកែទម្រង់ប្រព័ន្ធថវិកា ១៣

**ជំពូកទី៣ : យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥** ១៤

៣.១. ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ ១៤

*៣.១.១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច* ១៥

*៣.១.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)* ១៥

*៣.១.៣. ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF)* ១៦

*៣.១.៤ ផែនការយុទ្ធសាស្ត្រថវិកា* ១៧

៣.២. ការរៀបចំនិងការអនុម័តថវិកា ១៨

*៣.២.១. ដំណើរការរៀបចំថវិកាប្រចាំឆ្នាំ* ១៨

*៣.២.២. ការពិនិត្យពិភាក្សានិងការអនុម័តថវិកា* ២០

៣.៣. ការអនុវត្តនិងការត្រួតពិនិត្យថវិកា ២១

៣.៣.១. សិទ្ធអំណាចនៃការបញ្ជាចំណាយ ២១

៣.៣.២ ការត្រួតពិនិត្យការអនុវត្តថវិកា ២២

៣.៣.៣ កិច្ចលទ្ធកម្ម ២៣

៣.៣.៤ ការត្រួតពិនិត្យការបើកផ្តល់ ២៤

៣.៣.៥ អធិការកិច្ចហិរញ្ញវត្ថុ ២៤

៣.៤ ការតាមដាននិងវាយតម្លៃថវិកា ២៤

៣.៤.១ ប្រព័ន្ធរបាយការណ៍ ២៤

៣.៤.១.១. របាយការណ៍ហិរញ្ញវត្ថុ ២៤

៣.៤.១.២ របាយការណ៍សមិទ្ធកម្ម ២៥

៣.៤.២ ការតាមដាននិងការវាយតម្លៃ ២៥

៣.៤.៣ ការពិនិត្យចំណាយសាធារណៈឡើងវិញក្នុងក្របខ័ណ្ឌវិស័យ ឬអនុវិស័យ ២៧

៣.៥ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ២៧

៣.៥.១. ក្របខ័ណ្ឌគតិយុត្តនៃថវិកា ២៧

៣.៥.២ ជំនាញនិងសមត្ថភាពក្នុងការគ្រប់គ្រងថវិកា ២៧

៣.៥.៣ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២៨

៣.៥.៤ ការគ្រប់គ្រងការផ្លាស់ប្តូរនិងការប្រាស្រ័យទាក់ទងគ្នា ២៨

៣.៥.៥ ការលើកកម្ពស់តម្លាភាព ២៩

៣.៦. ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២៩

៣.៦.១. ក្របខ័ណ្ឌទស្សនាទាន ២៩

៣.៦.២ ការធ្វើផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ៣២

៣.៦.៣. ការរៀបចំគម្រោងថវិកា ការចរចាថវិកា និងការអនុម័តថវិកា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៣៣

៣.៦.៤ ការអនុវត្តនិងការត្រួតពិនិត្យថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៣៥

៣.៦.៥ ប្រព័ន្ធរបាយការណ៍ ការតាមដាន និងការវាយតម្លៃថវិកានៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ៣៧

**ជំពូកទី៤ : ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រឆ្នាំ ២០២៥** ៣៨

៤.១. វិសាលភាព ៣៨

៤.២. ផែនទីចង្អុលផ្លូវ ៣៩

៤.២.១. ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ ៣៩

៤.២.២ ការរៀបចំនិងការអនុម័តថវិកា ៣៩

៤.២.៣ ការអនុវត្តនិងការត្រួតពិនិត្យថវិកា ៤១

៤.២.៤ កិច្ចលទ្ធកម្ម ៤១

៤.២.៥ ការត្រួតពិនិត្យការបើកផ្តល់ ៤២

៤.២.៦ ការតាមដាននិងការវាយតម្លៃ ៤២

៤.២.៧ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ៤២

៤.៣. ក្របខ័ណ្ឌពេលវេលានិងអភិក្រមអនុវត្ត ៤៣

៤.៤. ការវិភាគហានិភ័យ ៤៤

**ជំពូកទី៥ : សេចក្តីសន្និដ្ឋាន** ៤៦

*ឧបសម្ព័ន្ធទី១ : បទពិសោធអន្តរជាតិផ្សេងៗទៀត*

*ឧបសម្ព័ន្ធទី២ : ការដ្ឋានកែទម្រង់គន្លឹះៗពាក់ព័ន្ធផ្សេងទៀត*

*ឧបសម្ព័ន្ធទី៣ : ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រ ២០២៥*

# ជំពូកទី១

## សាវតានៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMRP) នៅឆ្នាំ២០០៤ ក្នុងគោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាជាជំហានៗ ឱ្យទៅជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្របតាមបទដ្ឋាននិងឧត្តមានុវត្តជាអន្តរជាតិ។ កម្មវិធីនេះត្រូវបានរៀបចំតាក់តែងឡើងជាការកែទម្រង់ក្នុងរយៈពេលវែងនិងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយកំណត់ជា៤ជំហាននិង៤ដំណាក់កាលបន្តបន្ទាប់។ ដំណាក់កាលទី១ផ្តោតសំខាន់លើជំហានទី១នៃកម្មវិធីកែទម្រង់ គឺការបង្កើនភាពជឿទុកចិត្តនៃថវិកា (២០០៥-២០០៨)។ ដំណាក់កាលទី២ផ្តោតលើជំហានទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (២០០៩-២០១៥) ស្របពេលនឹងការពង្រឹងបន្ថែមសមិទ្ធផលនៃជំហានទី១ និងការកសាងមូលដ្ឋានគ្រឹះសម្រាប់ជំហានទី៣។ ដំណាក់កាលទី៣ផ្តោតលើជំហានទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៦-២០២០) ទន្ទឹមនឹងការពង្រឹងសមិទ្ធផលនៃជំហានពីរដំបូងនិងការត្រួសត្រាយផ្លូវសម្រាប់ត្រៀមអនុវត្តជំហានទី៤។ ដំណាក់កាលទី៤ នឹងផ្តោតជាសំខាន់លើការកសាងជំហានទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការបង្កើនគណនេយ្យភាពសមិទ្ធកម្ម (២០២១-២០២៥) ទន្ទឹមនឹងការបន្តពង្រឹងសមិទ្ធផលដែលសម្រេចបានក្នុងជំហានទាំងបីខាងដើម។

### ១.១. យុទ្ធសាស្ត្រតាមជំហាននិងដំណាក់កាល និងវឌ្ឍនភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដូចបានអធិប្បាយខាងលើ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានធ្វើឡើងតាមអភិក្រមជាជំហានៗទៅតាមដំណាក់កាលដែលដំណាក់កាលនីមួយៗផ្តោតលើជំហានមួយជាក់លាក់ ទន្ទឹមនឹងការបន្តពង្រឹងជំហានមុនៗផង និងការត្រៀមរៀបចំកសាងមូលដ្ឋានគ្រឹះសម្រាប់ជំហានបន្ទាប់ផង។ ដោយសារកម្មវិធីកែទម្រង់នេះត្រូវការរយៈពេលវែង អភិក្រមបែបនេះមានលក្ខណៈអំណោយផលសម្រាប់ការអនុវត្តជាបណ្តើរៗ ដើម្បីធានាឱ្យមានការផ្សារភ្ជាប់គ្នាឱ្យបានរឹងមាំពីជំហានមួយទៅជំហានមួយទៀត ប្រកបដោយប្រសិទ្ធភាព។

ដើម្បីគោលដៅខាងលើ **«គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** ត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើការរៀបចំ ការអនុវត្ត និងការតាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គណៈកម្មាធិការនេះដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដែលមានភារកិច្ចសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ទាំងមូល។ ជាមួយគ្នានេះ ក្រុមការងារកែទម្រង់ដែលដឹកនាំដោយថ្នាក់ដឹកនាំជារដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការត្រូវបានបង្កើតឡើងនៅតាមក្រសួង ស្ថាប័ននីមួយៗ ដើម្បីទទួលខុសត្រូវលើការងារកែទម្រង់ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ដំណាក់កាលនីមួយៗមាន***ផែនការសកម្មភាពរួម(CAP)*** មួយ ជាមគ្គុទ្ទេសក៍សម្រាប់ការអនុវត្តសកម្មភាព

កែទម្រង់។ CAP ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ដោយមានការពិភាក្សានិងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់។ ជាមួយនឹងការបញ្ចប់ផែនការសកម្មភាពរួមដំណាក់កាលទី១ (CAP-1) និងផែនការសកម្មភាពរួមដំណាក់កាលទី២(CAP-2) ប្រកបដោយជោគជ័យ នៅក្នុងឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ **«ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ»** **(PEFA Assessment Framework)** និងដោយមានការចូលរួមផ្តល់យោបល់ ពីទីប្រឹក្សាទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំតំបន់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ព្រមទាំងជំនាញការមកពីក្រៅប្រទេសផ្សេងទៀត។ លទ្ធផលនៃការវាយតម្លៃនេះបានក្លាយជាមូលដ្ឋានចាំបាច់សម្រាប់ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣(CAP-3) ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពីដើមឆ្នាំ២០១៦។

ជារួម វឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងជំហានទី១ ក៏ដូចជាក្នុងដំណាក់កាលទី១ ទទួលបានលទ្ធផលល្អប្រសើរ។ វឌ្ឍនភាពសំខាន់ៗគួរឱ្យកត់សម្គាល់រួមមាន ជោគជ័យនៃការកៀរគរប្រភពចំណូល ការរៀបចំថវិកាត្រូវបានកែលម្អឱ្យមានភាពគ្រប់ជ្រុងជ្រោយនិងប្រាកដនិយមជាងមុន ព្រមទាំងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកា។ ជាក់ស្តែង ចំណូលសារពើពន្ធប្រមូលបានមានកំណើន ១៧,៥%ក្នុងមួយឆ្នាំ និងចំណូលមិនមែនសារពើពន្ធបានកើនឡើង១៦,៩%ក្នុងមួយឆ្នាំ។ នៅក្នុងផ្នែករៀបចំថវិកា វដ្តថវិកាត្រូវបានកំណត់ឱ្យកាន់តែច្បាស់លាស់ជាងមុន ផែនការយុទ្ធសាស្ត្រថវិកា(BSP) និងចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មីត្រូវបានដាក់ឱ្យអនុវត្ត ព័ត៌មានចំណាយមូលធនត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីព្រាងច្បាប់ថវិកា និងសេចក្តីសង្ខេបនៃច្បាប់ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំនិងផ្សព្វផ្សាយជាសាធារណៈ។ នៅក្នុងផ្នែកអនុវត្តថវិកា គណនីទោលរតនាគារជាតិត្រូវបានបង្កើតឡើង ដោយបញ្ចូលគ្នានូវគណនីធនាគាររបស់រាជរដ្ឋាភិបាលទាំងអស់ និងបានរៀបចំឱ្យមានប្រព័ន្ធទិន្នន័យរួមនៃហិរញ្ញប្បទានក្រៅប្រទេស។ ជាមួយគ្នានេះ ការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំត្រូវបានធ្វើឡើងនៅដើមឆមាសទីពីរ ការបន្ថែមឥណទានក្នុងឆ្នាំត្រូវបានកំហិតមិនឱ្យលើសពីទំហំឥណទានមិនទាន់បែងចែកឡើយ ការអនុវត្តចំណាយមិនមែនបៀវត្សត្រូវបានកែលម្អ ហើយវិធានលទ្ធកម្មត្រូវបានធ្វើបច្ចុប្បន្នកម្មដោយតម្រូវឱ្យមានផែនការលទ្ធកម្ម របាយការណ៍ និងការត្រួតពិនិត្យក្រោយការអនុវត្ត។ កម្មវិធីចំណូលនិងចំណាយប្រចាំត្រីមាសបានក្លាយជាការងារជាប្រចាំ ហើយអង្គភាពគ្រប់គ្រងសាច់ប្រាក់ក៏បានបំពេញភារកិច្ចរបស់ខ្លួនបានល្អ និងបំណុលកកស្ទះត្រូវបានលុបបំបាត់ទាំងស្រុង។ នៅក្នុងដំណាក់កាលទី១នេះ ការងារត្រៀមសម្រាប់ជំហានបន្ទាប់ចំនួនប្រាំមួយត្រូវបានអនុវត្ត រួមមាន ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ការអង្កេតវិហ្វចំណាយក្នុងវិស័យអប់រំ និងសុខាភិបាល ការចាប់ផ្តើមបង្កើតឱ្យមានសវនកម្មផ្ទៃក្នុង ការរៀបចំការអនុវត្តសាកល្បងថវិកាកម្មវិធី ការរៀបចំផែនការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) និងការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងអភិវឌ្ឍន៍សមត្ថភាព។

បន្តមកទៀត ដំណាក់កាលទី២ត្រូវបានផ្តោតលើជំហានទី២ គឺការកសាងគណនេយ្យភាពហិរញ្ញវត្ថុ។ នៅក្នុងដំណាក់កាលនេះ ចំណាត់ថ្នាក់ថវិកាថ្មីត្រូវបានដាក់ឱ្យអនុវត្ត។ ទន្ទឹមនឹងនេះ មុខងារសវនកម្ម ការធ្វើ

របាយការណ៍និងតម្លាភាព ការសម្រួលដល់កិច្ចប្រតិបត្តិការនិងការអនុវត្តថវិកា ក៏ដូចជាបណ្តាឧបករណ៍ផ្សេងៗទៀតសម្រាប់លើកកម្ពស់គណនេយ្យភាព ត្រូវបានកែលម្អនិងពង្រឹង។ ជារួម ក្នុងការកសាងជំហានទី២នេះ សមាសធាតុចាំបាច់នានានៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ចេញនិងអនុវត្តក្នុងគោលដៅពង្រឹងបន្ទាត់គណនេយ្យភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។

ដំណាក់កាលទី២ ត្រូវបានចាត់ទុកថា សម្រេចជោគជ័យជាសារវន្ត បើទោះបីជានៅមានសកម្មភាពមួយចំនួនមិនអាចបញ្ចប់តាមផែនការដែលបានគ្រោងទុកទាំងស្រុងដែរក៏ដោយ ដូចជា ការពន្យារពេលនៃការដាក់ឱ្យដំណើរការប្រព័ន្ធ FMIS និងការរៀបចំឧបករណ៍គណនេយ្យភាពហិរញ្ញវត្ថុមួយចំនួនផ្សេងទៀត។ ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យដំណើរការសាកល្បងនៅចុងឆ្នាំ២០១៥ ជាមួយនឹងមុខងារចំនួន៦ រួមមាន មុខងារវិភាជន៍ថវិកា មុខងារសៀវភៅធំ មុខងារធានាចំណាយនិងបញ្ជាទិញ មុខងារគណនីត្រូវសង មុខងារគណនីត្រូវទារនិងមុខងារគ្រប់គ្រងសាច់ប្រាក់។ ទន្ទឹមនឹងនោះដែរ សមិទ្ធផលនៃភាពជឿទុកចិត្តនៃថវិកាត្រូវបានបន្តរក្សាជាសារវន្ត តាមរយៈការកៀរគរចំណូលបានល្អប្រសើរ ការអនុវត្តថវិកាកាន់តែមានប្រសិទ្ធភាព និងការគ្រប់គ្រងសាច់ប្រាក់ត្រូវបានពង្រឹងបន្ថែម។ ការអនុវត្តចំណាត់ថ្នាក់ថវិកាថ្មីនិងប្លង់គណនីមានវឌ្ឍនភាពល្អ និងមុខងារសវនកម្មផ្ទៃក្នុងក៏ត្រូវបានពង្រឹងបន្ថែមផងដែរ។ លើសពីនេះ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីក៏ត្រូវបានចាប់ផ្តើមសាកល្បងតាំងពីឆ្នាំ២០០៨ នៅក្រសួង ស្ថាប័នចំនួន៨ និងត្រូវបានពង្រីកជាបន្តបន្ទាប់ រហូតអាចដាក់ឱ្យអនុវត្តសាកល្បងពេញលេញនៅឆ្នាំ២០១៥ ជាមួយក្រសួង ស្ថាប័នចំនួន១០។ បទពិសោធទាំងអស់នេះបានផ្តល់ជាមូលដ្ឋានដ៏សំខាន់ សម្រាប់ការឈានទៅពង្រីកការអនុវត្តថវិកាកម្មវិធីពេញលេញដល់គ្រប់ក្រសួង ស្ថាប័ន នៅក្នុងដំណាក់កាលទី៣នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សរុបមក ការអនុវត្ត CAP-1 និង CAP-2 រហូតដល់ចុងឆ្នាំ២០១៥ បានបង្កើតជាមូលដ្ឋានចាំបាច់និងគ្រប់គ្រាន់ សម្រាប់ការអនុវត្តជំហានទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ នៅក្នុងដំណាក់កាលទី៣ (២០១៦-២០២០) ជាមួយនឹងការបន្តពង្រឹងបន្ថែមជំហានទាំងពីរដំបូងដែលបានអនុវត្តរួចមក។

### ១.២. សមាសធាតុនិងគោលបំណងនៃកម្មវិធីកែទម្រង់ដំណាក់កាលទី៣និងទី៤

ផែនការសកម្មភាពរួមដំណាក់កាលទី៣(CAP-3)នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តក្នុងខែមីនា ឆ្នាំ២០១៦ ផ្តោតជាសំខាន់លើការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយដោយមានគោលបំណងចំនួនប្រាំ។ គោលបំណងទី១ គឺបន្តការពង្រឹងភាពជឿទុកចិត្តនៃថវិកា តាមរយៈការពង្រឹងការគ្រប់គ្រងចំណូល ការគ្រប់គ្រងបំណុល ការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អការអនុវត្តថវិកា។ គោលបំណងទី២ គឺការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការពង្រឹងការអនុវត្តចំណាត់ថ្នាក់ថវិកា ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធថវិកាថ្មីនិងប្រព័ន្ធប្រតិបត្តិការថ្មី ការពង្រឹងប្រព័ន្ធធ្វើរបាយការណ៍និងគណនេយ្យភាពហិរញ្ញវត្ថុ និងការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង។ គោលបំណងទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការពង្រីកការអនុវត្តថវិកាកម្មវិធីពេញលេញនិងអង្គភាពថវិកា ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា ការកំណត់ឱ្យបានច្បាស់លាស់នូវតួនាទីនិងការទទួលខុសត្រូវរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាមី និងស្ថាប័ន

នីតិប្បញ្ញត្តិ ការរៀបចំឱ្យមានក្របខ័ណ្ឌចំណាយសាធារណៈរយៈពេលមធ្យម ការបង្កើតប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។ គោលបំណងទី៤ គឺការត្រៀមរៀបចំសម្រាប់គណនេយ្យភាពសមិទ្ធកម្ម ដែលរាប់បញ្ចូលនូវក្របខ័ណ្ឌថវិកាសមិទ្ធកម្ម ការកំណត់បន្ទាត់គណនេយ្យភាពថវិកាសមិទ្ធកម្ម ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌសវនកម្មសមិទ្ធកម្មនិងផែនការអភិវឌ្ឍន៍សមត្ថភាព។ គោលបំណងទី៥ គឺការគាំទ្រដល់កម្មវិធីកែទម្រង់តាមរយៈការលើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងការងារកែទម្រង់ ការកសាងសមត្ថភាព និងការផ្តល់ការលើកទឹកចិត្តដល់ការងារកែទម្រង់ និងការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តដំណាក់កាលទី៣។

ជំហានទី៤ គឺគណនេយ្យភាពសមិទ្ធកម្ម ដែលត្រូវបានរំពឹងថានឹងសម្រេចការអនុវត្តនៅឆ្នាំ២០២៥។ គោលបំណងនៃផែនការសកម្មភាពរួមសម្រាប់ដំណាក់កាលទី៤មិនទាន់ត្រូវបានកំណត់នៅឡើយ។

## ១.៣. ឧបសគ្គនៃការសម្រេចគោលបំណងនៃជំហានទី៣និងទី៤

ជំហានទី៣ត្រូវបានរំពឹងថានឹងមានវឌ្ឍនភាពល្អ ប៉ុន្តែការកែលម្អគុណភាពនៃការរៀបចំរចនាសម្ព័ន្ធកម្មវិធី ការធ្វើសមាហរណកម្មថវិកា និងការលើកកម្ពស់ភាពគ្រប់ជ្រុងជ្រោយនៃថវិកានឹងនៅតែជាបញ្ហាប្រឈម។ នៅក្នុងការអនុវត្តជាក់ស្តែង ការផ្លាស់ប្តូរការគ្រប់គ្រងថវិកាពីអភិក្រមផ្អែកលើធាតុចូលទៅអភិក្រមផ្អែកលើកម្មវិធីមិនជាការលំបាកពេកទេ ប៉ុន្តែការផ្លាស់ប្តូរពីប្រព័ន្ធថវិកាកម្មវិធី ទៅរកប្រព័ន្ធថវិកាសមិទ្ធកម្មនឹងជួបការលំបាក ប្រសិនបើប្រព័ន្ធគណនេយ្យភាពសមិទ្ធកម្មនៅទន់ខ្សោយ។

ការកែទម្រង់ប្រព័ន្ធថវិកា ដែលផ្តោតលើសមាសធាតុនៃវដ្តថវិកា ដូចជាការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ ការរៀបចំថវិកា ការអនុវត្តថវិកា ការតាមដាននិងត្រួតពិនិត្យ និងសវនកម្ម គឺជាស្នូលនៃ PFMRP។ ការងារនេះត្រូវបានអមដោយសមាសធាតុដែលមានអន្តរទំនាក់ទំនងដទៃទៀត ជាអាទិ៍ ការកៀរគរចំណូល ប្រព័ន្ធ FMIS ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងវិហ្វូរសាច់ប្រាក់ និងកិច្ចការគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ។ សមាសធាតុទាំងនេះមានបច្ច័យយ៉ាងសំខាន់ និងអាចបង្កភាពរាំងស្ទះដល់ការសម្រេចគោលបំណងនៃការកែទម្រង់ប្រព័ន្ធថវិកាដែលកំពុងតែបោះជំហានទៅមុខ។ ក្នុងន័យនេះ ការខ្វះយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការសម្របសម្រួល និងតាមដានការកែទម្រង់ប្រព័ន្ធថវិកាជាមួយនឹងការកែទម្រង់ដែលមានអន្តរទំនាក់ទំនងដទៃទៀតអាចបង្កើតជាហានិភ័យដល់ការសម្រេចបានគោលបំណងនៃជំហានទី៣និងទី៤ ក៏ដូចជា PFMRP ទាំងមូល។

លើសពីនេះទៀត ជំហានទី១និងជំហានទី២ ស្របជាមួយនឹងការអនុវត្តជំហានទី៣ នៅតែទាមទារឱ្យមានការកែលម្អបន្ថែមទៀត ជាពិសេស ការធានាទីរភាពនៃចំណូល ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តថវិកា រួមទាំងកិច្ចលទ្ធកម្មដែលត្រូវពង្រឹងបន្ថែម។ ប្រការសំខាន់គឺត្រូវធានាឱ្យបាននូវភាពជឿទុកចិត្តនៃថវិកា និងដំណើរការល្អនៃប្រព័ន្ធ FMIS សម្រាប់គណនេយ្យភាពសមិទ្ធកម្ម។

ទន្ទឹមនឹងនេះ ក្រៅពី PFMRP មានការដ្ឋានកែទម្រង់ពាក់ព័ន្ធសំខាន់ៗដទៃទៀត ជាពិសេស ការកែទម្រង់រដ្ឋបាលសាធារណៈ និង ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលកំពុងត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀតនៃរាជរដ្ឋាភិបាល ដែលអាចនឹងមានឥទ្ធិពលមកលើដំណើរការនៃការកែទម្រង់ប្រព័ន្ធថវិកា ក៏ដូចជាការសម្រេចគោលបំណងនៃដំណាក់កាលទី៣និងទី៤។ ក្រៅពីនេះ ក៏មានការចាំបាច់ក្នុងការកែលម្អនិងលើកកម្ពស់

ប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីជាមូលដ្ឋាននៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការពង្រឹងនិងលើកកម្ពស់តួនាទីនៃសវនកម្មឯករាជ្យ។ ការកែទម្រង់ទាំងនេះចាំបាច់ត្រូវអនុវត្តព្រមគ្នានិងត្រូវមានការសម្របសម្រួលល្អជាមួយនឹងការកែទម្រង់ក្នុងដំណាក់កាលទី៣និងទី៤ បើពុំនោះទេ គោលបំណងនៃ PFMRP អាចនឹងមិនសម្រេចបានឡើយ។

ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈមិនទាន់មានវឌ្ឍនភាពពេញលេញនិងគ្រប់គ្រាន់នៅឡើយ ដែលអាចជាឧបសគ្គក្នុងការសម្រេចគោលដៅនៅគ្រប់ជំហាននិងដំណាក់កាលទាំងអស់។ ការកែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈចាំបាច់ត្រូវពន្លឿនថែមទៀត ទើបអាចពង្រឹងមន្ត្រីរាជការស៊ីវិលឱ្យមានគណនេយ្យភាពចំពោះសមិទ្ធកម្ម។ ជាក់ស្តែង ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សបែបសមិទ្ធកម្មនិងប្រកបដោយប្រសិទ្ធភាពមួយនៃវិស័យសាធារណៈ មិនរំពឹងថានឹងអាចដាក់ឱ្យដំណើរការបានក្នុងរយៈពេលខ្លីនិងមធ្យមនោះទេ។ ប្រការនេះតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាបន្ថែមទៀត ដើម្បីជំរុញការកែទម្រង់រដ្ឋបាលសាធារណៈឱ្យទៅមុខ ជាពិសេស ក្នុងពេលអនុវត្តដំណាក់កាលទី៣និងទី៤។

នៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ទោះបីជាមុខងារមិនទាន់ត្រូវបានញែកដាច់ចេញពីគ្នាហើយក្តី ក៏ក្របខ័ណ្ឌឯកភាពមួយនៃប្រព័ន្ធថវិកានៅពុំទាន់មាននៅឡើយ។ ដំណើរការរៀបចំផែនការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានការតម្រឹមឱ្យស៊ីគ្នានិងបំពេញគ្នា ដើម្បីសម្រេចគោលបំណងរួម។ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តួនាទីនិងការទទួលខុសត្រូវគួរត្រូវកំណត់ឱ្យបានច្បាស់លាស់ថែមទៀត ដើម្បីជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌគណនេយ្យភាពឱ្យបានល្អជាងមុននិងការរៀបចំថវិកាឱ្យចំគោលដៅជាងមុន ដើម្បីធ្វើឱ្យមានគណនេយ្យភាពកាន់តែប្រសើរ។

## ១.៤. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌពេលវេលា

វឌ្ឍនភាពជារួមនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបានលទ្ធផលល្អគួរជាទីលើកទឹកចិត្ត។ លើសពីនេះ ការប្រកាន់យកនូវអភិក្រមនៃការផ្លាស់ប្តូរជាជំហានៗឬតាមដំណាក់កាលនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបង្កើតជីវភាពនៃការងារកែទម្រង់ ដោយអនុញ្ញាតឱ្យមានការផ្លាស់ប្តូរឬការពង្រឹងបន្ថែមផែនការសកម្មភាពរួម ផ្អែកលើបទពិសោធនៃការអនុវត្តជាក់ស្តែង។

ទោះជាយ៉ាងនេះក្តី ការវាយតម្លៃវឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើ **«ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ»** នៅឆ្នាំ២០១៥ បានផ្តល់មេរៀន បទពិសោធដ៏មានតម្លៃ និងបានចង្អុលបង្ហាញនូវបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាលទី៣និងទី៤។ ការវាយតម្លៃនោះបានគូសរំលេចថា ការសម្រេចបាននូវដំណាក់កាលទី៣នៅឆ្នាំ២០២០នឹងត្រូវផ្សារភ្ជាប់និងបំពេញគ្នាជាមួយវឌ្ឍនភាពនៃការកែទម្រង់រដ្ឋបាលសាធារណៈ និងវឌ្ឍនភាពកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

ទន្ទឹមនឹងនេះ ការសិក្សាពិនិត្យឡើងវិញអំពីការអនុវត្តថវិកាកម្មវិធី ធ្វើឡើងដោយធនាគារពិភពលោកកាលពីឆ្នាំ២០១៦ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាផ្នែកមួយនៃការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា

២០១៧-២០២០ បានដកស្រង់នូវបទពិសោធអន្តរជាតិជាច្រើនស្តីពីការរៀបចំថវិកាកម្មវិធីនិងបានផ្តល់អនុសាសន៍ស្តីពីទិសដៅអនាគតក្នុងការអនុវត្តថវិកាកម្មវិធីសម្រាប់កម្ពុជា។ ការសិក្សានេះបានបង្ហាញថាការអនុវត្តថវិកាកម្មវិធីពេញលេញអាចសម្រេចបានជោគជ័យ លុះត្រាតែមានប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល ដែលប្រព័ន្ធនេះមិនទាន់ត្រូវបានអនុវត្តនៅឡើយនៅកម្ពុជា ហើយម៉្យាងទៀតផ្អែកលើមេរៀននិងបទពិសោធនៃការអនុវត្តកន្លងមក ក្របខ័ណ្ឌពេលវេលាបច្ចុប្បន្ន សម្រាប់ការឈានទៅការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសមិទ្ធកម្មមានមហិច្ឆតាខ្លាំងពេក។ ក្នុងន័យនេះ ការសិក្សាពិនិត្យឡើងវិញនេះបានសន្និដ្ឋានថា ការចាប់អនុវត្តពេញលេញនូវការគ្រប់គ្រងថវិកាដោយផ្អែកលើសមិទ្ធកម្មនៅឆ្នាំ២០២០ គឺមិនមានភាពជាក់ស្តែង។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាមានការចាំបាច់ត្រូវពិនិត្យឡើងវិញអំពីទិសដៅយុទ្ធសាស្ត្រឱ្យបានកាន់តែច្បាស់លាស់ និងពេលវេលាឱ្យបានសមស្របដើម្បីធានាជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា។

៙៙✵៙៙

# ជំពូកទី២

## ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ បានបើកច្រកសម្រាប់ការកែទម្រង់ប្រព័ន្ធថវិកា ដោយការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកានិងចាប់ផ្តើមសាកល្បងថវិកាកម្មវិធី។ នៅខែមិថុនា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានអនុម័តឯកសារ ***«ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣- ២០២០»*** ដើម្បីជាមគ្គុទេសក៍សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។ ឯកសារទស្សនាទាននេះ គឺជាគន្លឹះក្នុងការតម្រង់ការងារកែទម្រង់ប្រព័ន្ធថវិការហូតមកដល់ពេលនេះ។ ការអនុវត្តក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ជាពិសេសបន្ទាប់ពីថវិកាកម្មវិធីពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅក្រសួង ស្ថាប័នមួយចំនួន រាជរដ្ឋាភិបាលបានយល់កាន់តែច្បាស់ថែមទៀត អំពីបញ្ហាប្រឈមក្នុងការអនុវត្តថវិកាកម្មវិធី។ នៅក្នុងកំលុងពេលនោះដែរ ថ្នាក់ដឹកនាំនិងមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើទស្សនកិច្ចសិក្សា ដកស្រង់បទពិសោធកាន់តែស៊ីជម្រៅ ពីបណ្តាប្រទេសដែលកំពុងអនុវត្តថវិកាសមិទ្ធកម្ម។ បទពិសោធទទួលបានពីទស្សនកិច្ចសិក្សា រួមផ្សំនឹងលទ្ធផលនៃការសិក្សាពិនិត្យឡើងវិញស្តីពីការអនុវត្តថវិកាកម្មវិធី បានឈានទៅរកសេចក្តីសន្និដ្ឋានជារួមថា ***ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ចាំបាច់ត្រូវកែសម្រួល ដើម្បីឱ្យមានភាពប្រាកដនិយមនិងច្បាស់លាស់ជាងមុន។*** ជំពូកទី២នេះនឹងពិនិត្យឡើងវិញនូវបណ្តាគោលបំណងពាក់ព័ន្ធនៃឯកសារទស្សនាទានបច្ចុប្បន្ន បទពិសោធ និងមេរៀនដែលទទួលបានពីការអនុវត្តជាក់ស្តែង និងដែលទទួលបានពីប្រទេសដទៃ ទឡ្ហីករណ៍ក្នុងការសម្រេចជ្រើសរើសទិសដៅឆ្ពោះទៅរកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មនៅឆ្នាំ២០២៥ និងសេចក្តីពន្យល់អំពីគោលដៅយុទ្ធសាស្ត្រនៃប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

### ២.១. ការពិនិត្យឡើងវិញលើឯកសារ «ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០»

**«ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ »** បានកំណត់គោលបំណងនៃការផ្លាស់ប្តូរជាបណ្តើរៗជាជំហានៗ ពី «ប្រព័ន្ធថវិកាផ្អែកលើធាតុចូលនិងមជ្ឈការ» ទៅរក «ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ» ត្រឹមឆ្នាំ២០២០។ ក្នុងទិសដៅនេះ ឯកសារទស្សនាទានបានកំណត់គោលបំណងនិងវិសាលភាពនៃការកែទម្រង់ក្នុងក្របខ័ណ្ឌនៃវដ្តថវិកា រួមមានការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកានិង ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម។ មកទល់នឹងពេលនេះ គោលបំណងនិងវិសាលភាពពាក់ព័ន្ធទៅនឹងនៃសមាសភាពបីខាងដើម ជាទូទៅ នៅតែមានសមានគតិភាពទៅនឹងបរិការណ៍បច្ចុប្បន្ននៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ។ ដោយឡែក ចំពោះការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម ដែលជាគោលបំណងនៃដំណាក់កាលទី៤នៅមិនទាន់មានសកម្មភាពធំដុំនៅឡើយទេ។ ទោះជាយ៉ាងនេះក្តី លទ្ធផលនៃការធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធពីប្រទេសដែលអនុវត្តថវិកាកម្មវិធីនិងថវិកាសមិទ្ធកម្ម បានបង្ហាញឱ្យឃើញពីភាព

ចាំបាច់ក្នុងការពិនិត្យឡើងវិញអំពីគោលបំណងនិងវិសាលភាពនៃការកែទម្រង់ទាំងនោះ ដើម្បីកែសម្រួលឱ្យមានសមានគតិភាពទៅនឹងឧត្តមានុវត្តជាអន្តរជាតិនាពេលបច្ចុប្បន្ន។

ដោយឡែក សម្រាប់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឯកសារទស្សនាទានបានចង្អុលទិសដៅកែទម្រង់ដោយតម្រឹមជាមួយនឹងប្រព័ន្ធថវិកាថ្នាក់ជាតិដូចខាងក្រោម៖

- គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

- ការផ្លាស់ប្ដូរជាជំហានៗនៃវដ្ដថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងវដ្ដថវិកាជាតិ។

- ប្រព័ន្ធនិងការគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងថ្នាក់ជាតិដោយប្រើប្រាស់ចំណាត់ថ្នាក់ថវិកា ប្លង់គណនី និងទម្រង់របាយការណ៍ដូចគ្នា។

ចំពោះទិសដៅនេះ លទ្ធផលនៃការសិក្សាពិនិត្យឡើងវិញបង្ហាញថា គោលបំណង និងវិសាលភាពនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិនៅតែមានសមានគតិភាពនិងមិនចាំបាច់សើរើឡើយ។

ដើម្បីអាចសម្រេចបាននូវគោលបំណងនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាត្រូវដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួន រួមមាន ការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការពង្រីកការអនុវត្តសាកល្បងថវិកាកម្មវិធី ការដាក់ឱ្យអនុវត្តអង្គភាពថវិកា ការអនុវត្តចំណាត់ថ្នាក់ថវិកាថ្មីជាមួយនឹងការកែសម្រួលប្លង់គណនេយ្យ និងការពង្រឹងនិងពង្រីកការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ព្រមទាំងការត្រៀមខ្លួនសម្រាប់ការដាក់ឱ្យអនុវត្ត «ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម» ចាប់ពីឆ្នាំ២០២០តទៅ។

សរុបមក ឯកសារទស្សនាទាននេះមានសារប្រយោជន៍ សម្រាប់ជាមគ្គុទ្ទេសក៍នៃការកែទម្រង់ប្រព័ន្ធថវិកាតាមអភិក្រមកែទម្រង់ជាបណ្ដើរៗនិងជាជំហានៗ ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមកដល់ពេលនេះ គឺកំពុងស្ថិតនៅក្នុងទិសដៅត្រឹមត្រូវ។ អភិក្រមបែបនេះ បានផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការផ្លាស់ប្ដូរនៅក្នុងប្រព័ន្ធថវិកា និងផ្ដល់លទ្ធភាពឱ្យគ្រប់ភាគីពាក់ព័ន្ធអាចរៀនសូត្រនិងដកបទពិសោធនៃការអនុវត្តជាក់ស្ដែង ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

## ២.២. វឌ្ឍនភាពនិងបញ្ហាប្រឈមនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា

បន្ទាប់ពីអនុវត្តថវិកាកម្មវិធីពេញលេញបានជាង២ឆ្នាំមក ការសិក្សាវាយតម្លៃលទ្ធផលនៃការអនុវត្តសាកល្បងដោយគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈខ្លួនឯង និងដោយធនាគារពិភពលោកក្នុងក្របខ័ណ្ឌនៃPFMRP បានបង្ហាញថា ***«កម្ពុជាមានវឌ្ឍនភាពល្អប្រសើរក្នុងការអនុវត្តថវិកាកម្មវិធី»***។ ការសិក្សាបានរកឃើញថាកត្តាគន្លឹះមួយនៃវឌ្ឍនភាពនេះ គឺការផ្ដួចផ្ដើមដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា។ លើសពីនេះ ការកំណត់នូវចំនួនគោលបំណងគោលនយោបាយ កម្មវិធីនិងសូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា គឺជាចំណុច

វិជ្ជមានក្នុងការជំរុញឱ្យផ្តោតការយកចិត្តទុកដាក់លើសមិទ្ធកម្មឱ្យបានកាន់តែខ្លាំងឡើង។ ការកែលម្អស្ថានភាពប៉ាន់ប្រមាណបាននៃថវិកា បង្កើតបាននូវបរិយាកាសល្អប្រសើរ ដល់ការរៀបចំផែនការថវិកា។

ជាក់ស្តែង បន្ទាប់ពីបញ្ចប់ដំណាក់កាលសាកល្បងអនុវត្តថវិកាកម្មវិធីមិនពេញលេញនៅឆ្នាំ២០១៤ ការសាកល្បងថវិកាកម្មវិធីពេញលេញត្រូវបានដាក់អនុវត្តនៅក្រសួងចំនួន១០ ក្នុងឆ្នាំ២០១៥ និងត្រូវបានពង្រីកទៅដល់ចំនួន៣៦ ក្រសួង ស្ថាប័ន ក្នុងឆ្នាំ២០១៧ ព្រមជាមួយនឹងការចាប់ផ្តើមអនុវត្តចំពោះរដ្ឋបាលខេត្តចំនួន៦ផងដែរ។ តាមទិសដៅនេះ គ្រប់ក្រសួង ស្ថាប័នទាំងអស់នឹងត្រូវអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៨។ ក្រសួង ស្ថាប័នទាំងអស់ ត្រូវបានតម្រូវឱ្យរៀបចំថវិកាប្រចាំឆ្នាំ ទៅតាមគោលបំណង គោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព សម្រាប់ការចរចារៀបចំកញ្ចប់ថវិកា និងអនុវត្តផ្ទាល់ដោយអង្គភាពថវិកានៃក្រសួង ស្ថាប័ន។ ទោះជាយ៉ាងនេះក្តី ក្នុងដំណាក់កាលសាកល្បងនេះ ការរៀបចំថវិកាតាមធាតុចូលនៅតែជាឯកសារផ្លូវការសម្រាប់ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័ត។

ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកាមានដំណើរការល្អ ជាមួយនឹងការរៀបចំថវិកាប្រចាំឆ្នាំកាន់តែគ្រប់ជ្រុងជ្រោយទៅតាមដំណាក់កាលនិងពេលវេលាច្បាស់លាស់។ ការកំណត់ចំនួនគោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា(BSP) បានធ្វើឱ្យដំណើរការរៀបចំនិងអនុវត្តថវិកាកម្មវិធីកាន់តែមានប្រសិទ្ធភាពនិងគ្រប់គ្រងបាន។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ការបណ្តុះបណ្តាលការគាំទ្រផ្នែកបច្ចេកទេសនិងមគ្គុទ្ទេសក៍ជាច្រើនដល់ក្រសួង ស្ថាប័ន ការអនុវត្តថវិកាកម្មវិធីក៏ទទួលបានការគាំទ្រនិងចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន ទាំងកម្រិតនយោបាយនិងទាំងកម្រិតបច្ចេកទេស។

ចំណាត់ថ្នាក់ថវិកាចំនួនប្រាំពីរ រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់កម្មវិធី ចំណាត់ថ្នាក់ប្រភពថវិកា និងចំណាត់ថ្នាក់គម្រោង ត្រូវបានប្រកាសឱ្យប្រើប្រាស់។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ត្រូវបានប្រកាសដាក់ឱ្យចាប់ផ្តើមដំណើរការជាផ្លូវការនៅឆ្នាំ២០១៥ និងត្រូវបានពង្រាយទៅតាមអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្តនៅឆ្នាំ២០១៦។

ជាមួយនឹងវឌ្ឍនភាពខាងលើ ការសិក្សានេះបានគូសបញ្ជាក់ឱ្យឃើញនូវចំណុចខ្វះខាតមួយចំនួនដែលទាមទារនូវដំណោះស្រាយ រួមមាន

- ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើងដោយមិនមានការកំណត់ពិដានចំណាយ ដែលធ្វើឱ្យក្រសួង ស្ថាប័នប្រើប្រាស់ផែនការយុទ្ធសាស្ត្រថវិកាជាឧបករណ៍ ដើម្បីទាមទារដំឡើងថវិកាមិនសមហេតុផល។ នៅពេលចាប់ផ្តើមអនុវត្តដំបូង គម្រោងចំណាយនៃផែនការយុទ្ធសាស្ត្រថវិកាត្រូវបានគ្រោងលើសពីថវិកាជាក់ស្តែងឆ្នាំអនុវត្តដល់ទៅ១០០%។ មកដល់ឆ្នាំ២០១៥ ទោះបីការគ្រោងថវិកាលើសត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ក៏ផែនការយុទ្ធសាស្ត្រថវិកាមួយចំនួនធំនៅតែគ្រោងលើសប្រមាណពី៤០%ទៅ៥០% ដែលបញ្ហានេះបានបង្កជាការលំបាកដល់ការវិភាជថវិកាឱ្យចំគោលដៅ ហើយការចរចាថវិកានៅតែផ្តោតទៅលើចំណាត់ថ្នាក់សេដ្ឋកិច្ចជាជាងផ្តោតទៅលើចំណាត់ថ្នាក់កម្មវិធី។

- ការប៉ាន់ស្មានចំណាយមូលធនមិនទាន់ច្បាស់លាស់និងមិនទាន់បំបែកចំណាយបុគ្គលិកនិងមុខសញ្ញាចំណាយធំៗមួយចំនួនដែលជាកម្មវត្ថុនៃនីតិវិធីលទ្ធកម្មសាធារណៈ ទៅតាមកម្មវិធី។
- ការរៀបចំខ្លឹមសារនៃផែនការយុទ្ធសាស្ត្រថវិកាក៏នៅមានភាពទន់ខ្សោយ ដោយសារការយល់ដឹងផ្នែកទស្សនាទាននៅមានកម្រិត ហើយសមត្ថភាពខុសៗគ្នានៃក្រសួង ស្ថាប័ន បានធ្វើឱ្យការរៀបចំរចនាសម្ព័ន្ធកម្មវិធីនៅមិនទាន់បានល្អ។
- ការកំណត់សូចនាករសមិទ្ធកម្មមិនទាន់បានល្អដោយសារបញ្ហាសមត្ថភាពនិងមិនទាន់មានយន្តការប្រមូលនិងផ្តល់ព័ត៌មានអំពីសូចនាករទាំងនេះ នៅមានលក្ខណៈដាច់ដោយឡែកពីគ្នានិងដោយដុំៗ តាមក្រសួង ស្ថាប័ន។ ម៉្យាងវិញទៀត កង្វះទិន្នន័យជាទៀងទាត់និងអាចជឿជាក់បាន ក៏ជាមូលហេតុចម្បងដែលធ្វើឱ្យរបាយការណ៍អំពីសូចនាករសមិទ្ធកម្មសំខាន់ៗមិនអាចយកទៅប្រើប្រាស់បានក្នុងគោលដៅរៀបចំផែនការថវិកាឱ្យមានប្រសិទ្ធភាព។
- ធនធានមនុស្សនៅមិនទាន់មានគ្រប់គ្រាន់ និងសមត្ថភាពមានកម្រិត ជាឧបសគ្គចំពោះគណនេយ្យភាពសមិទ្ធកម្មនៃកម្មវិធីនីមួយៗ។ ទន្ទឹមនឹងនេះ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈប្រកបដោយប្រសិទ្ធភាពនិងផ្អែកលើសមិទ្ធកម្ម មិនរំពឹងថានឹងអាចសម្រេចបានមុនឬត្រឹមឆ្នាំ២០២០នោះទេ។

ជារួម ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មពេញលេញអាចនឹងសម្រេចបាន លុះត្រាតែស្ថិតនៅក្នុងបរិការណ៍រួមនៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដែលក្នុងនោះ អ្នកគ្រប់គ្រងកម្មវិធីមានសិទ្ធិក្នុងការចាត់ចែងធនធាន សមិទ្ធកម្មអាចវាស់វែងបាន និងមានរបាយការណ៍ត្រឹមត្រូវ កម្មវិធីត្រូវបានវាយតម្លៃជាទៀងទាត់ អ្នកគ្រប់គ្រងកម្មវិធីត្រូវមានគណនេយ្យភាពលើសមិទ្ធកម្ម និងមានការលើកទឹកចិត្តផ្អែកតាមសមិទ្ធកម្ម។ សម្រាប់កម្ពុជា ធាតុសំខាន់ៗដែលជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដូចបានរៀបរាប់មកនេះ នៅពុំទាន់មានឬមិនទាន់រៀបចំឱ្យបានគ្រប់គ្រាន់នៅឡើយ ដែលជាឧបសគ្គក្នុងការសម្រេចបានប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មពេញលេញ នៅក្នុងរយៈពេលមធ្យម។

## ២.៣. គំរូនៃប្រព័ន្ធថវិកាសមិទ្ធកម្មនិងបទពិសោធអន្តរជាតិ

ជាក់ស្តែង ប្រព័ន្ធថវិកាសមិទ្ធកម្មមិនទាន់មានបទដ្ឋានឬនិយមន័យបច្ចេកទេសជាក់លាក់នៅឡើយទេ។ ការកែទម្រង់ប្រព័ន្ធថវិកាសមិទ្ធកម្ម នៅពេលខ្លះត្រូវបានគេហៅថា «ប្រព័ន្ធថវិកាផ្អែកលើលទ្ធផលឬសមិទ្ធកម្ម» «ប្រព័ន្ធថវិកាកម្មវិធី» ឬ «ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»។ ប្រទេសជាច្រើន ទាំងប្រទេសអភិវឌ្ឍ ទាំងប្រទេសកំពុងអភិវឌ្ឍបាននិងកំពុងអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្ម តាមគំរូផ្សេងៗគ្នា អាស្រ័យទៅតាមដំណាក់កាលនៃការអភិវឌ្ឍ រចនាសម្ព័ន្ធស្ថាប័ន និងអំណាចនីតិប្បញ្ញត្តិ។ យោងតាមឯកសារចងក្រងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ថវិកាសមិទ្ធកម្មត្រូវបានធ្វើចំណាត់ថ្នាក់ជាបីគំរូ ដូចខាងក្រោម៖

- **ប្រព័ន្ធថវិកាបង្ហាញសមិទ្ធកម្ម** ក្នុងគំរូនេះ ព័ត៌មានសមិទ្ធកម្មមានបង្ហាញក្នុងឯកសារថវិកាឬឯកសារផ្សេងៗរបស់រដ្ឋាភិបាល។ ព័ត៌មានសមិទ្ធកម្មសំដៅដល់គោលដៅ ឬលទ្ធផល ឬទាំងពីរ និងត្រូវបានបញ្ចូលជាសារតាសម្រាប់គណនេយ្យភាពនិងសម្រាប់កិច្ចពិភាក្សាអំពីបញ្ហាគោលនយោបាយសាធារណៈជាមួយស្ថាប័ន

នីតិប្បញ្ញត្តិនិងសាធារណៈជន។ ព័ត៌មានសមិទ្ធកម្មទាំងនោះមិនមានឥទ្ធិពលជាផ្លូវការចំពោះការសម្រេចនានា នៅក្នុងដំណើរការរៀបចំថវិកានោះទេ។

- **ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម** តាមគំរូនេះ ការរៀបចំកញ្ចប់ថវិកាមានការពាក់ព័ន្ធជាប្រយោលជាមួយនឹងសមិទ្ធកម្មដែលបានស្នើឡើងឬដែលសម្រេចបានកន្លងមក ដោយក្រសួង ស្ថាប័ន។ ព័ត៌មានសមិទ្ធកម្មមានតួនាទីសំខាន់ ប៉ុន្តែមិនមែនជាទម្ងន់ឬជាកត្តាកំណត់ដាច់ខាតសម្រាប់ធ្វើការសម្រេចលើការវិភាជថវិកានោះទេ។ ក្នុងន័យនេះ ព័ត៌មានសមិទ្ធកម្មមិនមែនជាមូលដ្ឋានតែមួយគត់នោះទេ ប៉ុន្តែត្រូវប្រើគួបផ្សំជាមួយនឹងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងសេដ្ឋកិច្ច នយោបាយ និងអាទិភាពគោលនយោបាយសម្រាប់ការសម្រេចលើការវិភាជថវិកាឬធនធាន។
- **ប្រព័ន្ធថវិកាសមិទ្ធកម្មផ្ទាល់ឬប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម** តាមគំរូនេះ ការវិភាជធនធានធ្វើឡើងដោយផ្ទាល់និងច្បាស់លាស់ ទៅតាមឯកតាសមិទ្ធកម្មដែលត្រូវសម្រេចបាន ដែលជាទូទៅ គឺផ្តោតលើលទ្ធផលក្នុងឆ្នាំ។

បទពិសោធនៃបណ្តាប្រទេសសមាជិក OECD បានបង្ហាញថាការអនុវត្ត «ប្រព័ន្ធថវិកាសមិទ្ធកម្មផ្ទាល់ឬប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម» គឺជាការលំបាក សូម្បីតែនៅក្នុងប្រទេសដែលមានធនធានច្រើននិងមានស្ថាប័នរឹងមាំ។ ប្រព័ន្ធថវិកាគំរូនេះត្រូវបានប្រើប្រាស់តែនៅក្នុងប្រទេសមួយចំនួនតូចប៉ុណ្ណោះនៃអង្គការ OECD ផ្ទុយទៅវិញ ប្រទេសសមាជិកភាគច្រើនកំពុងប្តូរមកអនុវត្ត «ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»។

ជាក់ស្តែង បទពិសោធពីទស្សនកិច្ចសិក្សាអំពីការអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្មនៅប្រទេសស៊ុយអែត ម៉ាឡេស៊ី បារាំង និងថៃ បានបង្ហាញថាមានចំណោទនិងបញ្ហាស្រដៀងៗគ្នាជាច្រើន ជាពិសេស នៅក្នុងដំណាក់កាលនៃការរៀបចំថវិកា។ ប្រទេសទាំងនោះសុទ្ធតែផ្អែកលើអាទិភាពឬរបៀបវារៈជាតិជាគោល រួចបំបែកចុះមកក្រោមជាកម្មវិធីនិងអនុកម្មវិធីសម្រាប់ការអនុវត្ត។ កម្រិតនៃការប្រើប្រាស់ព័ត៌មានសមិទ្ធកម្មប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយទៀត ហើយត្រូវបានប្រើប្រាស់ដើម្បីតម្រង់ទិសការចរចាថវិកានិងត្រួតពិនិត្យសមិទ្ធកម្ម។ ប្រទេសស៊ុយអែតស្ថិតក្នុងចំណោមប្រទេសដែលមានភាពជឿនលឿនបំផុតមួយ នៅក្នុងការប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម ប៉ុន្តែប្រព័ន្ធថវិកានៃប្រទេសនេះមានលក្ខណៈពិសេសដោយឡែក ដែលទទួលមរតកពីដំណើរវិវត្តយូរលង់នៃប្រព័ន្ធនយោបាយ សង្គម សេដ្ឋកិច្ច វប្បធម៌។ នៅក្នុងប្រទេសថៃនិងប្រទេសម៉ាឡេស៊ី ការប្រើប្រាស់ព័ត៌មានសមិទ្ធកម្មតិចតួចសម្រាប់ការចរចានិងរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ ប៉ុន្តែព័ត៌មានសមិទ្ធកម្មត្រូវបានប្រើច្រើនក្នុងការរៀបចំរបាយការណ៍។ ដោយឡែក នៅប្រទេសបារាំង ព័ត៌មានសមិទ្ធកម្មត្រូវបានប្រើប្រាស់ទូលំទូលាយនៅក្នុងដំណើរការនៃការរៀបចំថវិកា ប៉ុន្តែការវិភាជថវិកាមិនផ្អែកទាំងស្រុងទៅលើសមិទ្ធកម្មទេ។ សូមពិនិត្យបន្ថែមសេចក្តីលម្អិតនៃបទពិសោធរបស់ប្រទេស OECD ប្រទេសស៊ុយអែត បារាំង ម៉ាឡេស៊ី និងថៃ ដែលមាននៅក្នុងឧបសម្ព័ន្ធ១។

ជារួម តាមបទពិសោធរបស់ប្រទេសទាំងបួនខាងលើ ការកែទម្រង់ប្រព័ន្ធថវិកានៅប្រទេសបារាំងផ្តល់នូវមេរៀនដ៏មានតម្លៃក្នុងការតម្រង់ទិស សម្រាប់ការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដោយសារកម្ពុជាធ្លាប់បានអនុវត្តប្រព័ន្ធថវិកាដែលមានលំនាំពីប្រព័ន្ធបារាំង ហើយការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាបាន និងកំពុងធ្វើដំណើរតាមទិសដៅ

និងអភិក្រមប្រហាក់ប្រហែលនឹងប្រព័ន្ធថវិកាបច្ចុប្បន្នរបស់បារាំង។ ក្នុងន័យនេះ គំរូបារាំងអាចចាត់ទុកជាមូលដ្ឋានសមស្របសម្រាប់កម្ពុជាពិចារណាក្នុងការកែទម្រង់ប្រព័ន្ធថវិការបស់ខ្លួន។

**២.៤. ជម្រើសសម្រាប់កម្ពុជា**

មកទល់នឹងពេលនេះ នៅក្រោមក្របខ័ណ្ឌបច្ចុប្បន្ននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្ពុជាបាននិងកំពុងខិតខំកែទម្រង់ប្រព័ន្ធថវិការបស់ខ្លួនឆ្ពោះរកគោលដៅ «ប្រព័ន្ធថវិកាដោយផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម»។ ទោះបីជាដំណើរនៃការកែទម្រង់នេះត្រូវបានចាត់ទុកថាកំពុងស្ថិតនៅលើគន្លងផ្លូវត្រឹមត្រូវក៏ដោយ ក៏បញ្ហាសំខាន់នៅពេលនេះគឺ កម្ពុជាមានភាពចាំបាច់ក្នុងការពិនិត្យឡើងវិញនូវគោលដៅប្រកបដោយមហិច្ឆតានេះ ដោយផ្អែកលើបទពិសោធនៃការអនុវត្តជាក់ស្តែងរបស់ខ្លួនកន្លងមក និងដោយផ្អែកលើឧត្តមានុវត្តន៍អន្តរជាតិថ្មីៗ។

បទពិសោធអន្តរជាតិបានបង្ហាញថាបណ្តាប្រទេសភាគច្រើនជួបការលំបាកក្នុងការអនុវត្តប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម ទោះបីជាប្រទេសទាំងនោះមានធនធានច្រើនក៏ដោយ ហើយជាទូទៅបានដកថយពីការដាក់ឱ្យអនុវត្ត «ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មពេញលេញ» មកជា«ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»វិញ។ ប្រទេសដែលសម្រេចបានវឌ្ឍនភាពល្អប្រសើរក្នុងការអនុវត្តប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម គឺដោយសារប្រព័ន្ធថវិកាជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល។ នៅក្នុងប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល ទាំងផែនការនីយកម្ម ទាំងការគ្រប់គ្រងធនធានមនុស្ស និងទាំងការគ្រប់គ្រងថវិកា ត្រូវបានតម្រែតម្រង់និងតម្រឹមរវាងគ្នាទាំងអស់ ដើម្បីសម្រេចគោលនយោបាយរបស់រដ្ឋាភិបាល និងដោយមានប្រព័ន្ធទិន្នន័យដែលអាចជឿទុកចិត្តបានសម្រាប់ការសម្រេចនានា។ ប្រធានអង្គភាពថវិកាត្រូវបានបណ្តុះបណ្តាលយ៉ាងល្អនិងផ្តល់ប្រតិភូកម្មអំណាចគ្រប់គ្រាន់ សម្រាប់គ្រប់គ្រងថវិកានិងធនធាន។

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន បុរេលក្ខខណ្ឌចាំបាច់ទាំងនេះនៅមិនទាន់មានគ្រប់គ្រាន់ដើម្បីអាចជាមូលដ្ឋានក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៅឡើយទេ។ ប្រការនេះមានន័យថាកម្ពុជាមិនទាន់អាចអនុវត្តប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មបានទេ ក្នុងរយៈពេលមធ្យមខាងមុខ។ និយាយម្យ៉ាងទៀត «ប្រព័ន្ធថវិកាសមិទ្ធកម្មផ្ទាល់» ដែលជាគំរូមួយនៃប្រព័ន្ធថវិកាសមិទ្ធកម្ម នឹងមិនមែនជាជម្រើសសម្រាប់កម្ពុជាទេ។

ការសិក្សាពិនិត្យឡើងវិញអំពីថវិកាកម្មវិធី ដោយអ្នកជំនាញនៃធនាគារពិភពលោក ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានផ្តល់អនុសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាគួរកែសម្រួលទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកាពី «ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មឬលទ្ធផល»ទៅជា «ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»វិញ។ ការវាយតម្លៃដោយផ្អែកលើបទពិសោធនៃការអនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញរយៈពេលបីឆ្នាំនិងវឌ្ឍនភាពថ្មីៗនៃការកែទម្រង់ប្រព័ន្ធថវិការបស់ប្រទេសដទៃទៀត ក៏បានផ្តល់សេចក្តីសន្និដ្ឋានដូចគ្នានឹងការសិក្សានោះដែរ។ អាស្រ័យហេតុនេះ កម្ពុជាសម្រេចជ្រើសរើសយកគំរូ **«ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»** (Performance-Informed Budgeting) ជាទិសដៅជាក់លាក់ ដើម្បីកសាងប្រព័ន្ធថវិការបស់ខ្លួនស្របតាមឧត្តមានុវត្តអន្តរជាតិ។ ចាប់ពីពេលនេះទៅ ប្រព័ន្ធថវិកាកម្ពុជាត្រូវបានហៅកាត់ថា **«ថវិកាសមិទ្ធកម្ម»** (Performance Budgeting-PB) ។

## ២.៥. ការកំណត់ទិសដៅ និងក្របខ័ណ្ឌពេលវេលាថ្មីនៃការកែទម្រង់ប្រព័ន្ធថវិកា

ឯកសារទស្សនាទានស្ដីអំពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ បានកំណត់គោលដៅនៃការសម្រេច **«ថវិកាផ្អែកលើសមិទ្ធកម្ម»** ឱ្យបាននៅឆ្នាំ២០២០។ ក៏ប៉ុន្តែផ្អែកតាមការសិក្សាពិនិត្យឡើងវិញដូចបានអធិប្បាយខាងលើ សន្និដ្ឋានថាក្របខ័ណ្ឌពេលវេលានេះមិនសមស្រប នៅក្នុងបរិការណ៍កម្ពុជាទេ។ ដូចនេះ ជាមួយនឹងការសម្រេចជ្រើសរើសយក **«ថវិកាសមិទ្ធកម្ម»** ជាទិសដៅជាក់លាក់ រាជរដ្ឋាភិបាលបានសម្រេចរៀបចំជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាដែលមានរយៈពេលវែង គ្រប់ជ្រុងជ្រោយ និងមានពេលវេលាសមស្រប សម្រាប់ធ្វើការផ្លាស់ប្ដូរប្រព័ន្ធនេះជាជំហានៗ ប្រកបដោយភាពប្រាកដនិយម។

ដោយសារការកែទម្រង់ប្រព័ន្ធថវិកា គឺជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធថវិកាមិនអាចធ្វើឡើងដាច់ដោយឡែកឬគ្មានសមកាលកម្ម ជាមួយនឹងការកែទម្រង់ផ្សេងទៀតនៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះបានទេ។ ការកែទម្រង់នេះទៀតសោតត្រូវការការគាំទ្រពីការងារកែទម្រង់សំខាន់ៗផ្សេងទៀតដូចជា ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការពង្រឹងមុខងារសវនកម្មជាដើម។ ក្នុងន័យនេះ យុទ្ធសាស្ត្រនៃការកែទម្រង់នេះ ត្រូវផ្ដល់ជាអភិក្រមគ្រប់ជ្រុងជ្រោយមួយ ដើម្បីធានាឱ្យការកែទម្រង់ដទៃទៀតនៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការដ្ឋានកែទម្រង់សំខាន់ៗដទៃទៀតរបស់រាជរដ្ឋាភិបាល អាចផ្សារភ្ជាប់គ្នានិងបំពេញឱ្យគ្នាទៅវិញទៅមកបាន។

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជានឹងត្រូវផ្ដោតជាចម្បងទៅលើប្រព័ន្ធថវិកាជាតិ ក៏ដូចជាផ្ដល់នូវគោលការណ៍និងមគ្គុទ្ទេសក៍សម្រាប់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដើម្បីឈានទៅសម្រេចបាននូវលទ្ធផល និងគោលបំណងគោលនយោបាយរបស់ប្រទេសជាតិតែមួយរួមគ្នា តាមរយៈការធ្វើសមាហរណកម្មការធ្វើផែនការ ការគ្រប់គ្រងថវិកា និងប្រព័ន្ធរបាយការណ៍ ដោយប្រើប្រាស់អភិក្រមដែលមានសុខដុមនីយកម្មនឹងគ្នា។ អភិក្រមនេះនឹងមិនត្រឹមតែមិនប៉ះពាល់ទៅដល់ដំណើរការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលកំពុងអនុវត្តបច្ចុប្បន្ននោះទេ ប៉ុន្តែថែមទាំងជួយជំរុញឱ្យការផ្ទេរមុខងារ និងការធ្វើប្រតិភូកម្មការអនុវត្តថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅបានកាន់តែរលូន។

ដោយផ្អែកលើការវាយតម្លៃជារួមអំពីស្ថានភាពបច្ចុប្បន្ននិងភាពស្មុគស្មាញនៃការកែទម្រង់ដែលនឹងត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃប្រព័ន្ធ**«ថវិកាសមិទ្ធកម្ម»** ពេលវេលាសមស្របបំផុតក្នុងការសម្រេចគោលដៅនេះ គឺឆ្នាំ២០២៥។ ដូច្នេះ យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកានឹងគ្របដណ្ដប់ការងារកែទម្រង់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៥ ហៅថា **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»** ដែលជាគោលការណ៍តម្រង់ទិសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ហើយតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ពិនិត្យឡើងវិញនូវការដ្ឋានកែទម្រង់របស់ខ្លួនឱ្យមានសង្គតិភាពទាំងគោលការណ៍ និងក្របខ័ណ្ឌពេលវេលា ទៅតាមយុទ្ធសាស្ត្រនេះ។

៙៙៙

# ជំពូកទី៣

## យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

គោលដៅជាសារវន្តនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ គឺដើម្បីឈានឆ្ពោះទៅអនុវត្ត **ថវិកាសមិទ្ធកម្ម** ស្របតាមទិសដៅជាយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងគណនេយ្យភាពសមិទ្ធកម្ម នៅឆ្នាំ២០២៥។ នៅក្នុងប្រព័ន្ធនេះ ថវិកាត្រូវបានរៀបចំឡើងផ្អែកតាមកម្មវិធី ព្រមជាមួយនឹងការវាស់វែងលទ្ធផលដែលត្រូវសម្រេចបាន ដោយផ្អែកលើក្របខ័ណ្ឌសមិទ្ធកម្មមួយច្បាស់លាស់។ ក្នុងគោលដៅនេះ កិច្ចដំណើរការរៀបចំគម្រោងថវិកានឹងត្រូវបើកឱ្យមានការចូលរួមកាន់តែទូលាយ និងមានតម្លាភាព ហើយការពិនិត្យពិនិស្ច័យថវិកានឹងត្រូវបានលើកកម្ពស់ថែមទៀតនៅស្ថាប័ននីតិប្បញ្ញត្តិ។ ទន្ទឹមនឹងនេះ ការអនុវត្តថវិកានឹងត្រូវបានបង្កើនប្រសិទ្ធភាពថែមទៀត តាមរយៈការកែលម្អ និងការធ្វើសាមញ្ញកម្មនីតិវិធីចំណាយ ការរៀបចំរបាយការណ៍ទាន់ពេលវេលាស្របតាមបទដ្ឋានអន្តរជាតិ ការធ្វើទំនើបកម្មប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ព្រមទាំងមានក្របខ័ណ្ឌប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ។ ក្នុងន័យនេះ សមត្ថភាពធនធានមនុស្សនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននឹងត្រូវពង្រឹងជាបន្តបន្ទាប់ទៀត ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរទាំងនេះ។

ជំពូកនេះនឹងរៀបរាប់អំពីការកែទម្រង់សមាសធាតុគន្លឹះចំនួនបួននៃវដ្តថវិកានិងការកំណត់ទិសដៅឆ្នាំ២០២៥។ ដើម្បីធានាប្រសិទ្ធភាពនិងចីរភាពនៃការកែទម្រង់ សមាសធាតុគន្លឹះនីមួយៗ ចាំបាច់ត្រូវធ្វើស្ថាប័ននីយកម្ម។ ក្រៅពីនេះ នៅមានការកែទម្រង់មួយចំនួនទៀតនៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បើទោះបីជាមិនត្រូវបានចាត់ទុកថាជាសមាសធាតុគន្លឹះក្តី ក៏សមាសធាតុទាំងនេះមានបច្ច័យខ្ពស់ ឬមានការផ្សារភ្ជាប់ ឬមានអន្តរទំនាក់ទំនងទៅនឹងប្រព័ន្ធថវិកាដែរ ដែលជាហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់។ សមាសធាតុទាំងនោះនឹងមិនត្រូវលើកយកមកពិភាក្សាលម្អិតនៅក្នុងយុទ្ធសាស្ត្រនេះទេ ដោយសារការកែទម្រង់នៃសមាសធាតុទាំងនោះ មាននៅក្នុងឯកសារយុទ្ធសាស្ត្រ ឬផែនការផ្សេងទៀតរួចហើយ នៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.១. ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ

ការរៀបចំថវិការយៈពេលមួយឆ្នាំ គឺជាពេលវេលាខ្លីពេក ដោយសារការឈានទៅបិទបញ្ចប់កម្មវិធីឬរៀបចំកម្មវិធីថ្មី ទាមទារពេលវេលាយូរ ដែលជាទូទៅ ច្រើនជាងមួយឆ្នាំ។ ក្នុងន័យនេះ ថវិកាប្រចាំឆ្នាំអាចឆ្លុះបញ្ចាំងការផ្លាស់ប្តូរទិសដៅនៃចំណាយបានប្រកបដោយប្រសិទ្ធភាព លុះត្រាតែមានការព្យាកររយៈពេលមធ្យម។ ដូចនេះ បុរេនិទស្សន៍រយៈពេលមធ្យមនៃថវិកាប្រចាំឆ្នាំ គឺជាការចាំបាច់។

បច្ចុប្បន្ននេះ កម្ពុជាបានដាក់បញ្ចូលបុរេនិទស្សន៍រយៈពេលមធ្យម ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងតាមអភិក្រមពីលើចុះក្រោមទៅតាមទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងនិន្នាការចំណូលនិងចំណាយ។

ដោយឡែក «ក្របខ័ណ្ឌថវិកា» ត្រូវបានរៀបចំដោយដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីផ្តល់ព័ត៌មានដល់ក្រសួង ស្ថាប័ន អំពីលទ្ធភាពនិងអាទិភាពចំណាយ និងសក្តានុពលចំណូលនៃឆ្នាំថវិកា និងពីរឆ្នាំទៅមុខ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺត្រូវធ្វើស្ថាប័ននីយកម្មផែនការថវិការយៈពេលមធ្យម ហើយផែនការនោះនឹងត្រូវដាក់ឱ្យក្រសួង ស្ថាប័នទាំងអស់អនុវត្ត។ ការធ្វើផែនការថវិការយៈពេលមធ្យមមាន៣សមាសធាតុដូចខាងក្រោម៖

- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
- ក្របខ័ណ្ឌថវិការយៈពេលមធ្យម និង
- ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត

ក្របខ័ណ្ឌនិងផែនការទាំងអស់ខាងលើនឹងត្រូវបានរៀបចំនិងធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ដោយបង្ហាញពីបុរេនិទស្សន៍រយៈពេលបីឆ្នាំរំកិលទៅមុខ។ ផែនការថវិការយៈពេលមធ្យមត្រូវមានភាពគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលនូវប្រភពហិរញ្ញប្បទានគ្រប់ប្រភេទ រួមទាំងហិរញ្ញប្បទានក្រៅប្រទេសនិងចំណាយគ្រប់ប្រភេទ រួមមាន ចរន្ត មូលធន ការវិនិយោគ ហិរញ្ញប្បទានឥតសំណង ការផ្ទេរសាច់ប្រាក់ ឧបត្ថម្ភធន។ល។ ទន្ទឹមនឹងការធ្វើស្ថាប័ននីយកម្មផែនការថវិការយៈពេលមធ្យមខាងលើ ការកែទម្រង់ប្រព័ន្ធថវិកាអាចនឹងនាំឱ្យមានតម្រូវការក្នុងការពិនិត្យឡើងវិញអំពីប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំក្នុងពេលបច្ចុប្បន្ន។

### ៣.១.១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

គំរូម៉ាក្រូសេដ្ឋកិច្ចផ្តល់ជាមូលដ្ឋានសំខាន់ក្នុងការព្យាករកំណើនតាមវិស័យនៃសេដ្ឋកិច្ច អត្រាអតិផរណា អត្រាការប្រាក់ អត្រាប្តូរប្រាក់ ចំណូលចំណាយសាធារណៈ។ល។ ដោយផ្អែកលើសម្មតិកម្មអំពីអន្តរសកម្មភាពនៃវិស័យទាំងឡាយនៅក្នុងសេដ្ឋកិច្ច ក៏ដូចជាផលប៉ះពាល់ពីព្រឹត្តការណ៍យថាហេតុផ្សេងៗនៃសេដ្ឋកិច្ចពិភពលោក។ ភាពជឿទុកចិត្តបាននៃការព្យាករ គឺអាស្រ័យទៅលើគំរូសេដ្ឋកិច្ចនិងសម្មតិកម្ម ដែលអាចឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច។ លទ្ធផលនៃការព្យាករទាំងនេះ គឺជាមូលដ្ឋានសម្រាប់កំណត់ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ។

គោលបំណងនៅឆ្នាំ២០២៥ គឺការកែលម្អគុណភាពនៃការព្យាករម៉ាក្រូសេដ្ឋកិច្ច តាមរយៈការពង្រឹងវិធីសាស្ត្រនៃការព្យាករ ការកសាងសមត្ថភាព ការសម្របសម្រួល និងការផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័នរាជរដ្ឋាភិបាល ដែលពាក់ព័ន្ធរួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានិងក្រសួងផែនការ។ ម៉្យាងទៀត ស្ថាប័នអន្តរជាតិនានាអាចដើរតួនាទីបំពេញបន្ថែមនិងផ្តល់បច្ចេកទេសក្នុងការកែលម្អនេះ។ ក្នុងន័យនេះ គុណភាពនៃទិន្នន័យ ទាំងម៉ាក្រូសេដ្ឋកិច្ច ទាំងហិរញ្ញវត្ថុសាធារណៈ ត្រូវធ្វើការកែលម្អឱ្យទាន់ពេលវេលានិងកាន់តែសុក្រឹតថែមទៀត។

### ៣.១.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមផ្តោតលើការប្រកាន់ខ្ជាប់នូវគោលបំណងនិងវិធាននៃហិរញ្ញវត្ថុសាធារណៈ ដូចជា ការកម្រិតអំពីទំហំបំណុលសាធារណៈ ការកំណត់ពិដាននៃឱនភាពថវិកា ឬកំហិតជាអតិបរមាលើ

មុខសញ្ញាចំណាយមួយចំនួន។ល។ ក្របខ័ណ្ឌនេះនឹងកំណត់ទំហំចំណូលសរុបនិងចំណាយសរុប សម្រាប់រយៈពេលមធ្យម ដែលជាមូលដ្ឋានកំណត់អំពីពិដានចំណាយតាមវិស័យទាំងបួន រួមមាន វិស័យរដ្ឋបាលទូទៅ វិស័យការពារជាតិ និងសន្តិសុខ វិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច។ ក្របខ័ណ្ឌនេះនឹងត្រូវរៀបចំដោយផ្អែកលើសម្មតិកម្មនៃការព្យាករម៉ាក្រូសេដ្ឋកិច្ចដោយប្រយ័ត្នប្រយែង ជាពិសេស ទាក់ទងនឹងការព្យាករចំណូលនិងចំណាយសាធារណៈ។

លទ្ធផលនៃការអនុវត្តជាក់ស្តែងផ្នែកហិរញ្ញវត្ថុសាធារណៈ អាចខុសគ្នាច្រើនពីការគ្រោងទុក ដោយសារមានកត្តាប្រែប្រួលមិនអាចប៉ាន់ស្មានបាននៃកំណើនសេដ្ឋកិច្ច ការផ្លាស់ប្តូរលក្ខខណ្ឌពាណិជ្ជកម្ម បច្ច័យជាក់ស្តែងនៃការធានារបស់រាជរដ្ឋាភិបាល និងគ្រោះមហន្តរាយធម្មជាតិជាដើម។ ក្នុងន័យនេះ ព័ត៌មានអំពីហានិភ័យហិរញ្ញវត្ថុអាចជួយដល់ការគ្រប់គ្រងហានិភ័យ កែលម្អប្រសិទ្ធភាពសេដ្ឋកិច្ច និងកាត់បន្ថយថ្លៃដើមនៃប្រាក់កម្ចី។ ការផ្តល់ព័ត៌មានអំពីហានិភ័យហិរញ្ញវត្ថុច្បាស់លាស់និងគ្រប់ជ្រុងជ្រោយដល់អ្នកដែលត្រូវសម្រេច នឹងជួយឱ្យមានការពិនិត្យពិនិស្ស័យបានហ្មត់ចត់ ហើយសម្រេចបានត្រឹមត្រូវ ប្រកបដោយគុណភាព ជាពិសេស ការសម្រេចអំពីកម្រិតនៃហានិភ័យដែលរាជរដ្ឋាភិបាលគួរទទួលយក។ លើសពីនេះ តម្លាភាពនៃការងារនេះនឹងជួយជំរុញ ការឆ្លើយតបខាងគោលនយោបាយឱ្យបានទាន់ពេលវេលា រលូន និងមានប្រសិទ្ធភាព។

ឯកសារស្តីពីហានិភ័យហិរញ្ញវត្ថុនឹងត្រូវភ្ជាប់ជាមួយនឹងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។ ឯកសារស្តីពីហានិភ័យហិរញ្ញវត្ថុនេះ មានគោលដៅបង្ហាញពីលទ្ធភាពនៃការប្រែប្រួលទៅលើលទ្ធផលចុងក្រោយនៃថវិកាដែលបណ្តាលមកពីការផ្លាស់ប្តូរលក្ខខណ្ឌ និងសម្មតិកម្មម៉ាក្រូសេដ្ឋកិច្ច។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការវាយតម្លៃ និងធ្វើរបាយការណ៍ហានិភ័យហិរញ្ញវត្ថុ។ ចំណែកក្រសួង ស្ថាប័នផ្សេងទៀត រួមទាំងធនាគារជាតិនៃកម្ពុជានិងក្រសួង ស្ថាប័ន ដែលមានសហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មានតួនាទីក្នុងការកំណត់មុខសញ្ញាហានិភ័យនិងការគ្រប់គ្រងហានិភ័យទាំងនោះផងដែរ។ យន្តការសម្របសម្រួលមួយនឹងត្រូវបានបង្កើតឡើងដើម្បីផ្លាស់ប្តូរព័ត៌មាន តាមដាន និងត្រួតពិនិត្យពាក់ព័ន្ធនឹងហានិភ័យហិរញ្ញវត្ថុ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។

ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងការវាយតម្លៃហានិភ័យហិរញ្ញវត្ថុនឹងដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេច មុនពេលរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាប្រចាំឆ្នាំ។

### ៣.១.៣. ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF)

ក្របខ័ណ្ឌថវិការយៈពេលមធ្យមគឺជាឧបករណ៍សំខាន់ក្នុងការវិភាជថវិកាទៅតាមវិស័យនិងតាមក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ស្របទៅតាមអាទិភាពគោលនយោបាយនិងគោលដៅអភិវឌ្ឍន៍ជាតិ។ ក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងត្រូវរៀបចំទៅតាមវិស័យទាំងបួន រួមមាន វិស័យរដ្ឋបាលទូទៅ វិស័យការពារជាតិនិងសន្តិសុខ វិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច និងលម្អិតទៅតាមក្រសួង ស្ថាប័ន ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។ ការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមក៏ត្រូវពិចារណាផងដែរទៅដល់តម្រូវការចំណាយសម្រាប់កម្មវិធីដែលត្រូវបន្ត និងការប៉ាន់ស្មានតម្រូវការចំណាយសម្រាប់កម្មវិធីឬគោលនយោបាយថ្មី។ បន្ថែមលើ

ការវិភាជចំណាយតាមវិស័យនិងតាមក្រសួង ស្ថាប័ន ក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងធ្វើអាទិភាពនិងវិភាជចំណាយ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចបំប្រួញ ដូចជា បន្ទុកបុគ្គលិក មិនមែនបន្ទុកបុគ្គលិក ចំណាយមូលធន ការវិនិយោគផ្នែកហិរញ្ញវត្ថុ ការធានាបំណុល ជាដើម។ ប្រការនេះ នឹងជួយធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលផង និងជួយគ្រប់គ្រងពិដានតាមប្រភេទចំណាយនីមួយៗ។ ការប៉ាន់ស្មានថវិកានៅក្នុងក្របខ័ណ្ឌនៃ MTBF នេះ នឹងក្លាយជាអញ្ញត្តិគោលមួយមានមូលដ្ឋានជាក់ស្តែង សម្រាប់ក្រសួង ស្ថាប័ន រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងត្រូវរៀបចំ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងសំណើចំណាយថ្មីៗ និងការកែសម្រួលអាទិភាពចំណាយ ក្រោមមគ្គុទ្ទេសក៍ និងការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**៣.១.៤ ផែនការយុទ្ធសាស្ត្រថវិកា**

ផែនការយុទ្ធសាស្ត្រថវិកា គឺជាផែនការបីឆ្នាំរំកិល តាមអភិក្រមពីក្រោមឡើងលើ ដែលក្រសួង ស្ថាប័ន ត្រូវរៀបចំជារៀងរាល់ឆ្នាំ ដោយផ្សារភ្ជាប់អាទិភាពគោលនយោបាយរបស់ក្រសួង ស្ថាប័ន ទៅនឹងគោលដៅតាមវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (សូមមើលបន្ថែមឧបសម្ព័ន្ធ ២.៣ ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ)។ ផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវរៀបចំទៅតាមគោលបំណងគោលនយោបាយនិងកម្មវិធី ដោយមានសេចក្តីពន្យល់ខ្លឹមសារពិពណ៌នាអំពីគោលបំណងនិងសនិទាន ប្រភេទហិរញ្ញប្បទាន សូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល គោលដៅសមិទ្ធកម្ម ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ ផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវផ្អែកលើពិដានចំណាយ ដែលមាននៅក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម។

ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាក៏ត្រូវពិចារណាផងដែរ ទៅដល់តម្រូវការចំណាយសម្រាប់កម្មវិធីដែលមានចរិតជាប្រចាំ (បន្ទុកបុគ្គលិក ចំណាយដំណើរការការិយាល័យ ការថែទាំអគារ និងសេវាកម្មផ្សេងៗទៀត) ការរៀបចំគោលនយោបាយ និងសកម្មភាពផ្សេងទៀតដែលមិនពាក់ព័ន្ធផ្ទាល់ទៅនឹងលទ្ធផលចុងក្រោយ ក្រសួង ស្ថាប័នអាចរៀបចំកម្មវិធីជាផ្នែកនៃផែនការយុទ្ធសាស្ត្រថវិកាបាន ប៉ុន្តែជាកម្មវត្ថុនៃការសម្រេចជាមុនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីប្រភេទនោះនឹងផ្តោតការយកចិត្តទុកដាក់ទៅលើធាតុចូល លទ្ធផលក្នុងឆ្នាំ និងការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ ដោយមិនផ្តោតទៅលើសមិទ្ធកម្មគោលនយោបាយ និងសក្តិសិទ្ធភាពនៃកម្មវិធីនោះទេ។

ផែនការយុទ្ធសាស្ត្រថវិកាត្រូវមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈការពង្រីកវិសាលភាពឱ្យគ្របដណ្តប់គ្រប់ប្រភពចំណូលទាំងអស់ (ថវិការដ្ឋ ថវិកាដៃគូ ចំណូលផ្ទាល់អង្គភាព ...)និងគ្រប់មុខសញ្ញាចំណាយទាំងអស់ (ចំណាយចរន្ត ចំណាយមូលធន ហិរញ្ញប្បទានឥតសំណង ឧបត្ថម្ភធន ការផ្ទេរធនធាន ...)។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍សំខាន់សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាមូលធន។

បច្ចុប្បន្ន ការរៀបចំផែនការវិនិយោគរយៈពេលមធ្យម ដោយហិរញ្ញប្បទានដោយការខ្ចី ដែលមួយចំណែកធំជាថវិកាមូលធនហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ត្រូវបានធ្វើដោយឡែកៗតាមដៃគូ នៅក្រោមសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការទាំងនោះត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងបញ្ជីគម្រោងវិនិយោគសាធារណៈ

បីឆ្នាំរំកិលដែលរៀបចំដោយក្រសួងផែនការ រួមជាមួយនឹងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍនានា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកលើបញ្ជីគម្រោងវិនិយោគសាធារណៈបីឆ្នាំរំកិល សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំថវិកាប្រចាំឆ្នាំ ផ្នែកចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស។ ដោយឡែក ថវិកាមូលធនដោយហិរញ្ញប្បទានក្នុងប្រទេសពុំទាន់មានផែនការរយៈពេលមធ្យមនៅឡើយទេ ដែលបច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកវិភាជជូនក្រសួង ស្ថាប័ន ក្នុងក្របខ័ណ្ឌនៃថវិកាប្រចាំឆ្នាំ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។

បញ្ហាប្រឈមនៃការធ្វើសមាហរណកម្មថវិកាទាំងពីរប្រភេទឱ្យបានពេញលេញគឺ៖

- ផែនការថវិការយៈពេលមធ្យមនិងផែនការគម្រោងវិនិយោគសាធារណៈ មានក្របខ័ណ្ឌពេលវេលាពីរខុសគ្នា ដោយគម្រោងវិនិយោគធំៗ នឹងត្រូវទទួលការអនុម័តពិសេស អាស្រ័យដោយគម្រោងវិនិយោគទាំងនោះមានកាតព្វកិច្ចហិរញ្ញវត្ថុរយៈពេលវែង និងហួសពីរយៈពេលស្តង់ដានៃការធ្វើផែនការនីយកម្មថវិកា។
- ដំណើរការរៀបចំផែនការមានពីរខុសគ្នា(ការរៀបចំកម្មវិធីវិនិយោគសាធារណៈនិងការរៀបចំថវិកាចរន្ត) ទទួលបន្ទុកដោយស្ថាប័នពីរផ្សេងគ្នានិងរៀបចំតាមពេលវេលាខុសគ្នា។

គោលបំណងក្នុងផ្នែកនេះ គឺធ្វើការកែលម្អសមាហរណកម្មថវិកា ទាំងចរន្ត ទាំងវិនិយោគ ឱ្យបានល្អប្រសើរឡើងនៅក្នុងដំណាក់កាលនៃការរៀបចំថវិកាប្រចាំឆ្នាំ។ សំណើគម្រោងវិនិយោគត្រូវរៀបចំដោយក្រសួង ស្ថាប័ន និងជាផ្នែកមួយនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងត្រូវធ្វើយុត្តិកម្មដើម្បីសម្រេចគោលបំណងរបស់កម្មវិធីនីមួយៗ។ ក្នុងន័យនេះ ចាំបាច់ត្រូវរៀបចំក្របខ័ណ្ឌនៃការគ្រប់គ្រងចំណាយវិនិយោគ (Public Investment Management Framework-PIM) ច្បាស់លាស់ សម្រាប់ជាមូលដ្ឋាននៃការរៀបចំនិងអនុម័តថវិកាវិនិយោគរយៈពេលមធ្យម។

## ៣.២. ការរៀបចំនិងការអនុម័តថវិកា

### ៣.២.១. ដំណើរការរៀបចំថវិកាប្រចាំឆ្នាំ

បច្ចុប្បន្ន ការគ្រោងថវិកាប្រចាំឆ្នាំ ជាទូទៅ ត្រូវបានរៀបចំឈរលើមូលដ្ឋានកំណើនប្រចាំឆ្នាំ ដើម្បីបន្តផ្តល់សេវាសាធារណៈពីមួយឆ្នាំទៅមួយឆ្នាំទៀត ទោះបីថវិកាកម្មវិធីត្រូវបានអនុវត្តមួយរយៈហើយក៏ដោយ។ ការគ្រោងថវិកាត្រូវបានកែសម្រួលខ្លះៗ ទៅតាមអត្រានៃការដំឡើងប្រាក់បៀវត្ស កំណើនសុទ្ធនៃចំនួនបុគ្គលិក ការអនុវត្តថវិកាក្នុងឆ្នាំ និងការប្រែប្រួលថ្លៃដែលមិនបានរំពឹងទុកជាមុន។ ក្រសួង ស្ថាប័ននីមួយៗអាចស្នើសុំថវិកាបន្ថែមស្របគ្នាទៅតាមផែនការយុទ្ធសាស្ត្រថវិកា និងក្នុងទំហំអត្រាកំណើនដែលបានកំណត់ជាពិដានសម្រាប់ក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័នត្រូវការពារសំណើនេះ ជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំពិភាក្សាគម្រោងថវិកា ដែលបច្ចុប្បន្ន ផ្តោតជាសំខាន់លើធាតុចូលនិងលទ្ធផលក្នុងឆ្នាំមួយចំនួន។

ថវិកាប្រចាំឆ្នាំឆ្លុះបញ្ចាំងអំពីការផ្សារភ្ជាប់រវាងគោលនយោបាយតាមវិស័យ ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ តាមរយៈការផ្សារភ្ជាប់រវាងក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងផែនការយុទ្ធសាស្ត្រថវិកា ហើយដែលគោលនយោបាយតាមវិស័យនិងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំដោយផ្អែកលើគោលនយោបាយជាតិ(យុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍ជាតិ) ដូចមានបង្ហាញនៅក្នុងដ្យាក្រាមទី១។ លើសពីនេះ ដ្យាក្រាមទី២បង្ហាញពីទំនាក់ទំនងរវាងរចនាសម្ព័ន្ធគោលនយោបាយ (គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព) និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន(កម្រិតដឹកនាំ កម្រិតគ្រប់គ្រង និងកម្រិតបច្ចេកទេស) ជាមួយនឹងការកំណត់យ៉ាងច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវ ប្រកបដោយគណនេយ្យភាព និងតម្លាភាព។

*ដ្យាក្រាមទី១ : ការផ្សារភ្ជាប់រវាងអាទិភាពជាតិនិងគោលនយោបាយតាមវិស័យ*




គោលដៅសម្រាប់ឆ្នាំ២០២៥ គឺការពិភាក្សាលើសំណើថវិកា ទាំងថវិកាចរន្ត ទាំងថវិកាមូលធននឹងត្រូវផ្អែកជាសំខាន់លើសមិទ្ធកម្មនៃកម្មវិធី ជាពិសេស លើសំណើថវិកាថ្មី ដែលនឹងរួមចំណែកដល់ការសម្រេចគោលបំណងនៃកម្មវិធី លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ និងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី។ ការពិភាក្សាដេញដោលអំពីគម្រោងថវិកានៅតែផ្អែកលើគោលការណ៍កំណើនប្រចាំឆ្នាំ ប៉ុន្តែដើម្បីបង្កើនភាពបត់បែននៃថវិកាបាន ក្រសួង ស្ថាប័នត្រូវខិតខំសន្សំសំចៃ ដើម្បីធ្វើការវិភាជថវិកាឡើងវិញឱ្យអស់លទ្ធភាពសិន។

*ដ្យាក្រាមទី២ : ទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រង រចនាសម្ព័ន្ធគោលនយោបាយនិងសិទ្ធិអំណាច*




ក្រសួង ស្ថាប័នតម្រូវឱ្យកំណត់ពីមុខសញ្ញាដែលអាចសន្សំបាននិងជាកម្មវត្ថុនៃការធ្វើវិភាជឡើងវិញ។ ដំណើរការនៃការចរចាថវិកាផ្អែកលើធាតុចូលបច្ចុប្បន្ន នឹងផ្លាស់ប្ដូរជាបណ្ដើរៗឆ្ពោះទៅរកការចរចាថវិកាផ្អែកជាសំខាន់លើលទ្ធផលក្នុងឆ្នាំនិងលទ្ធផលចុងក្រោយនៃកម្មវិធី។

ទន្ទឹមនឹងនេះ ការរៀបចំថវិកានឹងប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង ៧ ឱ្យបានពេញលេញ ដោយដាក់បញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ចំណាត់ថ្នាក់ថវិកាទាំងនេះ រួមមានចំណាត់ថ្នាក់សេដ្ឋកិច្ច រដ្ឋបាល មុខងារ ភូមិសាស្ត្រ កម្មវិធី ប្រភពមូលនិធិនិងចំណាត់ថ្នាក់គម្រោង។ ការគ្រប់គ្រងនៅកម្រិតចំណាត់ថ្នាក់សេដ្ឋកិច្ច នឹងប្រព្រឹត្តទៅលើប្រភេទចំណាយមួយចំនួនតែប៉ុណ្ណោះ ដោយអនុញ្ញាតឱ្យមានភាពបត់បែនច្រើននៅក្នុងការប្រើប្រាស់ថវិកាសម្រាប់អនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព។

### ៣.២.២. ការពិនិត្យពិនិស្ច័យនិងការអនុម័តថវិកា

ដំណើរការនៃការអនុម័តថវិកាប្រចាំឆ្នាំ មានលំដាប់លំដោយទៅតាមប្រតិទិននៃការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំ។ ជាទូទៅ គោលការណ៍នេះត្រូវបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន ហើយក្រសួង ស្ថាប័ននីមួយៗមានរយៈពេលជាងប្រាំមួយសប្ដាហ៍ ក្នុងការរៀបចំថវិការបស់ខ្លួន។ ក្រោយពីបានការសម្រេចរួចដោយរាជរដ្ឋាភិបាល សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ (ឬហៅខ្លីថា ច្បាប់ថវិកាប្រចាំឆ្នាំ) ត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីពិនិត្យនិងអនុម័ត។

ក្នុងពេលបច្ចុប្បន្ន ការពិនិត្យពិនិស្ស័យសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំនៅស្ថាប័ននីតិប្បញ្ញត្តិ ត្រូវបានពិភាក្សានៅក្នុងគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២) ដោយមានការចូលរួមពីគណៈកម្មការជំនាញពាក់ព័ន្ធផ្សេងទៀត។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវជំនួសមុខគ្រប់ក្រសួង ស្ថាប័នក្នុងការការពារសេចក្តីព្រាងច្បាប់ថវិកាទាំងនៅក្នុងគណៈកម្មការទី២ និងនៅក្នុងកិច្ចប្រជុំពេញអង្គនៃស្ថាប័ននីតិប្បញ្ញត្តិស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។

នៅឆ្នាំ២០២៥ ការពិនិត្យពិនិស្ស័យច្បាប់ថវិកាប្រចាំឆ្នាំ រួមទាំងច្បាប់កែតម្រូវនិងច្បាប់ទូទាត់ថវិកាដោយស្ថាប័ននីតិប្បញ្ញត្តិ នឹងត្រូវកែសម្រួលនិងពង្រឹងបន្ថែមទៀត។ ការពិភាក្សាដេញដោលអំពីថវិកានៅកម្រិតកម្មវិធីនឹងធ្វើឡើងនៅក្នុងរង្វង់គណៈកម្មការជំនាញពាក់ព័ន្ធនៃស្ថាប័ននីតិប្បញ្ញត្តិ ដែលរៀបចំដោយរដ្ឋសភា និងអាចមានការចូលរួមពីគណៈកម្មការជំនាញពាក់ព័ន្ធនៃព្រឹទ្ធសភា។ ជាគោលការណ៍ ក្រសួង ស្ថាប័ននឹងទទួលខុសត្រូវក្នុងការចូលរួមការពារថវិកាក្នុងកម្រិតកម្មវិធីនៅក្នុងអង្គប្រជុំគណៈកម្មការជំនាញពាក់ព័ន្ធ។ ការពិភាក្សាថវិកាប្រចាំឆ្នាំក្នុងសម័យប្រជុំពេញអង្គនៃស្ថាប័ននីតិប្បញ្ញត្តិ នឹងផ្តោតជាសំខាន់លើគោលបំណងគោលនយោបាយកម្រិតក្រសួង ស្ថាប័ន និងកញ្ចប់ថវិកាទាំងមូល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងទទួលខុសត្រូវក្នុងការការពារកញ្ចប់ថវិកាកម្រិតក្រសួង ស្ថាប័ន នៅក្នុងគណៈកម្មការទី២និងនៅកិច្ចប្រជុំពេញអង្គនៃនីតិប្បញ្ញត្តិ។ កិច្ចប្រជុំនៅគណៈកម្មការទី២ គឺជាកិច្ចប្រជុំសម្រេចលើការរៀបចំថវិកាទាំងមូល មុននឹងសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំត្រូវបានដាក់ចូលក្នុងកិច្ចប្រជុំពេញអង្គនៃស្ថាប័ននីតិប្បញ្ញត្តិ។

ជាបណ្តើរៗ រដ្ឋសភានឹងអនុម័តថវិកាទៅតាមជំពូកនៃអត្ថបទសេចក្តីព្រាងច្បាប់ ដោយមានការបែងចែកថវិកាទៅតាមគោលបំណងគោលនយោបាយ កម្មវិធី និងចំណាត់ថ្នាក់សេដ្ឋកិច្ចបំប្រួញជាឧបសម្ព័ន្ធ។ នៅឆ្នាំ២០២៥ សេចក្តីព្រាងច្បាប់ថវិកានឹងរួមបញ្ចូលព័ត៌មានសមិទ្ធកម្មជាឧបសម្ព័ន្ធ ដែលមានតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មានក្នុងដំណើរការពិនិត្យពិនិស្ស័យ។

## ៣.៣. ការអនុវត្តនិងការត្រួតពិនិត្យថវិកា

### ៣.៣.១. សិទ្ធិអំណាចនៃការបញ្ជាចំណាយ

ក្នុងប្រព័ន្ធបច្ចុប្បន្ន ក្រសួង ស្ថាប័នដែលជាអាណាប័កដើមខ្សែ តម្រូវឱ្យស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាចំណាយ។ ក្រោយពេលប្រកាសដាក់ឱ្យចូលជាធរមាននៃច្បាប់ថវិកាប្រចាំឆ្នាំ និងការដាក់ឱ្យអនុវត្តសៀវភៅថវិកា ក្រសួង ស្ថាប័នអាចស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន។ ចំពោះមុខចំណាយប្រតិបត្តិការប្រក្រតីផ្សេងៗទៀត ត្រូវបានអនុវត្តតាមនីតិវិធីនៃការផ្តល់ធានាចំណាយនិងនីតិវិធីលទ្ធកម្មសាធារណៈ។ នៅពេលក្រសួង ស្ថាប័ន ទទួលបានទំនិញនិងសេវាកម្ម ព្រមទាំងបានផ្ទៀងផ្ទាត់រួចរាល់ ក្រសួង ស្ថាប័នត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដោយមានភ្ជាប់លិខិតយុត្តការគាំទ្រ និងដាក់ឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីត្រូវបានពិនិត្យដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន និងអនុម័តដោយថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅតាមកម្រិតនៃសិទ្ធិសម្រេច អាណត្តិបើកប្រាក់ដែលត្រូវបានចុះទិដ្ឋាការរួចព្រមជាមួយនឹងលិខិតយុត្តការគាំទ្រ ត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីត្រួតពិនិត្យនិង

ទូទាត់ជាក់ស្តែងទៅឱ្យអ្នកផ្គត់ផ្គង់។ ចំពោះថវិកាមន្ទីរជំនាញរាជធានី ខេត្ត មានយន្តការគ្រប់គ្រង និងនីតិវិធីអនុវត្ត ដូចគ្នាទៅនឹងថវិកាក្រសួង ស្ថាប័នដែរ ដោយប្រធានមន្ទីរជំនាញជាអាណាប័កផ្ទេរសិទ្ធិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការត្រួតពិនិត្យផ្តល់ទិដ្ឋាការធានាចំណាយនិងអាណត្តិបើកប្រាក់ ហើយរតនាគាររាជធានី ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈត្រួតពិនិត្យនិងទូទាត់ចំណាយថវិកា។

គោលបំណងនៅឆ្នាំ២០២៥ គឺនៅពេលច្បាប់ថវិកាត្រូវបានអនុម័តរួច ឥណទានថវិកានឹងក្លាយជាមូលដ្ឋាននៃការអនុញ្ញាតឱ្យបញ្ជាចំណាយពេញមួយឆ្នាំសម្រាប់ក្រសួង ស្ថាប័ន។ ការអនុញ្ញាតឱ្យបញ្ជាចំណាយនឹងត្រូវធ្វើឡើងជាកម្មវិធីចំណាយប្រចាំត្រីមាសឬឆមាស ស្របតាមគោលការណ៍កំណត់ លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ មិនមានគោលការណ៍/គោលរបបច្បាស់លាស់និង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីចំណាយប្រចាំត្រីមាសឬឆមាស គឺជាការបែងចែកធនធានទៅតាមកម្មវិធី អង្គភាពថវិកា មុខចំណាយ និងពេលវេលា។ នីតិវិធីនៃការអនុវត្តថវិកានឹងត្រូវបានធ្វើទំនើបកម្មនិងពន្លឿនថែមទៀត តាមរយៈការលើកកម្ពស់ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព។ តាមទិសដៅនេះ ការប្រើប្រាស់ថវិកាបុរេប្រទានដែលមិនទាន់ត្រូវបានកត់ត្រាជាចំណាយថវិកា ដូចការអនុវត្តបច្ចុប្បន្នក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការចំណាយថវិកា នឹងត្រូវកាត់បន្ថយជាអតិបរមា។

**៣.៣.២. ការត្រួតពិនិត្យការអនុវត្តថវិកា**

បច្ចុប្បន្ន ការត្រួតពិនិត្យចំណាយរបស់ក្រសួង ស្ថាប័នត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ក្នុងដំណាក់កាលធានាចំណាយ កិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់។ ទាំងការអនុវត្ត ទាំងការត្រួតពិនិត្យការអនុវត្តថវិកាត្រូវធ្វើឡើងតាមក្រដាសស្នាម មានន័យថាមិនទាន់មានប្រើប្រាស់ប្រព័ន្ធ FMIS នៅឡើយទេ។ ទន្ទឹមនឹងនេះ ការធ្វើនិយ័តកម្មថវិកាក៏នៅមិនទាន់មានភាពទន់ភ្លន់គ្រប់គ្រាន់។

មកដល់ពេលនេះ ការត្រួតពិនិត្យថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបានអនុវត្តដោយផ្អែកលើអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យករសាធារណៈ។ អនុក្រឹត្យទាំងពីរនេះដែលត្រូវបានអនុវត្តជាង២០ឆ្នាំមកហើយ មិនអាចឆ្លើយតបបានគ្រប់ជ្រុងជ្រោយទៅនឹងការវិវត្តនៃប្រព័ន្ធគ្រប់គ្រងថវិកាស្របតាមឧត្តមានុវត្តអន្តរជាតិថ្មីនោះទេ ជាពិសេស ពាក់ព័ន្ធនឹងតួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករសាធារណៈ។ អាស្រ័យហេតុនេះ អនុក្រឹត្យទាំងពីរនឹងត្រូវពិនិត្យឡើងវិញ ដើម្បីធ្វើការកែសម្រួលឬរៀបចំថ្មីជាយថាហេតុ។

គោលបំណងនៅឆ្នាំ២០២៥ គឺធ្វើសាមញ្ញកម្មប្រព័ន្ធត្រួតពិនិត្យថវិកា ដោយធ្វើឱ្យច្បាស់លាស់និងឱ្យខ្លីនូវនីតិវិធីអនុវត្ត និងត្រួតពិនិត្យថវិកា ទាំងនៅក្រសួង ស្ថាប័ន និង នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ ត្រូវដាក់ដំណើរការពេញលេញនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បី

ប្រើប្រាស់ប្រព័ន្ធនេះជាឧបករណ៍សម្រាប់បំពេញមុខងារតាមដាន និងត្រួតពិនិត្យជាស្វ័យប្រវត្តិ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពកិច្ចប្រតិបត្តិការ និងភាពទន់ភ្លន់ក្នុងការគ្រប់គ្រង និងអនុវត្តថវិកា។

ស្របតាមទិសដៅនេះ មុខងារត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកាថ្នាក់ជាតិនឹងត្រូវកែសម្រួល ដោយធ្វើប្រតិភូកម្មអំណាចឱ្យកៀកនឹងកម្រិតអនុវត្តផ្ទាល់ ដើម្បីការអនុវត្តថវិកាបានលឿន ទាន់ពេលវេលា មានប្រសិទ្ធភាពខ្ពស់ និងមានគណនេយ្យភាពច្បាស់លាស់ ស្របតាមទស្សនាទាននៃថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ ចាំបាច់ត្រូវបង្កើតយន្តការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលថ្នាក់ជាតិ ដូចខាងក្រោម

- បង្កើតយន្តការគ្រប់គ្រងការអនុវត្តថវិការដ្ឋបាលកណ្តាល ក្រោមចំណុះផ្ទាល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម ដោយដាក់ឱ្យនៅអមក្រសួង ស្ថាប័ន
- បង្កើតយន្តការគ្រប់គ្រងការអនុវត្តថវិកាមន្ទីរជំនាញរាជធានី ខេត្ត ដោយផ្តល់អំណាច និងការទទួលខុសត្រូវផ្ទាល់ដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម។

ដើម្បីធានាប្រតិតុល្យភាព មុខងារគណនេយ្យករសាធារណៈនឹងត្រូវបន្តអនុវត្តយន្តការដោយឡែកដូចបច្ចុប្បន្ន ក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ ប៉ុន្តែត្រូវកាត់បន្ថយការត្រួតពិនិត្យឱ្យមកនៅត្រឹមកម្រិតអប្បបរមា តាមរយៈការរៀបចំគតិយុត្តឱ្យច្បាស់លាស់ និងមានប្រសិទ្ធភាព ព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធ FMIS និង E-Transfer ។ នៅពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិកាកាន់តែត្រូវបានកែលម្អស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងសមត្ថភាពស្ថាប័នពាក់ព័ន្ធកាន់តែខ្ពស់ គណនេយ្យករសាធារណៈអាចនឹងត្រូវបញ្ជូនទៅបំពេញមុខងារនៅអមក្រសួង ស្ថាប័ន ដើម្បីឱ្យយន្តការត្រួតពិនិត្យកាន់តែស្រាលនិងមានប្រសិទ្ធភាព ដែលជាបុរេលក្ខខណ្ឌសម្រាប់ឱ្យក្រសួង ស្ថាប័នកាន់តែមានគណនេយ្យភាពពេញលេញ ទាំងផ្នែកហិរញ្ញវត្ថុ និងទាំងផ្នែកសមិទ្ធកម្ម។

ទន្ទឹមនឹងមុខងារត្រួតពិនិត្យផ្នែកចំណាយ យន្តការគ្រប់គ្រងការអនុវត្តថវិកាខាងលើក៏ត្រូវបំពេញមុខងារតាមដាន និងត្រួតពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

### ៣.៣.៣ កិច្ចលទ្ធកម្ម

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវបានអនុម័តនៅខែមករា ឆ្នាំ២០១២ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរៀបចំបញ្ចប់នូវបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗដើម្បីអនុវត្តច្បាប់នេះឱ្យបានពេញលេញ។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្របខ័ណ្ឌគតិយុត្តនេះមិនទាន់មានការបែងចែកអំណាចឱ្យដាច់ស្រឡះរវាងនិយ័តករ និងស្ថាប័នអនុវត្តកិច្ចលទ្ធកម្មនៅឡើយ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺពង្រឹងយន្តការគណនេយ្យភាព តាមរយៈក្របខ័ណ្ឌនិយ័តកម្ម ដែលក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីជានិយ័តករនិងសវនកម្មកិច្ចលទ្ធកម្ម ចំណែកស្ថាប័នអនុវត្តលទ្ធកម្មត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះកិច្ចលទ្ធកម្ម។ យន្តការទទួលពាក្យបណ្តឹងនិងដោះស្រាយពាក្យបណ្តឹងនឹងត្រូវកែលម្អ និងធ្វើឱ្យមានឯករាជ្យភាព ជាមួយនឹងការបង្កើតឱ្យមានរបបទោសទណ្ឌ។ វិធាន បទប្បញ្ញត្តិនិងនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈនឹងត្រូវធ្វើសុខដុមនីយកម្ម ដើម្បីបង្កើនការប្រកួតប្រជែងប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

### ៣.៣.៤ ការត្រួតពិនិត្យការបើកផ្តល់

បច្ចុប្បន្ន ស្របតាមអនុក្រឹត្យ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យករសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងបំពេញតួនាទីជាគណនេយ្យករសាធារណៈ ព្រមទាំងទទួលខុសត្រូវក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់អនុលោមភាពនៃនីតិវិធីហិរញ្ញវត្ថុមុនពេលបើកផ្តល់សាច់ប្រាក់ទៅតាមអាណត្តិបើកប្រាក់។

គោលបំណងនៅឆ្នាំ២០២៥ គឺឈានទៅធ្វើសាមញ្ញកម្មក្របខ័ណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យការបើកផ្តល់តាមរយៈប្រព័ន្ធ FMIS ចំណែកការទូទាត់សាច់ប្រាក់នឹងធ្វើតាមរយៈការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិច (E-Transfer)។ តួនាទីនិងមុខងារនៃគណនេយ្យករសាធារណៈ នឹងត្រូវពិនិត្យឡើងវិញក្នុងពេលកែសម្រួលឬរៀបចំថ្មីបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងគណនេយ្យករសាធារណៈ ដូចបានគូសបញ្ជាក់ក្នុងចំណុច ៣.៣.២. ខាងលើ។

### ៣.៣.៥ អធិការកិច្ចហិរញ្ញវត្ថុ

ជាទិសដៅនៃថវិកាសមិទ្ធកម្ម ការគ្រប់គ្រងថវិកានឹងត្រូវផ្លាស់ប្តូរពីប្រព័ន្ធមជ្ឈការដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រួតពិនិត្យមុនចំណាយក្នុងកម្រិតខ្ពស់ ទៅប្រព័ន្ធវិមជ្ឈការដែលក្រសួង ស្ថាប័ន និងអង្គភាពថវិកាមានសិទ្ធិស្វ័យសម្រេចខ្ពស់ក្នុងការអនុវត្តថវិកា។ ដើម្បីធានាប្រតិតុល្យការ ការត្រួតពិនិត្យក្រោយចំណាយកាន់តែមានភាពចាំបាច់។ក្នុងន័យនេះ មុខងារអធិការកិច្ចហិរញ្ញវត្ថុនៃអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាស្ថាប័នមានសិទ្ធិអំណាចនីត្យានុកូលស្រាប់ក្នុងការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល នឹងត្រូវពង្រឹងនិងលើកកម្ពស់។ ទោះយ៉ាងនេះក្តី ដើម្បីធានាប្រសិទ្ធភាព និងភាពសន្សំសំចៃខ្ពស់ការងារអធិការកិច្ចហិរញ្ញវត្ថុនឹងត្រូវអនុវត្តដោយឈរលើមូលដ្ឋាននៃភាពចាំបាច់ជាក់ស្តែង ការរាយការណ៍ដោយគណនេយ្យករសាធារណៈ និងការប្តឹងផ្តល់ឬព័ត៌មាននៃភាពមិនប្រក្រតីជាយថាហេតុ។

## ៣.៤. ការតាមដាននិងវាយតម្លៃថវិកា

### ៣.៤.១. ប្រព័ន្ធរបាយការណ៍

### ៣.៤.១.១. របាយការណ៍ហិរញ្ញវត្ថុ

បច្ចុប្បន្ន ប្រទេសកម្ពុជាប្រើប្រាស់ប្រព័ន្ធគណនេយ្យផ្អែកលើមូលដ្ឋាន «សាច់ប្រាក់កែសម្រួល» សម្រាប់កិច្ចបញ្ជិកាគណនេយ្យ និងការរៀបចំរបាយការណ៍។ ទោះបីជាយ៉ាងនេះក្តី គណនេយ្យប្រចាំឆ្នាំមិនទាន់អនុវត្តតាមទម្រង់នៃស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ(IPSAS)នៅឡើយ ដែលក្នុងនោះតម្រូវឱ្យមានរបាយការណ៍វិហ្វរសាច់ប្រាក់ របាយការណ៍ទូទាត់(ដោយរួមមានសមតុល្យសាច់ប្រាក់ដើមគ្រានិងចុងគ្រា) របាយការណ៍បូកសរុបនៃអង្គភាពថវិកាទាំងអស់នៅក្រោមរដ្ឋបាលថ្នាក់ជាតិ ទៅតាមនិយមន័យនៃស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល(GFS) របាយការណ៍អំពីគោលនយោបាយគណនេយ្យ និងកំណត់ពន្យល់គណនេយ្យជាច្រើនទៀត។

គោលបំណងសម្រាប់ឆ្នាំ២០២៥ នឹងបំពេញឱ្យបានតាមទម្រង់របាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់កែសម្រួលស្របតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ(Modified Cash-IPSAS) សម្រាប់ក្រសួងស្ថាប័ននីមួយៗ។ ដោយឡែក គណនេយ្យទូទៅរបស់រដ្ឋនឹងអនុវត្តតាមមូលដ្ឋានសាច់ប្រាក់កែសម្រួល(Modified

Cash Basis)។ ដោយសារមានប្រព័ន្ធ FMIS ការតាមដានការអនុវត្តផ្នែកហិរញ្ញវត្ថុនឹងអាចផលិតជារបាយការណ៍បច្ចុប្បន្នហេតុទៅតាមសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់។ ប្រព័ន្ធ FMIS អាចផលិតជារបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ ទៅតាមគ្រប់ចំណាត់ថ្នាក់ និងតាមសេចក្តីត្រូវការ។ ការតាមដាន ការអនុវត្តហិរញ្ញវត្ថុនឹងត្រូវកែលម្អ និងបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសាធារណៈ។

**៣.៤.១.២ របាយការណ៍សមិទ្ធកម្ម**

ក្នុងការអនុវត្តថវិកាកម្មវិធី ក្រសួង ស្ថាប័នត្រូវផ្តល់របាយការណ៍សមិទ្ធកម្មតាមកម្មវិធីប្រចាំឆមាសនិងប្រចាំឆ្នាំ ដោយផ្អែកលើទម្រង់នៃរបាយការណ៍ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បច្ចុប្បន្ន អនុលោមភាពនៅមានកម្រិតទាប។ ដូចនេះ ការពង្រឹងប្រព័ន្ធរបាយការណ៍សមិទ្ធកម្មនិងការបង្កើនកម្រិតអនុលោមភាពគឺជាការចាំបាច់ ព្រោះកិច្ចការនេះជាបុរេលក្ខខណ្ឌសម្រាប់ការបង្កើតឱ្យមាននូវប្រព័ន្ធតាមដាន និងវាយតម្លៃ(M&E) ដែលដំណើរការល្អ។

គោលដៅសម្រាប់ឆ្នាំ២០២៥គឺកែលម្អរបាយការណ៍សមិទ្ធកម្មនៅគ្រប់កម្មវិធីនិងកម្រិតអនុកម្មវិធី នៅក្រោមប្រព័ន្ធតាមដាន និងវាយតម្លៃមួយដែលដំណើរការល្អ។

**៣.៤.២ ការតាមដាននិងការវាយតម្លៃ**

ប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើសមិទ្ធកម្មល្អ តម្រូវឱ្យមានការតាមដាន និងវាយតម្លៃជាទៀងទាត់។ ប្រព័ន្ធនេះផ្តល់ជាយន្តការទទួលព័ត៌មានត្រឡប់ សម្រាប់ធ្វើការសម្រេចចិត្តនៅគ្រប់កម្រិត និងស្វែងយល់អំពីវឌ្ឍនភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃកម្មវិធីនីមួយៗ ហើយសំខាន់ជាងនេះ គឺការដាក់វិធានការកែតម្រូវទាន់ពេលវេលានៅពេលដែលកម្មវិធីមិនមានវឌ្ឍភាពល្អឬមានវឌ្ឍនភាពលឿនជ្រុលទៅមុខ។ មូលហេតុនៃវឌ្ឍនភាពទាបពេក (ឬខ្ពស់ជ្រុល) ដោយសារការរៀបចំកម្មវិធីមិនបានល្អ គោលដៅមិនត្រឹមត្រូវ/មិនសមស្រប ការគ្រប់គ្រងកម្មវិធីមិនបានល្អ និងធនធានមិនមានគ្រប់គ្រាន់។

ប្រការនីមួយៗខាងលើ ទាមទារនូវការឆ្លើយតបខុសៗគ្នាពីអ្នកគ្រប់គ្រងដែលអាចពាក់ព័ន្ធឬមិនពាក់ព័ន្ធនឹងថវិកា។ បច្ចុប្បន្ន ប្រព័ន្ធតាមដានរបស់ក្រសួង ស្ថាប័ន និងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ។ សម្រាប់ការវាយតម្លៃវិញ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មសមិទ្ធកម្ម ប៉ុន្តែនៅមានកម្រិត ហើយផ្តោតលើការធ្វើសវនកម្មហិរញ្ញវត្ថុជាចម្បង។ ទន្ទឹមនឹងនេះ នីតិវិធីជាប្រព័ន្ធសម្រាប់វាយតម្លៃកម្មវិធីក៏មិនទាន់មាននៅឡើយដែរ។

ចំពោះសវនកម្មផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័នវិញ នាពេលបច្ចុប្បន្ននេះ កំពុងបំពេញតួនាទីសវនកម្មសមិទ្ធកម្មតិចតួច។ តួនាទីរបស់សវនកម្មផ្ទៃក្នុងត្រូវពង្រឹងនិងតម្រង់ទិសឆ្ពោះទៅរកការវាយតម្លៃសមិទ្ធកម្មរបស់អង្គភាពថវិកា និងការផ្តល់សេវា។ គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺការតាមដាននិងវាយតម្លៃកម្មវិធីនឹងធ្វើឡើងជាប្រព័ន្ធស្របទៅតាមឧត្តមានុវត្តជាអន្តរជាតិ។ ប្រការនេះទាមទារឱ្យមានការរៀបចំលិខិតបទដ្ឋាននិងគោលការណ៍ណែនាំពាក់ព័ន្ធនានា បង្កើនការយល់ដឹង និងការកសាងសមត្ថភាពផ្នែកសវនកម្មសមិទ្ធកម្ម។

ជាគោលការណ៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមដានជាទៀងទាត់ នៅពាក់កណ្តាលឆ្នាំនិងប្រចាំឆ្នាំនៃការអនុវត្តថវិកាកម្មវិធី ដើម្បីពិនិត្យអំពីវឌ្ឍនភាពនៃការសម្រេចបាននូវគោលបំណងនិងលទ្ធផលដែលបានគ្រោងទុក។ ក្រសួង ស្ថាប័ននីមួយៗនឹងត្រូវតាមដានជាប្រចាំការអនុវត្តកម្មវិធីរបស់ខ្លួនផងដែរ ដើម្បីពិនិត្យមើលការសម្រេចបាននូវគោលបំណង និងលទ្ធផលដែលបានគ្រោងទុក។ ការតាមដានដែលធ្វើឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន នឹងក្លាយជាមូលដ្ឋានឈានទៅកែសម្រួលកម្មវិធី។ ក្រសួង ស្ថាប័ន អាចធ្វើការវាយតម្លៃស៊ីជម្រៅតាមការចាំបាច់ ដើម្បីពិនិត្យអំពីប្រសិទ្ធភាពនៃកម្មវិធីនីមួយៗ។

កម្មវិធីទាំងអស់គួរតែជាកម្មវត្ថុនៃការតាមដានជាទៀងទាត់ ប៉ុន្តែការវាយតម្លៃកម្មវិធីនឹងធ្វើឡើងតែលើកម្មវិធីមួយចំនួន និងតាមតម្រូវការជាក់ស្តែង។ ការវាយតម្លៃកម្មវិធីត្រូវការជំនាញពាក់ព័ន្ធច្រើន ទាំងផ្នែកហិរញ្ញវត្ថុ ទាំងផ្នែកជំនាញបច្ចេកទេសច្បាស់លាស់នៅក្នុងវិស័យនោះ។ ដោយសារការងារនេះត្រូវចំណាយច្រើន ការវាយតម្លៃគ្រប់ជ្រុងជ្រោយគួរតែផ្តោតលើកម្មវិធីណាដែលមានទំហំថវិកាធំ ហានិភ័យខ្ពស់ ឬមានសារៈសំខាន់ខ្ពស់ផ្នែកនយោបាយ ឬមានបញ្ហាផ្នែកសមិទ្ធកម្ម។ បច្ចុប្បន្ននេះ ការវាយតម្លៃកម្មវិធីបែបលក្ខណៈទូលាយ ត្រូវបានធ្វើឡើងម្តងម្កាល (ad hoc) ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ។

នៅត្រឹមឆ្នាំ២០២៥ នឹងមានក្របខ័ណ្ឌតាមដាននិងវាយតម្លៃកម្មវិធីដែលគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់ ដោយរួមមានសមាសធាតុសំខាន់ៗដូចខាងក្រោម៖

- ការពិនិត្យតាមដានការអនុវត្តពាក់កណ្តាលឆ្នាំនិងប្រចាំឆ្នាំ
- ការតាមដានស៊ីជម្រៅអំពីប្រសិទ្ធភាពនៃការរៀបចំនិងការអនុវត្តកម្មវិធី
- ការវាយតម្លៃកម្មវិធីដោយគ្រប់ជ្រុងជ្រោយតាមការចាំបាច់និងការវាយតម្លៃក្រោយការអនុវត្តតាមការជ្រើសរើស។

ក្រសួង ស្ថាប័ននីមួយៗត្រូវតាមដានជាប្រចាំនិងអាចត្រួតពិនិត្យឡើងវិញស៊ីជម្រៅជាយថាហេតុ ដើម្បីអាចចាត់វិធានការកែតម្រូវទាន់ពេលនិងមានប្រសិទ្ធភាព ចំពោះកម្មវិធីណាដែលអនុវត្តចាកខុសផ្លូវ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមដានការអនុវត្តកម្មវិធីនិងអាចពិនិត្យឡើងវិញជាលក្ខណៈសាមញ្ញនូវសមិទ្ធកម្មកម្មវិធី ដោយផ្អែកលើទិន្នន័យអនុវត្តថវិកានិងសមិទ្ធកម្ម ដើម្បីប្រើប្រាស់ជាការផ្តល់ព័ត៌មាន សម្រាប់ជួយដល់ការវិភាជថវិកា ប៉ុន្តែមិនមែនកត្តាកំណត់ក្នុងការវិភាជនោះទេ។ កម្មវិធីមួយចំនួននឹងជាកម្មវត្ថុនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ តាមការចាំបាច់ ដើម្បីស្វែងយល់និងរកមូលហេតុនៃភាពឃ្លាតពីគ្នារវាងគម្រោងថវិកានិងលទ្ធផលទទួលបាន ដោយធ្វើការពិនិត្យមើលទាំងការវាស់វែងចំណាយនិងការវាស់វែងសមិទ្ធកម្ម។ ការវាយតម្លៃក្រោយការអនុវត្តកម្មវិធី ដើម្បីប្រមូលផ្តុំបទពិសោធនិងមេរៀននឹងត្រូវធ្វើតែលើកម្មវិធីមួយចំនួនតាមការជ្រើសរើស។

អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើការពិនិត្យឡើងវិញដោយឯករាជ្យលើសមិទ្ធកម្មនៃកម្មវិធី ទៅតាមអាណត្តិការងាររបស់ខ្លួន។ ការងារទាំងនេះរួមមាន ការពិនិត្យសុពលភាពចំណាយ ប្រសិទ្ធភាពនៃកម្មវិធី ការធ្វើសវនកម្មទៅលើសូចនាករសមិទ្ធកម្មមិនមែនហិរញ្ញវត្ថុ ក៏ដូចជា ពិនិត្យឡើងវិញនូវការរៀបចំនិងការគ្រប់គ្រងកម្មវិធី (សូមមើលបន្ថែមនៅក្នុងឧបសម្ព័ន្ធ២.៤ ស្តីអំពីសវនកម្មឯករាជ្យក្នុងប្រព័ន្ធថវិកាសមិទ្ធកម្ម)។

ទោះយ៉ាងណាក៏ដោយ តាមទិសដៅខាងលើ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអាជ្ញាធរសវនកម្មជាតិ) ត្រូវខិតខំធ្វើឱ្យការងារតាមដាននិងវាយតម្លៃខាងលើ ប្រព្រឹត្តទៅដោយមានសង្គតិភាព និងស៊ីចង្វាក់គ្នាជាប្រព័ន្ធដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងចៀសវាងបាននូវការងារជាន់គ្នា។

**៣.៤.៣ ការពិនិត្យចំណាយសាធារណៈឡើងវិញក្នុងក្របខ័ណ្ឌវិស័យឬអនុវិស័យ**

ការពិនិត្យចំណាយសាធារណៈឡើងវិញអាចនឹងត្រូវធ្វើក្នុងក្របខ័ណ្ឌវិស័យអនុវិស័យ ឬក្រសួង ស្ថាប័ន ក្នុងគោលបំណងតម្រែតម្រង់ចំណាយទៅនឹងអាទិភាពគោលនយោបាយ និងកំណត់មុខសញ្ញាដែលអាចសន្សំសំចៃថវិកា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចធ្វើការជ្រើសរើសយកគោលដៅនិងពេលវេលា តាមការចាំបាច់ ដែលជាទូទៅក្នុងរង្វង់៥ឆ្នាំម្តង។

**៣.៥. ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់**

**៣.៥.១. ក្របខ័ណ្ឌគតិយុត្តនៃថវិកា**

បច្ចុប្បន្ន កម្ពុជាកំពុងអនុវត្តប្រព័ន្ធគ្រប់គ្រងថវិកាដែលផ្អែកលើធាតុចូលនិងមជ្ឈការ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ប៉ុន្តែច្បាប់នេះបានបើកច្រកឱ្យរាជរដ្ឋាភិបាលអាចអនុវត្តសាកល្បងថវិកាកម្មវិធី ដែលជាជំហានមួយនៅលើទិសដៅឆ្ពោះទៅរកប្រព័ន្ធថវិកាសមិទ្ធកម្មនិងវិមជ្ឈការ ដែលមានសមាសធាតុកែទម្រង់គន្លឹះ ដូចបានរៀបរាប់នៅក្នុងផ្នែកខាងដើមនៃជំពូកនេះ។ ក្នុងន័យនេះ ដើម្បីឱ្យប្រព័ន្ធថវិកាសមិទ្ធកម្មត្រូវបានដាក់ឱ្យអនុវត្តដោយផ្អែកលើបទដ្ឋានគតិយុត្តច្បាស់លាស់ ពេញលេញ និងគ្រប់ជ្រុងជ្រោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ននេះចាំបាច់ត្រូវធ្វើវិសោធនកម្ម។

**៣.៥.២ ជំនាញនិងសមត្ថភាពក្នុងការគ្រប់គ្រងថវិកា**

ការធ្វើទំនើបកម្មនិងការពង្រឹងប្រព័ន្ធថវិកាតម្រូវឱ្យមានការវិនិយោគច្រើន ដើម្បីលើកកម្ពស់ជំនាញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្នែកសំខាន់ៗដែលទាមទារឱ្យលើកកម្ពស់ជំនាញមានដូចខាងក្រោម៖

- ការវិភាគថវិកា
- គណនេយ្យបង្គរនិងរបាយការណ៍ហិរញ្ញវត្ថុ
- បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ
- កិច្ចលទ្ធកម្ម
- ការគ្រប់គ្រងគម្រោង
- ការតាមដាននិងវាយតម្លៃ

ការកសាងសមត្ថភាពធនធានមនុស្ស គឺជាដំណើរការរយៈពេលវែងនិងបន្តឥតឈប់។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវរៀបចំឱ្យបានពីដំណាក់កាលដំបូងនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធនេះដើម្បីលើកកម្ពស់និងថែរក្សាជំនាញសំខាន់ៗ ខាងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរដ្ឋបាលសាធារណៈ។ ធាតុសំខាន់ៗនៃផែនការយុទ្ធសាស្ត្រនេះរួមមាន ការកំណត់/ការរៀបចំសមត្ថភាពគន្លឹះៗ ការរៀបចំឱ្យមាននីតិវិធី

និងយន្តការជ្រើសរើសបុគ្គលិកឱ្យមានប្រសិទ្ធភាព ការផ្តល់ការបណ្តុះបណ្តាលមានលក្ខណៈជាប្រព័ន្ធនិងការគាំទ្រដល់ការអភិវឌ្ឍអាជីព។

### ៣.៥.៣ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ត្រូវបានរៀបចំជាសមាសធាតុសំខាន់នៃដំណាក់កាលទីពីរនៃ PFMRP ដើម្បីគាំទ្រដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសសម្រាប់ការគ្រប់គ្រងថវិកា។ ប្រព័ន្ធ FMIS គឺជាប្រព័ន្ធសមាហរណកម្មមួយ ដែលគ្របដណ្តប់ការរៀបចំគម្រោងថវិកា ការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យ ការធ្វើរបាយការណ៍ ការតាមដាន និងសវនកម្ម។ ប្រព័ន្ធនេះនឹងជំរុញឱ្យមានការផ្លាស់ប្តូរនីតិវិធីការងារ។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធ FMIS នេះ ប្រព័ន្ធមាតិកាថវិកាបច្ចុប្បន្ន ត្រូវបានធ្វើចំណាត់ថ្នាក់ចំណាយទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចភូមិសាស្ត្រ កម្មវិធី រដ្ឋបាល មុខងារ គម្រោង និងប្រភពធនធាន។ ចំណាត់ថ្នាក់ទាំងអស់នេះមានសង្គតិភាពទៅនឹងស្តង់ដាអន្តរជាតិនៃចំណាត់ថ្នាក់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)។

ផលប្រយោជន៍ភ្លាមៗដែលទទួលបានពីការប្រើប្រាស់ប្រព័ន្ធ FMIS គឺការកែលម្អការរៀបចំនិងអនុវត្តថវិកាតាមរយៈការពន្លឿន និងធ្វើស្វ័យប្រវត្តិកម្មការទូទាត់ ការកត់ត្រាគណនេយ្យ និងការរៀបចំរបាយការណ៍ថវិកាជាតិ។ យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍប្រព័ន្ធ FMIS បានរៀបចំជាពីរជំហាន ដែលក្នុងជំហានទីមួយបានផ្តោតលើការអនុវត្តមុខងារសំខាន់ៗនៃការអនុវត្តថវិកា នៅក្នុងក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជំហានទី២នឹងដាក់បញ្ចូលការធ្វើផែនការថវិកានិងការរៀបចំគម្រោងថវិកា កិច្ចលទ្ធកម្ម ទ្រព្យអចលនកម្ម និងសន្និធិ ព្រមជាមួយនឹងការពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS នេះទៅដល់ក្រសួងស្ថាប័ននានា រួមទាំងរដ្ឋបាលរាជធានី ខេត្តផងដែរ។

គោលដៅសម្រាប់ឆ្នាំ២០២៥ ប្រព័ន្ធ FMIS នឹងធ្វើស្វ័យប្រវត្តិកម្មការរៀបចំថវិកា ការជួយសម្រួលដល់ការផ្ទេរឥណទានថវិកាទៅដល់អង្គភាពថវិកា ហើយបន្តិចម្តងៗនឹងក្លាយជាឧបករណ៍សំខាន់ សម្រាប់ការគ្រប់គ្រងនិងត្រួតពិនិត្យចំណាយរបស់ក្រសួង ស្ថាប័ន រួមទាំងរដ្ឋបាលរាជធានី ខេត្តផងដែរ ។ លើសពីនេះ ប្រព័ន្ធ FMIS នេះអាចនឹងមានតម្រូវការធ្វើសន្ទានកម្មនិងសមកាលកម្ម ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងសមិទ្ធកម្មនៅកម្ពុជា។

### ៣.៥.៤ ការគ្រប់គ្រងការផ្លាស់ប្តូរនិងការប្រាស្រ័យទាក់ទងគ្នា

ការអនុវត្តការកែទម្រង់ការគ្រប់គ្រងថវិកាក្នុងទ្រង់ទ្រាយធំនេះ តម្រូវឱ្យមន្ត្រីសាធារណៈផ្លាស់ប្តូររបៀបរបបធ្វើការងារបច្ចុប្បន្ន ទាំងជាបុគ្គល ទាំងជាអង្គភាព។ កិច្ចខិតខំប្រឹងប្រែងក្នុងការផ្លាស់ប្តូរនេះអាចបង្កើតឱ្យមានបរិយាកាសតឹងតែងនិងព្រួយបារម្ភនៅក្នុងការអនុវត្តការងារដែលអាចនាំទៅដល់ការប្រឆាំងជំទាស់ឬការបង្កឧបសគ្គដោយចំហឬដោយស្ងៀមស្ងាត់។ ដូចនេះ ចាំបាច់ទាមទារឱ្យមានការពន្យល់បកស្រាយអំពីភាពចាំបាច់និងសារៈសំខាន់ដោយឈរលើហេតុផលច្បាស់លាស់ មានគោលការណ៍ត្រឹមត្រូវ មានការថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ដើម្បីកាត់បន្ថយភាពភ័យខ្លាចនិងលើកកម្ពស់ការចូលរួមនៅក្នុងដំណើរការកែទម្រង់។

កត្តាគន្លឹះដើម្បីធានាជោគជ័យនៅក្នុងការផ្លាស់ប្តូរ ចាំបាច់ត្រូវលើកកម្ពស់ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងគ្នា តាមរយៈការប្រកាសឱ្យដឹងអំពីចក្ខុវិស័យ និងទិសដៅនៃការផ្លាស់ប្តូរចរិតនៃការផ្លាស់ប្តូរ ពេលវេលា និងចំណុចសំខាន់នៃការផ្លាស់ប្តូរទៅដល់ក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន ចាប់ពីថ្នាក់ដឹកនាំរហូតដល់មន្ត្រីរាជការទូទៅ។ លើសពីនេះ ការប្រាស្រ័យទាក់ទងនេះត្រូវបង្ហាញឱ្យឃើញនិងឱ្យមានការជឿជាក់លើផលប្រយោជន៍ពិតប្រាកដនៃការផ្លាស់ប្តូរពីលក្ខខណ្ឌបច្ចុប្បន្នក្នុងការគ្រប់គ្រងថវិកា តាមទិសដៅថ្មីមួយដើម្បីបុព្វហេតុលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងថវិកា។

### ៣.៥.៥ ការលើកកម្ពស់តម្លាភាព

តម្លាភាពនិងការបើកចំហព័ត៌មាន គឺជាធាតុគន្លឹះនៅក្នុងប្រព័ន្ធថវិកាសមិទ្ធកម្ម។ ទិដ្ឋភាពទូទៅពាក់ព័ន្ធនឹងថវិកាដូចជា ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ក្របខ័ណ្ឌថវិការយៈពេលមធ្យម និងសមាសធាតុពាក់ព័ន្ធនឹងហានិភ័យហិរញ្ញវត្ថុ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានអនុម័ត ឯកសារថវិកាពាក់ព័ន្ធ និងសៀវភៅថវិកានឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។ ការផ្សព្វផ្សាយព័ត៌មាននឹងត្រូវធ្វើឡើងនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូចគ្នាដែរ ក្រសួង ស្ថាប័ននឹងផ្តល់ព័ត៌មានអំពីថវិការបស់ខ្លួន នៅលើគេហទំព័ររៀងៗខ្លួន។ ជារួម ការផ្តល់ព័ត៌មានសាធារណៈទាំងនេះ នឹងរួមចំណែកដល់ការលើកកម្ពស់ តម្លាភាព ព្រមទាំងជួយផ្តល់ជាទឡ្ហីករណ៍ មូលដ្ឋាននិងយុត្តិការសម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម។ បន្ថែមលើនេះទៀត តម្លាភាពនឹងត្រូវបានការលើកកម្ពស់បន្ថែមទៀត តាមរយៈការប្រើប្រាស់ប្រព័ន្ធ FMIS។

## ៣.៦. ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងប្រទេសកម្ពុជា រដ្ឋបាលសាធារណៈចែកចេញជាពីរកម្រិតរួមមាន រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលទាំងពីរកម្រិតមានគោលបំណងតែមួយ គឺសម្រេចឱ្យបាននូវគោលនយោបាយជាអាទិភាព និងសមិទ្ធផលសំខាន់ៗជូនប្រទេសជាតិ។ ក្នុងន័យនេះ ចាំបាច់ត្រូវធ្វើឱ្យមានសមាហរណកម្មផែនការនីយកម្មថវិការវាងរដ្ឋបាលទាំងពីរកម្រិត ទន្ទឹមនឹងនេះ ក៏ចាំបាច់ត្រូវធានាសង្គតិភាពកម្រិតគោលការណ៍និងអភិក្រមនៃការគ្រប់គ្រងថវិកាផងដែរ។ ដូច្នេះ ផ្នែកនេះនឹងផ្តោតជាសំខាន់ទៅលើការកែទម្រង់ប្រព័ន្ធថវិកា ដែលធ្វើសមាហរណកម្ម និងតម្រឹមគ្នារវាងបណ្តាលក្ខខណ្ឌនិងគោលការណ៍នៃការរៀបចំផែនការ ការគ្រប់គ្រងថវិកា និង ប្រព័ន្ធរបាយការណ៍រវាងថវិការដ្ឋបាលថ្នាក់ជាតិនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតែមួយ។

ក្រោយពីបានសិក្សាអំពីប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងប្រទេសជាច្រើនបង្ហាញថា ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្ពុជាមានភាពស្រដៀងគ្នាច្រើនទៅនឹងប្រទេសបារាំង។ នៅក្នុងន័យនេះ គំរូនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិរបស់ប្រទេសបារាំងបានផ្តល់ជាមូលដ្ឋានទស្សនាទាន សម្រាប់យកមកគិតគូររៀបចំប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបរិបទរបស់កម្ពុជា ជាពិសេស ការអនុវត្តនិងការត្រួតពិនិត្យ។

### ៣.៦.១. ក្របខ័ណ្ឌទស្សនាទាន

ក្នុងពេលបច្ចុប្បន្ន រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈកម្ពុជាទាំងពីរកម្រិតមានទំនាក់ទំនងដូចដ្យាក្រាមទី៤។

ប្រធានមន្ទីររាជធានីខេត្តនៃក្រសួង ស្ថាប័នត្រូវ បានតែងតាំងដោយរដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នសាមី តាមសំណើរបស់អភិបាលរាជធានី ខេត្ត។ នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលរាជធានី ខេត្តត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ចំណែកប្រធានក្រុមប្រឹក្សារាជធានី ខេត្តត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សា ដែលសមាជិកទាំងនោះត្រូវបានជ្រើសរើសដោយការបោះឆ្នោតអសកល។ នៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយអនុក្រឹត្យ ហើយប្រធានក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិក ដែលសមាជិកទាំងនោះត្រូវបានជ្រើសរើសដោយការបោះឆ្នោតអសកល។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ មានភារកិច្ចមួយក្នុងចំណោមភារកិច្ចដទៃទៀតគឺ

*ដ្យាក្រាមទី៤: ទំនាក់ទំនងរវាងរដ្ឋបាលទាំងពីរកម្រិតសម្រាប់ការអនុវត្តអាទិភាពគោលនយោបាយជាតិ*




ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍និងផែនការថវិកាប្រចាំឆ្នាំ( សូមមើលបន្ថែមឧបសម្ព័ន្ធ២.២ ស្តីពីសាវតានៃការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ)។ ចំណែកអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ ទទួលខុសត្រូវក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍របស់ខ្លួន ព្រមទាំងអនុវត្តសកម្មភាពទាំងនោះ។

បច្ចុប្បន្ន ការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំ តាមយន្តការត្រួតពិនិត្យមុន នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងថវិកាវិមជ្ឈការ ទាំងថវិកាវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ។ លើកលែងតែថវិកាឃុំ សង្កាត់

គឺមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តថវិកាដោយផ្ទាល់។ រតនាគាររាជធានី ខេត្ត ដើរតួនាទីជាគណនេយ្យករសាធារណៈ និងទូទាត់ចំណាយទាំងអស់របស់រដ្ឋបាលក្រោមជាតិទាំងបីថ្នាក់។

*ដ្យាក្រាមទី៥ : ក្របខ័ណ្ឌទស្សនាទាននៃសមាហរណកម្មផែនការនីយកម្មថវិកាថ្នាក់ជាតិនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ*




ការកែទម្រង់ប្រព័ន្ធថវិកានឹងធ្វើសមាហរណកម្មផែនការនីយកម្មនៃរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយតម្រឹមកម្មវិធីទៅតាមរចនាសម្ព័ន្ធរដ្ឋបាលដូចបានបង្ហាញក្នុងដ្យាក្រាមទី៤។ គោលដៅសំខាន់នៃការធ្វើសមាហរណកម្មផែនការនីយកម្ម គឺការលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡានិងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ ដើម្បីសម្រេចគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(ឧបសម្ព័ន្ធ២.៣ ពន្យល់បន្ថែមអំពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ)។ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងបង្កើតជាអភិក្រមសម្រាប់ការធ្វើសមាហរណកម្មនេះ។ ដ្យាក្រាមទី៥បង្ហាញពីកម្មវិធីនៅរដ្ឋបាលទាំងពីរថ្នាក់ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានគោលបំណងតាមវិស័យនិងការសម្រេចបានអាទិភាពគោលនយោបាយជាតិ។ សម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើការរួមគ្នា ដើម្បីធ្វើផែនការនីយកម្ម និងអនុវត្តឱ្យបានសម្រេចនូវគោលបំណងរួមតាមវិស័យ។ ដោយឡែក កម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើផែនការឆ្លើយតបទៅនឹងអាទិភាពនៅមូលដ្ឋានរបស់ខ្លួន ដោយតម្រឹមទៅនឹងគោលបំណងតាមវិស័យ ដែលជាវិភាគទានសម្រាប់សម្រេចបានអាទិភាពជាតិ។

ក្នុងពេលបច្ចុប្បន្ន ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈគឺជាមគ្គុទ្ទេសក៍សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា នៅក្នុងដំណើរការរៀបចំថវិកា ទាំងសម្រាប់ក្រសួង ស្ថាប័ន ទាំងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សម្រាប់ការងារនេះ ក៏មានយន្តការសម្របសម្រួលសម្រាប់ដាក់បញ្ចូលកម្មវិធីតាមវិស័យទៅក្នុង

កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែប្រសិទ្ធភាពនៃយន្តការនេះនៅមានកម្រិត។ ដំណើរការរៀបចំនិងអនុម័តថវិកាត្រូវបានដឹកមុខដោយថ្នាក់ជាតិ ក្នុងនោះ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវិភាជជាកញ្ចប់ ដោយមិនទាន់បំបែកលម្អិតទៅតាមកម្មវិធីនៅឡើយទេ។ អភិបាលរាជធានី ខេត្តទាំងអស់ត្រូវបញ្ជូនសំណើថវិការបស់ខ្លួនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចរចានិងសុំការអនុម័តយល់ព្រម។ ចំពោះការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យនិងរបាយការណ៍ គឺផ្អែកតាមអភិក្រមមជ្ឈការ។ ប្រតិបត្តិការហិរញ្ញវត្ថុ ដែលរួមមាន ចំណូល ចំណាយ និងសាច់ប្រាក់ និងកិច្ចការគណនេយ្យសាធារណៈត្រូវបានប្រមូលផ្តុំនៅរតនាគាររាជធានី ខេត្ត។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើអធិការកិច្ចហិរញ្ញវត្ថុ ចំណែកអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មឯករាជ្យ។

ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា គឺការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាកម្មវិធី និងឈានជាជំហានឆ្ពោះទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្មនៅឆ្នាំ២០២៥។ ជាគោលការណ៍ គោលបំណងនិងក្របខ័ណ្ឌនានានៃថវិកាកម្មវិធីឬថវិកាសមិទ្ធកម្ម គឺអនុវត្តដូចគ្នាចំពោះរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ សមាសធាតុគន្លឹះនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិដែលបានរៀបរាប់នៅផ្នែកខាងដើមនៃជំពូកនេះ ក៏ជាការកំណត់ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ ដោយគ្រាន់តែត្រូវប្រើពេលវែងជាង និងមានការកែតម្រូវទៅតាមបរិការណ៍នៃការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ នៅក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតែមួយ នឹងមានប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិមួយសម្រាប់អនុវត្តថវិការបស់ខ្លួន ដែលមានសមាហរណកម្ម និងតម្រឹមគ្នារវាងបណ្តាលក្ខខណ្ឌ និងគោលការណ៍នៃការរៀបចំ និងការអនុវត្តជាមួយនឹងប្រព័ន្ធថវិកាជាតិ។

### ៣.៦.២ ការធ្វើផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត

ក្នុងពេលបច្ចុប្បន្ន បន្ទាប់ពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់រួច រាជរដ្ឋាភិបាលចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាតិ។ ផ្អែកលើសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចេញសារាចរណែនាំដោយឡែកមួយទៀតស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្ត។ ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំនៅកម្រិតរាជធានី ខេត្ត ដោយផ្អែកលើកម្មវិធី និងអាទិភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងតម្រឹមជាមួយនឹងអាទិភាពជាតិ/ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរាជធានីខេត្តនីមួយៗ។ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តត្រូវបានដាក់ឱ្យក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័តសិន មុននឹងបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ដែលជាលទ្ធផលនៃការធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍នៃគ្រប់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលរាជធានី ខេត្តបានរៀបចំផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេលប្រាំឆ្នាំម្តង ដោយត្រូវដាក់ឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តមុនពេលបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីពិភាក្សានិងសម្រេច។ ផែនការអភិវឌ្ឍន៍ទាំងនោះត្រូវបានរៀបចំដាច់ដោយឡែក និងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួនដើម្បីពិនិត្យនិងអនុម័ត មុនពេលបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តដើម្បីបូកសរុប។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ មិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទេ។

បច្ចុប្បន្ន ការតម្រឹមផែនការ/កម្មវិធីតាមខ្សែទទឹង រវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី ខេត្តនៅមិនទាន់បានធ្វើនៅឡើយទេ ដោយសារតែពុំទាន់មានការប្រឹក្សាយោបល់គ្នានិងសហការគ្នាឱ្យបានគ្រប់គ្រាន់រវាងក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចនេះ ការប្រតិបត្តិបច្ចុប្បន្នមិនទាន់ផ្តល់ជាមូលដ្ឋានសមាហរណកម្មល្អរវាងផែនការនីយកម្មនៃស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

គោលបំណងនៅឆ្នាំ២០២៥ គឺកែលម្អជាបណ្តើរៗនូវដំណើរការធ្វើផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តឱ្យមានលក្ខណៈសមាហរណកម្ម ដែលផ្សារភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការ/កម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ/ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងផ្អែកទៅលើក្របខ័ណ្ឌថវិកាជាតិរយៈពេលមធ្យម ដែលក្នុងនោះ មានការកំណត់ពិដានថវិកាសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត នីមួយៗ។ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តនឹងត្រូវបានធ្វើសមាហរណកម្មតាមខ្សែទទឹង សម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងមានការតម្រឹមតាមខ្សែបណ្តោយ ជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ សម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ ដំណើរការនៃការធ្វើសមាហរណកម្មតាមខ្សែទទឹងនិងការតម្រឹមតាមខ្សែបណ្តោយ គឺធ្វើឡើងក្នុងគោលដៅប្រើប្រាស់ធនធានដែលមានកម្រិត ដើម្បីសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា សម្រាប់ជាគុណប្រយោជន៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រការនេះតម្រូវឱ្យមានការកែលម្អដំណើរការប្រឹក្សាយោបល់និងការសម្របសម្រួលរវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណាក់កាលនៃការធ្វើផែនការយុទ្ធសាស្ត្រថវិកា និងការគាំទ្រដល់ការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ។

ដើម្បីពង្រឹងនូវវិន័យថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកំណត់នូវពិដានថវិកាសម្រាប់ថ្នាក់ក្រោមជាតិដែលនឹងក្លាយជាមគ្គុទ្ទេសក៍សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តនឹងត្រូវតម្រឹម និងធ្វើសមាហរណកម្មជាមួយនឹងគោលនយោបាយថ្នាក់រាជធានី ខេត្ត ដើម្បីគាំទ្រដល់គោលនយោបាយនិងលទ្ធផលតាមវិស័យដូចមានបង្ហាញនៅក្នុងដ្យាក្រាមទី៥ខាងលើ។ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ នឹងរៀបចំផែនការអន្តរាគមន៍របស់ខ្លួន ដើម្បីគាំទ្រដល់អាទិភាពគោលនយោបាយរដ្ឋបាលរាជធានី ខេត្ត ដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យនិងអាទិភាពជាតិ។ ដោយសារផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានីខេត្តត្រូវបានរៀបចំ ដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិចុះមក ផែនការយុទ្ធសាស្ត្រថវិកានេះក៏ត្រូវផ្តល់ភាពទន់ភ្លន់ឱ្យមានការដាក់បញ្ចូលនូវអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពរនានាពីរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលជាអភិក្រមពីក្រោមទៅលើ។

**៣.៦.៣ ការរៀបចំគម្រោងថវិកា ការចរចាថវិកា និងការអនុម័តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងពេលបច្ចុប្បន្ន ទោះបីជាដំណើរការរៀបចំគម្រោងថវិកាក្រសួងស្ថាប័ន និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឡើងតាមដំណើរការពីរផ្សេងគ្នាក្តី ក៏ការរៀបចំថវិកាទាំងពីរនេះជួបប្រសព្វគ្នានៅកម្រិតរាជធានី ខេត្ត។ ថវិកាមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបានរៀបចំដោយក្រសួង ស្ថាប័ន ដោយផ្អែកលើផែនការនីយកម្មពីលើចុះក្រោមទៅតាមអាទិភាពជាតិ ហើយត្រូវបានចរចា និងយល់ព្រមដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួចអនុម័តដោយស្ថាប័ននីតិបញ្ញត្តិជាផ្នែកមួយនៃថវិកាជាតិ។ ថវិការដ្ឋបាលថ្នាក់រាជធានី ខេត្តត្រូវបានរៀបចំនិងដាក់ឱ្យក្រុមប្រឹក្សារាជធានី

ខេត្តពិនិត្យ និងអនុម័ត ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចរចា និងយល់ព្រម និងបូកសរុបដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ ដោយឡែក ថវិកាសរុបសម្រាប់ក្រុង ស្រុក និង ថវិកាសម្រាប់ឃុំ សង្កាត់ ត្រូវបានវិភាជក្នុងសមាមាត្រជាក់លាក់នៃចំណូលចរន្តថ្នាក់ជាតិឆ្នាំកំពុងអនុវត្ត។ ទំហំនៃការវិភាជនេះត្រូវកំណត់ដោយផ្អែកតាមរូបមន្តជាក់លាក់មួយ ដែលជាអនុគមន៍នៃចំណែកស្មើៗគ្នា ទំហំប្រជាជន សន្ទស្សន៍នៃភាពក្រីក្រ ចំនួនក្រុមប្រឹក្សា និងចំនួនឃុំ សង្កាត់ (សម្រាប់ ក្រុង ស្រុក) ឬចំនួនភូមិ (សម្រាប់ឃុំ សង្កាត់)។រដ្ឋបាលរាជធានី ខេត្តផ្តល់នូវការគាំទ្របច្ចេកទេសដល់ការរៀបចំថវិកាក្រុង ស្រុក។ បន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យនិងអនុម័តថវិកាក្រុង ស្រុករួច មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុបថវិកានេះនៅតាមខេត្តនីមួយៗ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលឃុំ សង្កាត់នីមួយៗរៀបចំថវិកាដោយខ្លួនឯង រួចដាក់ឱ្យក្រុមប្រឹក្សាខ្លួនពិនិត្យនិងអនុម័ត បន្ទាប់មកបញ្ជូនទៅរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងផ្តល់អនុលោមភាព។ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ជាផ្នែកមួយនៃថវិកាជាតិ។ មន្ទីរជំនាញរាជធានី ខេត្ត មិនមានពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំគម្រោងថវិកានេះទេ។ ទោះបីជាមានដំណើរការរៀបចំគម្រោងថវិកា ការចរចាថវិកា និងការអនុម័តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិច្បាស់លាស់បែបនេះក្តី ក៏ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅមានបញ្ហាផ្នែកគុណភាព ភាពគ្រប់ជ្រុងជ្រោយ និងភាពមិនច្បាស់លាស់នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

គោលបំណងនៅឆ្នាំ២០២៥ គឺធ្វើឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានភាពគ្រប់ជ្រុងជ្រោយ ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ថវិកាចរន្តនិងថវិកាមូលធននឹងត្រូវធ្វើសមាហរណកម្ម។ ការចរចាថវិការដ្ឋបាលថ្នាក់រាជធានី ខេត្តនឹងតម្រង់ទិសឆ្ពោះទៅរកការផ្តោតលើលទ្ធផលក្នុងឆ្នាំនៃកម្មវិធី។ ដោយសារប្លង់គណនីតម្រូវឱ្យមានការឯកភាពគ្នា ហើយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងត្រូវដាក់ពង្រាយទៅដល់រដ្ឋបាលរាជធានីខេត្ត ដូចនេះ ចំណាត់ថ្នាក់ថវិកានឹងត្រូវប្រើដូចគ្នានឹងថ្នាក់ជាតិដែរ។ ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនឹងមានតែមួយ ដែលរួមមានថវិកាថ្នាក់ជាតិនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិការដ្ឋបាលរាជធានី ខេត្តនឹងឆ្លុះបញ្ចាំងជាសរុបតាមខេត្តនីមួយៗ ដោយចែកជាថវិកាចរន្ត និងថវិកាមូលធនជាឧបសម្ព័ន្ធនៃច្បាប់។ ដោយឡែក ថវិការបស់រដ្ឋបាលក្រុង ស្រុក និង ឃុំ សង្កាត់ នឹងត្រូវឆ្លុះបញ្ចាំងជាទំហំសរុបដុល ដែលជាលទ្ធផលនៃការវិភាជលម្អិតតាមរដ្ឋបាលនីមួយៗ ដោយផ្អែកលើរូបមន្តបែងចែកជាក់លាក់ និងផ្អែកលើសមិទ្ធកម្ម។ នៅពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែត្រូវបានកែលម្អ គោលការណ៍នៃការរៀបចំ និងអនុម័តថវិកានឹងត្រូវពិនិត្យឡើងវិញ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។

ជារួម ការកែទម្រង់ការរៀបចំថវិកា ការចរចាថវិកា ការយល់ព្រមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងការដាក់ជូនគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័ត គឺត្រូវធ្វើឱ្យស៊ីចង្វាក់គ្នានៅក្រោមគោលការណ៍នៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ។

### ៣.៦.៤ ការអនុវត្តនិងការត្រួតពិនិត្យថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

#### ក. សិទ្ធិអំណាចនៃការបញ្ជាចំណាយ

ក្នុងប្រព័ន្ធបច្ចុប្បន្ន រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក តម្រូវឱ្យស្នើសុំទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធានាចំណាយ លើកលែងតែថវិការដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានផ្តល់សិទ្ធិស្វ័យសម្រេចក្នុងការចាត់ចែងចំណាយដោយខ្លួនឯង។ ក្រោយពេលប្រកាសដាក់ឱ្យចូលជាធរមាននៃច្បាប់ថវិកាប្រចាំឆ្នាំនិងការដាក់ឱ្យអនុវត្តសៀវភៅថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិអាចស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន។ ដោយឡែក មុខចំណាយប្រតិបត្តិការប្រក្រតីផ្សេងៗទៀតត្រូវបានអនុវត្តតាមនីតិវិធីនៃការផ្តល់ធានាចំណាយនិងនីតិវិធីលទ្ធកម្មសាធារណៈ។ នៅពេលរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ទទួលបានទំនិញនិងសេវាកម្ម ព្រមទាំងបានផ្ទៀងផ្ទាត់រួចរាល់ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដោយមានភ្ជាប់លិខិតយុត្តការគាំទ្រ និងដាក់ឆ្លងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីត្រូវបានពិនិត្យនិងអនុម័តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាណត្តិបើកប្រាក់ដែលត្រូវបានចុះទិដ្ឋាការរួច ព្រមជាមួយនឹងលិខិតយុត្តការគាំទ្រត្រូវបានបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីពិនិត្យ ទូទាត់ និងបើកផ្តល់។

គោលបំណងនៅឆ្នាំ២០២៥ គឺនៅពេលច្បាប់ថវិកាត្រូវបានអនុម័តរួច ឥណទានថវិកានឹងក្លាយជាមូលដ្ឋានក្នុងការផ្តល់ការអនុញ្ញាតឱ្យបញ្ជាចំណាយពេញមួយឆ្នាំ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអនុញ្ញាតឱ្យបញ្ជាចំណាយនឹងត្រូវធ្វើឡើងជាកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស ស្របតាមគោលការណ៍កំណត់ លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ និង/ឬ មានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីចំណាយប្រចាំត្រីមាស/ឆមាសគឺជាការបែងចែកធនធានទៅតាមកម្មវិធី អង្គភាពថវិកា មុខចំណាយ និងពេលវេលា។ នីតិវិធីនៃការអនុវត្តថវិកានឹងត្រូវបានធ្វើទំនើបកម្មនិងពន្លឿនថែមទៀត តាមរយៈការលើកកម្ពស់ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

កត្តាគន្លឹះនៃភាពជោគជ័យនៃប្រព័ន្ធថវិកាសមិទ្ធកម្ម គឺជាដំណើរការនៃការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅដល់អ្នកគ្រប់គ្រងផ្ទាល់ ក្នុងការចាត់ចែងធនធានឱ្យបានល្អបំផុត ដើម្បីសម្រេចសមិទ្ធកម្ម។ ដោយផ្អែកលើគោលការណ៍នេះ រដ្ឋបាលរាជធានី ខេត្ត និង រដ្ឋបាលក្រុង ស្រុក នឹងទទួលខុសត្រូវ និងមានគណនេយ្យភាពទាំងស្រុង ចំពោះការអនុវត្ត និងត្រួតពិនិត្យហិរញ្ញវត្ថុ។ នៅរដ្ឋបាលឃុំ សង្កាត់ ដោយសារតែក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជន ដូចនេះ គណនេយ្យភាពសង្គមនៅរដ្ឋបាលឃុំ សង្កាត់គឺជាអាទិភាពខ្ពស់។

#### ខ. ការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងពេលបច្ចុប្បន្ន ការត្រួតពិនិត្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ទាំងក្នុងដំណាក់កាលធានាចំណាយ កិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់ លើកលែងតែថវិការដ្ឋបាលឃុំ សង្កាត់។ ការត្រួតពិនិត្យថវិកាត្រូវបានអនុវត្តដូចនៅថ្នាក់ជាតិដែរ ដោយផ្អែកលើអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង

ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាលនិងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យករសាធារណៈ។ ចំពោះការធ្វើនិយ័តកម្មថវិកាក៏នៅមិនទាន់មានភាពទន់ភ្លន់គ្រប់គ្រាន់។

គោលបំណងនៅឆ្នាំ២០២៥ គឺពន្លឿននិងធ្វើសាមញ្ញកម្មការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រគល់សិទ្ធិជាអតិបរមា តាមការវិវត្តនៃការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងឧត្តមានុវត្តអន្តរជាតិ ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាពនិងគណនេយ្យភាពស្របតាមទស្សនាទាននៃថវិកាសមិទ្ធកម្ម។

ស្របតាមទិសដៅនេះដែរ ចំពោះថវិការដ្ឋបាលរាជធានី ខេត្ត យន្តការត្រួតពិនិត្យការអនុវត្តថវិកាដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម នឹងត្រូវទទួលបាននូវប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវផ្ទាល់កាន់តែច្រើនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងមុខងារត្រួតពិនិត្យផ្នែកចំណាយ សិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវលើកកម្ពស់ថែមទៀត។ ដូចគ្នានឹងថវិកាថ្នាក់ជាតិដែរ មុខងារគណនេយ្យករសាធារណៈនឹងត្រូវបន្តអនុវត្តយន្តការដោយឡែកដូចបច្ចុប្បន្ន ក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ ប៉ុន្តែត្រូវកាត់បន្ថយការត្រួតពិនិត្យឱ្យមកនៅត្រឹមកម្រិតអប្បបរមា តាមរយៈការរៀបចំគតិយុត្តឱ្យច្បាស់លាស់ និងមានប្រសិទ្ធភាពព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធ FMIS និង E-Transfer។ នៅពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិកាកាន់តែត្រូវបានកែលម្អស្របតាមឧត្តមានុវត្តជាអន្តរជាតិនិងសមត្ថភាពនៃស្ថាប័នពាក់ព័ន្ធកាន់តែខ្ពស់ មុខងារគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្តអាចនឹងត្រូវធ្វើសមាហរណកម្មជាមួយនឹងមុខងារត្រួតពិនិត្យថវិកានៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យយន្តការត្រួតពិនិត្យមានលក្ខណៈកាន់តែមានប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយ ដែលជាបុរេលក្ខខណ្ឌសម្រាប់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែមានគណនេយ្យភាពពេញលេញ ទាំងផ្នែកហិរញ្ញវត្ថុ ទាំងផ្នែកសមិទ្ធកម្ម។

ចំពោះថវិការដ្ឋបាលក្រុង ស្រុក និងថវិការដ្ឋបាលឃុំ សង្កាត់ ការត្រួតពិនិត្យការអនុវត្តថវិកាត្រូវធ្វើតាមរយៈរតនាគាររាជធានី ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ។ លើសពីនេះ ក្នុងគោលបំណងពន្លឿន និងសម្រួលដល់ការអនុវត្តថវិកា ជាពិសេសដើម្បីផ្តល់សេវាទូទាត់ឱ្យបានឆាប់រហ័ស គណនេយ្យករសាធារណៈអាចនឹងត្រូវដាក់ឱ្យនៅអមរដ្ឋបាលក្រុង ស្រុក ដោយអាចពង្រីកជាជំហានៗទៅតាមលទ្ធភាព និងតាមការចាំបាច់ជាក់ស្តែង។ ការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ជាកម្មវត្ថុនៃការត្រួតពិនិត្យក្រោយចំណាយ។

ក្នុងន័យនេះ ដើម្បីធានាប្រតិតុល្យការ ចាំបាច់ត្រូវលើកកម្ពស់តួនាទី និងភារកិច្ចអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទោះយ៉ាងនេះក្តី ដើម្បីធានាប្រសិទ្ធភាពនិងភាពសន្សំសំចៃខ្ពស់ ការងារអធិការកិច្ចហិរញ្ញវត្ថុនឹងត្រូវកំណត់ឱ្យធ្វើត្រឹមកម្រិតអប្បបរមា ដោយឈរលើមូលដ្ឋាននៃភាពចាំបាច់ជាក់ស្តែង ការរាយការណ៍ដោយគណនេយ្យករសាធារណៈ និងការប្តឹងផ្តល់ឬព័ត៌មាននៃភាពមិនប្រក្រតីជាយថាហេតុ។ ក្របខ័ណ្ឌ និងនីតិវិធីលម្អិត

នៃការងារអធិការកិច្ចហិរញ្ញវត្ថុលើការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងរដ្ឋបាល ឃុំ សង្កាត់ នឹងត្រូវកំណត់ដោយឡែក។

### ៣.៦.៥ ប្រព័ន្ធរបាយការណ៍ ការតាមដាន និងការវាយតម្លៃថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្ន ប្រព័ន្ធរបាយការណ៍ថវិកាថ្នាក់ក្រោមជាតិនៅមិនទាន់ល្អប្រសើរ និងមិនទាន់ទៀងទាត់នៅឡើយ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានប្រព័ន្ធរបាយការណ៍ស្រដៀងគ្នានឹងថ្នាក់ជាតិ ប៉ុន្តែសាមញ្ញជាង និងសមស្របទៅតាមការទទួលខុសត្រូវជាស្ថាប័ននិងគតិយុត្តនៅថ្នាក់ក្រោមជាតិ។ ដ្យាក្រាមទី៥បានបង្ហាញឱ្យឃើញពីតួនាទីសំខាន់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្រេចគោលបំណងកម្មវិធី និងការផ្តល់សេវាសាធារណៈ។

របបរបាយការណ៍នៃចង្កោមកម្មវិធីថវិការដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើពីក្រោមឡើងលើ។ រដ្ឋបាលឃុំ សង្កាត់នឹងរាយការណ៍ពីវឌ្ឍនភាពក្នុងទម្រង់ជាលទ្ធផលក្នុងឆ្នាំនៃសកម្មភាពទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំណែករដ្ឋបាលក្រុង ស្រុកខណ្ឌ ត្រូវរាយការណ៍ពីវឌ្ឍនភាពនៃអនុកម្មវិធីទៅឱ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើរបាយការណ៍បូកសរុបទាំងរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មនៅកម្រិតកម្មវិធី និងរាយការណ៍ទៅក្រុមប្រឹក្សា រាជធានី ខេត្ត និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការវាយតម្លៃនឹងធ្វើទៅតាមចង្កោមកម្មវិធីសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីវាស់ស្ទង់គុណភាពនៃការផ្តល់សេវាសាធារណៈ និងភាពពេញចិត្តរបស់អ្នកទទួលសេវានៅថ្នាក់រាជធានី ខេត្ត។

គោលបំណងនៅឆ្នាំ២០២៥ នឹងធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍នៅថ្នាក់ក្រោមជាតិ និងបង្កើនសមត្ថភាពថ្នាក់ក្រោមជាតិឱ្យធ្វើរបាយការណ៍សមិទ្ធកម្មនៅថ្នាក់រាជធានី ខេត្ត។

៚៚✵៙៙

# ជំពូកទី៤

# ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រឆ្នាំ២០២៥

ជំពូកទី២បានគូសបញ្ជាក់រួចហើយពីភាពចាំបាច់នៃការកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មក្នុងគំរូជា**«ថវិកាព័ត៌មានសមិទ្ធកម្ម»**។ ទិសដៅយុទ្ធសាស្ត្រថ្មីនេះត្រូវបានរៀបចំដោយកំណត់គោលបំណងដែលមានលក្ខណៈជាក់ស្តែងនិយម គ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ជាងមុន សម្រាប់កែប្រព័ន្ធថវិកាកម្ពុជាចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២៥។ ជំពូកទី៤នេះដាក់ចេញនូវសកម្មភាពកែទម្រង់តាមអភិក្រមសាមញ្ញជាក់ស្តែង តាមលំដាប់លំដោយ ដើម្បីសម្រេចបានគោលបំណងទាំងឡាយ ដែលបានកំណត់នៅក្នុងជំពូក៣។

យុទ្ធសាស្ត្រនេះបានរក្សាទុកគោលបំណងដើមនៃការអនុវត្តថវិកាកម្មវិធីពេញលេញ គឺប្រើប្រាស់កម្មវិធីជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយឱ្យបាននៅឆ្នាំ២០២០ ហើយបន្ទាប់ពីនោះនឹងចាប់ផ្តើមឈានទៅអនុវត្តថវិកាសមិទ្ធកម្ម ចាប់ពីឆ្នាំ២០២២ តទៅ ដោយពង្រឹងជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្ម/លទ្ធផល និងគណនេយ្យភាព ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងត្រៀមខ្លួនសម្រាប់អនុវត្តថវិកាសមិទ្ធកម្មពេញលេញចាប់ពីឆ្នាំ២០២៥។ គោលបំណងខាងលើមានសង្គតិភាពទៅនឹងដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៥-២០២០) និងដំណាក់កាលទី៤ គឺគណនេយ្យភាពសមិទ្ធកម្ម (២០២១-២០២៥)នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៤.១. វិសាលភាព

ជំពូកទី៤គូសរំលេចអំពីផែនទីចង្អុលផ្លូវក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាជាតិ ដោយប្រមូលផ្តុំលើសមាសធាតុគន្លឹះចំនួន៤ គឺការធ្វើផែនការកម្រិតយុទ្ធសាស្ត្រ ការរៀបចំគម្រោង និងការអនុម័តថវិកា ការអនុវត្តថវិកានិងការត្រួតពិនិត្យហិរញ្ញវត្ថុ និងការតាមដានការធ្វើរបាយការណ៍និងការវាយតម្លៃ ដូចមានចែងនៅក្នុងជំពូកទី៣។ ទន្ទឹមនឹងនេះ ក៏មានកំណត់ផែនទីចង្អុលផ្លូវសម្រាប់ការកែទម្រង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រសំខាន់ៗមួយចំនួន។

ជំពូកទី៤នេះមិនគូសរំលេចផែនទីចង្អុលផ្លូវសម្រាប់រៀបចំការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិទេ ព្រោះកិច្ចការនេះនឹងត្រូវរៀបចំដោយឡែក ដោយផ្អែកលើទិសដៅ គោលដៅ គោលការណ៍គន្លឹះៗ និងក្របខ័ណ្ឌដែលបានកំណត់នៅក្នុងជំពូកទី៣ ចំណុច៣.៦ ក៏ដូចជាផែនទីចង្អុលផ្លូវសម្រាប់ការកែទម្រង់ប្រព័ន្ធថវិកាជាតិដែលនឹងចង្អុលក្នុងជំពូកនេះ។ ទន្ទឹមនឹងនេះ ជំពូកទី៤ក៏មិនរួមបញ្ចូលផែនទីចង្អុលផ្លូវសម្រាប់ការកែទម្រង់ពាក់ព័ន្ធមួយចំនួន ដូចជា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងរំហូរសាច់ប្រាក់ ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ និងការកែទម្រង់សវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យសមិទ្ធកម្មដែលមានហេតុបច្ច័យទៅដល់ការកែទម្រង់ប្រព័ន្ធថវិកាផងដែរ។ ការកែទម្រង់ទាំងនោះនឹងត្រូវបំរដោះស្រាយដោយឡែកនៅក្រោម ផែនការសកម្មភាពរួមដំណាក់កាលទី៣និងទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ទោះយ៉ាងណាក៏ដោយ សមាសធាតុ

នៃការកែទម្រង់ទាំងនេះ ចាំបាច់ត្រូវពិនិត្យនៅពេលធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ ២០២០ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ដើម្បីគាំទ្រការផ្លាស់ប្តូរប្រព័ន្ធថវិកា។

**៤.២. ផែនទីចង្អុលផ្លូវ**

**៤.២.១. ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ**

ការធ្វើផែនការកម្រិតយុទ្ធសាស្ត្រនឹងត្រូវបានពង្រឹង តាមរយៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ក្របខ័ណ្ឌថវិការយៈពេលមធ្យម និងផែនការយុទ្ធសាស្ត្រថវិកា។

- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម គុណភាពនៃការរៀបចំក្របខ័ណ្ឌនេះនឹងត្រូវបានកែលម្អតាមរយៈការកសាងសមត្ថភាពនិងការសម្របសម្រួលកាន់តែល្អប្រសើរថែមទៀតរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា។ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ដឹកនាំការពិនិត្យពិភាក្សា និងសម្រេច មុនពេលដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេចជាចុងក្រោយ។

- ក្របខ័ណ្ឌថវិការយៈពេលមធ្យម ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមបច្ចុប្បន្ននឹងត្រូវរៀបចំឡើងវិញ និងប្តូរទៅជាក្របខ័ណ្ឌថវិការយៈពេលមធ្យម ដោយរៀបចំឱ្យមានការកំណត់ពិដានថវិកាដែលនឹងត្រូវបានអនុវត្តដោយម៉ឺងម៉ាត់ តាមវិស័យ តាមក្រសួង ស្ថាប័ន និងតាមរដ្ឋបាលរាជធានី ខេត្ត។

*ក្របខ័ណ្ឌទាំងពីរ ដែលនឹងក្លាយជាប្រព័ន្ធដែលមានលក្ខណៈសមាហរណកម្មនិងឆ្លើយឆ្លងគ្នា ត្រូវចាប់អនុវត្តជាផ្លូវការតាមទិសដៅដែលបានកំណត់ក្នុងជំពូក៣ ចាប់ពីឆ្នាំ២០២១តទៅ។*

- ផែនការយុទ្ធសាស្ត្រថវិកា: គុណភាពនៃផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវពង្រឹងដោយផ្តោតទៅលើកិច្ចការសំខាន់ពីរ គឺ (១)-ពង្រឹងឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធី ជាពិសេស គឺពិនិត្យឡើងវិញពីគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធ ដោយធានាឱ្យមានការផ្សារភ្ជាប់កាន់តែល្អទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទន្ទឹមនឹងនេះ ព័ត៌មានសមិទ្ធកម្មនឹងត្រូវកែលម្អដើម្បីបង្កើតជាមូលដ្ឋានអាចទុកបានសម្រាប់ការគ្រប់គ្រងបែបសមិទ្ធកម្ម (២)-សមាហរណកម្មចំណាយមូលធនទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ដើម្បីឱ្យមានព័ត៌មានគ្រប់ជ្រុងជ្រោយ ទាំងចំណាយចរន្ត ទាំងចំណាយមូលធន។ *កិច្ចការទាំងពីរនេះត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០២០។*

ទន្ទឹមនឹងផ្តោតលើកិច្ចការសំខាន់ទាំងពីរខាងលើ គុណភាពផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវកែលម្អ តាមរយៈការកសាងសមត្ថភាពមន្ត្រីវិភាគថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកគ្រប់គ្រងថវិកានិងអង្គភាពថវិកាទាំងអស់នៅតាមក្រសួង ស្ថាប័ន។ ការងារនេះ រួមបញ្ចូលការធ្វើបច្ចុប្បន្នកម្ម ***គោលការណ៍ណែនាំរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគោលការណ៍ណែនាំរៀបចំថវិកា*** *ដែលនឹងចាប់ផ្តើមពីឆ្នាំ២០១៨* តទៅ និងបន្ទាប់មករៀបចំកម្មវិធីបណ្តុះបណ្តាល។

**៤.២.២. ការរៀបចំនិងអនុម័តថវិកា**

ការរៀបចំថវិកាប្រចាំឆ្នាំនឹងត្រូវពង្រឹង ទន្ទឹមគ្នានឹងការលើកកម្ពស់គុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។ ក្នុងន័យនេះ ដើម្បីការត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ ទាំងគុណភាព សម្រាប់ការអនុវត្ត

ថវិកាសមិទ្ធកម្មនាពេលខាងមុខ ត្រូវបង្កើនចលនការនៃការរៀបចំថវិកាកម្មវិធីពេញលេញ ឱ្យសម្រេចបានតាមផែនការកំណត់ ដោយគ្រប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីត្រឹមឆ្នាំ២០១៨ និងគ្រប់រដ្ឋបាលរាជធានី ខេត្តអនុវត្តថវិកាកម្មវិធីនៅត្រឹមឆ្នាំ២០២០ ទន្ទឹមនឹងការសម្រេចឱ្យបានជាសារវន្តនូវសមាហរណកម្មថវិកាចរន្តនិងមូលធននៅឆ្នាំ២០២០។

ទន្ទឹមនឹងការពង្រឹងនិងពង្រីកថវិកាកម្មវិធី ប្រព័ន្ធមាតិកាថវិកានឹងត្រូវបានពង្រីកនិងប្រើប្រាស់ទាំង៧ចំណាត់ថ្នាក់ (សេដ្ឋកិច្ច រដ្ឋបាល មុខងារ ភូមិសាស្ត្រ កម្មវិធី ប្រភពមូលនិធិ និងគម្រោង) ដោយដាក់បញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ដែលដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៨និងសម្រេចឱ្យបានជាសារវន្តនៅឆ្នាំ២០២២។

ក្នុងគោលដៅពង្រឹងការរៀបចំថវិកាប្រចាំឆ្នាំ ការរៀបចំនិងដាក់ឱ្យអនុវត្តពិដានថវិកាសម្រាប់ក្រសួង ស្ថាប័ននឹងត្រូវចាប់ផ្តើមពីឆ្នាំ២០១៨ ហើយអនុវត្តពេញលេញ និងមានប្រសិទ្ធភាពនៅឆ្នាំ២០២១។ ក្រសួង ស្ថាប័ន នឹងត្រូវភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើគម្រោងថវិកា ចាប់ពីឆ្នាំ២០១៩តទៅ។

ដូចបានគូសរំលេចនៅក្នុងជំពូក៣ គោលបំណងសំខាន់នៃយុទ្ធសាស្ត្រ គឺនៅពេលច្បាប់ថវិកាត្រូវបានអនុម័តរួច ឥណទានថវិកានឹងក្លាយជាមូលដ្ឋាននៃការអនុញ្ញាតឱ្យបញ្ជាចំណាយសម្រាប់ក្រសួង ស្ថាប័ន។ នៅក្នុងន័យនេះ ចំណាយរដ្ឋទេយ្យបុរេប្រទាននឹងត្រូវអនុវត្តក្រោមក្របខ័ណ្ឌគតិយុត្តរួមដែលគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ត្រឹមឆ្នាំ២០២០ ជំនួសឱ្យការអនុវត្តបច្ចុប្បន្នដែលធ្វើឡើងដោយប្រកាសអន្តរក្រសួងជារៀងរាល់ឆ្នាំ។ ទន្ទឹមនឹងនេះ ជំនួសឱ្យនីតិវិធីបច្ចុប្បន្នដែលផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំនិងសម្រេច ក្រោយកិច្ចចរចាថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ការពិនិត្យនិងសម្រេចផែនការលទ្ធកម្មនឹងត្រូវធ្វើនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន សម្រាប់ជាមូលដ្ឋាននៃការផ្តល់ការឯកភាពជាផ្លូវការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ពីឆ្នាំ២០២០។

ក្របខ័ណ្ឌនៃការចរចាថវិកានឹងត្រូវពង្រឹងបន្ថែម ដោយផ្តោតកាន់តែច្រើនឡើងលើសមិទ្ធកម្ម ទាំងលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយនៃកម្មវិធី។ ទម្ងន់នៃការយកចិត្តទុកដាក់នឹងផ្លាស់ប្តូរជាបណ្តើរៗ ពីការផ្តោតលើធាតុចូលទៅផ្តោតលើលទ្ធផលក្នុងឆ្នាំ នៅឆ្នាំ២០១៩ និងឆ្ពោះទៅផ្តោតលើលទ្ធផលចុងក្រោយ ថែមទៀតចាប់ពីឆ្នាំ២០២១។ បន្ថែមពីលើនេះ «កិច្ចសន្យាសមិទ្ធកម្ម» (performance agreement) រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន នឹងចាប់ផ្តើមដាក់ឱ្យអនុវត្ត ចាប់ពីឆ្នាំ២០១៩តទៅ ដោយឆ្លុះបញ្ចាំងពីលទ្ធផលដែលត្រូវសម្រេចឱ្យបាននៅក្នុងឆ្នាំថវិកា។ កិច្ចសន្យាសមិទ្ធកម្មនេះនឹងត្រូវពង្រីកដាក់បញ្ចូលបន្ថែមលទ្ធផលចុងក្រោយ នៅក្នុងដំណើរការរៀបចំថវិកាឆ្នាំ២០២៣។

នៅក្នុងទិសដៅឆ្ពោះទៅអនុវត្តថវិកាសមិទ្ធកម្មឱ្យបានពេញលេញនៅឆ្នាំ២០២៥ ការពិនិត្យនិងអនុម័តថវិកានឹងត្រូវធ្វើជាជំហានៗ។ នៅឆ្នាំ២០២១ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ នឹងត្រូវរៀបចំដោយមានភ្ជាប់ចំណាយលម្អិតតាមកម្មវិធី និងតាមចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញជាឧបសម្ព័ន្ធ ដើម្បីដាក់ជូនត្រឹមគណៈរដ្ឋមន្ត្រី ពិនិត្យនិងសម្រេចសិន ប៉ុន្តែនៅបន្តដាក់សេចក្តីព្រាងច្បាប់ក្នុងទម្រង់ចាស់ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច ជូនស្ថាប័ននីតិបញ្ញត្តិ

ពិនិត្យនិងអនុម័តមួយឆ្នាំទៀតសិន។ សេចក្តីព្រាងច្បាប់នៅក្នុងទម្រង់និងមាតិកាថ្មី គឺតាមចំណាត់ថ្នាក់កម្មវិធីនិងចំណាត់ថ្នាក់សេដ្ឋកិច្ចបញ្ច្រាញ នឹងត្រូវដាក់ជូនស្ថាប័ននីតិបញ្ញត្តិ ដើម្បីពិនិត្យពិនិស្ស័យ និងសុំការអនុម័តនៅឆ្នាំ២០២២។

ដំណើរការនៃការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនឹងត្រូវបន្ថែមព័ត៌មានសមិទ្ធកម្មជាឧបសម្ព័ន្ធ ចាប់ពីឆ្នាំ២០២២ សម្រាប់ការពិនិត្យនិងសម្រេចនៅគណៈរដ្ឋមន្ត្រី។ ការធ្វើបែបនេះគឺជាការសាកល្បងឱ្យឃើញពីភាពពេញលេញនិងសារប្រយោជន៍ជាមុន ដើម្បីជាមូលដ្ឋានកែលម្អជាប្រចាំ ដោយផ្អែកលើមតិយោបល់ផ្ទៃក្នុងរាជរដ្ឋាភិបាល មុនពេលដាក់ព័ត៌មានសមិទ្ធកម្មជាឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុជូនទៅស្ថាប័ននីតិបញ្ញត្តិដើម្បីពិភាក្សានិងអនុម័តនៅឆ្នាំ២០២៤។

**៤.២.៣ ការអនុវត្តនិងការត្រួតពិនិត្យថវិកា**

ការរៀបចំការធានាចំណាយនិងការទូទាត់នឹងត្រូវពន្លឿននិងលើកកម្ពស់ប្រសិទ្ធភាព តាមរយៈការសម្រួលនីតិវិធីការងារនិងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំនួសឱ្យការប្រើក្រដាសស្នាមយ៉ាងយូរត្រឹមឆ្នាំ២០២៥។ ក្នុងទិសដៅនេះ ប្រព័ន្ធ FMIS តាមអភិក្រមបច្ចុប្បន្ន ត្រូវបានពង្រីកដាក់ឱ្យអនុវត្តនៅក្រសួង ស្ថាប័ន ចំនួន១០នៅក្នុងឆ្នាំ២០១៧ និងបន្តពង្រីកដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ននៅឆ្នាំ២០២០ មុនពេលចាប់ផ្តើមអនុវត្តស្វ័យប្រវត្តិកម្មពេញលេញតាមប្រព័ន្ធ FMIS។

គោលការណ៍ណែនាំស្តីពីនីតិវិធីចំណាយនិងបែបបទនៃការត្រួតពិនិត្យហិរញ្ញវត្ថុដែលមានបច្ចុប្បន្ន ជាពិសេសអនុក្រឹត្យលេខ៨១និងអនុក្រឹត្យលេខ៨២ ដូចគូសបញ្ជាក់ក្នុងជំពូកទី៣ ព្រមទាំងបទដ្ឋានគតិយុត្តជាមូលដ្ឋានពាក់ព័ន្ធនានា នឹងត្រូវកែលម្អ ដើម្បីរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងសាមញ្ញមួយ ព្រមទាំងនីតិវិធីការងារដែលកំណត់មុខងារ តួនាទី និងភារកិច្ចឱ្យច្បាស់លាស់រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការងារនេះនឹងចាប់ផ្តើមក្នុងឆ្នាំ២០១៨ និងដាក់ឱ្យអនុវត្តពេញលេញនៅឆ្នាំ២០២២។ នៅឆ្នាំ២០២៥ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងនឹងត្រូវរៀបចំសាជាថ្មី ដោយដាក់បញ្ចូលទៅក្នុងប្រព័ន្ធFMIS ឱ្យមានមុខងារត្រួតពិនិត្យនិងតាមដាន។

យន្តការគ្រប់គ្រងការអនុវត្តថវិការដ្ឋបាលកណ្តាល ក្រោមចំណុះផ្ទាល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម ដោយដាក់ឱ្យនៅអមក្រសួង ស្ថាប័ន នឹងចាប់ផ្តើមដាក់ឱ្យអនុវត្តសាកល្បងនិងពង្រីកជាបណ្តើរៗចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥។

**៤.២.៤ កិច្ចលទ្ធកម្ម**

ក្នុងគោលបំណងពន្លឿននិងសម្រួលនីតិវិធីការងារ ស្របតាមទិសដៅយុទ្ធសាស្ត្រដែលបានកំណត់ក្នុងជំពូកទី៣ ការប្រគល់សិទ្ធិសម្រេចនិងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មនឹងត្រូវបង្កើនជាបណ្តើរៗបន្ថែមទៀត ជូនក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈប្រហាក់ប្រហែល ទន្ទឹមនឹងការពង្រឹងសវនកម្មលទ្ធកម្ម ដើម្បីឈានទៅផ្តល់ឱ្យសិទ្ធិអំណាចនិងការទទួលខុសត្រូវពេញលេញ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់នៅឆ្នាំ២០២៥។

ក្នុងន័យនេះ មុខងារលទ្ធកម្មដែលជាផ្នែកនៃយន្តការគ្រប់គ្រងការអនុវត្តថវិកា ដូចបានកំណត់ក្នុងជំពូក៣ នឹងចាប់ផ្តើមដាក់ឱ្យអនុវត្តសាកល្បងនិងពង្រីកជាបណ្តើរៗ ចាប់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនឹងត្រូវរៀបចំដោយឡែក ដោយផ្អែកលើក្របខ័ណ្ឌនិងទិសដៅខាងលើ។

**៤.២.៥ ការត្រួតពិនិត្យការបើកផ្តល់**

នីតិវិធីត្រួតពិនិត្យការបើកផ្តល់នឹងត្រូវបង្រួមនិងពន្លឿនទាំងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងនៅតាមក្រសួង ស្ថាប័នចាប់ពីឆ្នាំ២០១៨តទៅ ដើម្បីឈានទៅអនុវត្តស្វ័យប្រវត្តិកម្មតាមប្រព័ន្ធFMIS នៅឆ្នាំ២០២៥។ ក្រសួង ស្ថាប័ននឹងតម្រូវឱ្យរៀបចំផែនការប្រតិបត្តិការថវិកា ដោយចាប់ផ្តើមពីឆ្នាំ២០២២ ដើម្បីធ្វើជាមគ្គុទ្ទេសក៍ក៏ដូចជាសម្រាប់អនុវត្តថវិកាដែលបានអនុម័ត ហើយដែលឧបករណ៍នេះនឹងក្លាយទៅជាលក្ខខណ្ឌគតិយុត្តចាប់ពីឆ្នាំ២០២៥តទៅ។ នៅពេលនោះ ការគ្រប់គ្រងសាច់ប្រាក់ អាណត្តិបើកប្រាក់ និងឯកសារលិខិតយុត្តការភ្ជាប់នឹងអាចគ្រប់គ្រង និងត្រួតពិនិត្យតាមរយៈប្រព័ន្ធFMIS សម្រាប់ជាមូលដ្ឋាននៃការបើកផ្តល់តាមបែបអេឡិចត្រូនិក។

**៤.២.៦ ការតាមដាននិងការវាយតម្លៃ**

ក្របខ័ណ្ឌនិងនីតិវិធីច្បាស់លាស់មួយនឹងត្រូវបង្កើតឱ្យមានឡើងសម្រាប់ការតាមដាននិងរបាយការណ៍ផ្នែកហិរញ្ញវត្ថុនិងផ្នែកសមិទ្ធកម្ម។ ការងារនេះនឹងត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ២០១៨ និងត្រូវបញ្ចប់នៅឆ្នាំ២០២០។ របាយការណ៍ហិរញ្ញវត្ថុទៀងទាត់ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើស្តង់ដាគណនេយ្យបច្ចុប្បន្ននឹងក្លាយជាលក្ខខណ្ឌគតិយុត្តចាប់ពីឆ្នាំ២០២១តទៅ និងរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើសាច់ប្រាក់កែសម្រួលតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ(Modified Cash-IPSAS) នឹងចាប់ផ្តើមនៅឆ្នាំ២០២៥។ចំពោះការតាមដាន និងការរាយការណ៍សមិទ្ធកម្ម ក្រសួង ស្ថាប័ននឹងតម្រូវឱ្យធ្វើរបាយការណ៍តាមសូចនាករសមិទ្ធកម្មគន្លឹះៗ (KPIs) ប្រចាំត្រីមាសនិងប្រចាំឆ្នាំនៅឆ្នាំ២០២២។

ក្របខ័ណ្ឌតាមដាននិងវាយតម្លៃជាសារវន្តមួយនឹងត្រូវរៀបចំចាប់ពីឆ្នាំ២០១៩ និងដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២៣។ ក្រសួងស្ថាប័ន អាចវាយតម្លៃកម្មវិធីរបស់ខ្លួននៅពាក់កណ្តាលឆ្នាំនីមួយៗ ដោយផ្អែកលើរបាយការណ៍និងការពិភាក្សាផ្ទៃក្នុងតាមការចាំបាច់។ ក្របខ័ណ្ឌសារវន្តនេះនឹងវិវត្តបន្តិចម្តងៗទៅជាប្រព័ន្ធតាមដាននិងវាយតម្លៃពេញលេញ នៅក្រោយឆ្នាំ២០២៥។

**៤.២.៧ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់**

- *ក្របខ័ណ្ឌគតិយុត្តនៃថវិកា*

ការសិក្សាពិនិត្យឡើងវិញគ្រប់ទិដ្ឋភាពនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨នឹងចាប់ធ្វើនៅឆ្នាំ២០១៨ ដោយទុកពេលវេលាឱ្យបានគ្រប់គ្រាន់ សម្រាប់បញ្ចប់ការងារត្រៀមរៀបចំជាមុនសិន មុនពេលដាក់ច្បាប់វិសោធនកម្មសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិពិនិត្យនិងអនុម័ត ក្នុងឆ្នាំ២០២០។ នៅក្នុងក្របខ័ណ្ឌនៃការធ្វើវិសោធនកម្មនេះ ប្រតិទិននៃកិច្ចដំណើរការរៀបចំថវិកាទាំងមូល ចាប់តាំងពីការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមនិងក្របខ័ណ្ឌថវិការយៈពេលមធ្យម ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ ការចរចាថវិកា ការវេចខ្ចប់ និងការដាក់ទៅគណៈរដ្ឋមន្ត្រី រហូតដល់ការដាក់សុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នឹងត្រូវពិនិត្យ និង

កែសម្រួល តាមការចាំបាច់ ដើម្បីឱ្យដំណើរការនៃការរៀបចំ និងអនុម័តថវិកា មានពេលវេលាគ្រប់គ្រាន់សម្រាប់ដំណាក់កាលនីមួយៗ។

- *ក្របខ័ណ្ឌគណនេយ្យភាព*

ក្នុងពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងបោះជំហានទៅមុខឆ្ពោះទៅរកគណនេយ្យសមិទ្ធកម្ម សវនកម្មផ្ទៃក្នុងនិងសវនកម្មសមិទ្ធកម្មនឹងដើរតួនាទីសំខាន់ ដើម្បីតម្រង់ទិសទៅកាន់ការវាយតម្លៃសមិទ្ធកម្មក្នុងការផ្តល់សេវានិងសមិទ្ធកម្មរបស់អង្គភាពថវិកា។ ក្នុងទិសដៅនេះ គោលការណ៍ណែនាំនិងនីតិវិធីការងារសវនកម្មសមិទ្ធកម្មនឹងត្រូវដាក់បញ្ចូលក្នុងក្របខ័ណ្ឌសវនកម្មផ្ទៃក្នុងត្រឹមឆ្នាំ២០២១។ ដោយឡែក ការធ្វើសវនកម្មសមិទ្ធកម្មឯករាជ្យជាបណ្តើរៗ នឹងក្លាយជាការងារចម្បងមួយទៀតរបស់អាជ្ញាធរសវនកម្មជាតិ។

## ៤.៣. ក្របខ័ណ្ឌពេលវេលានិងអភិក្រមអនុវត្ត

ផ្អែកតាមផែនទីចង្អុលផ្លូវតាមដំណាក់កាលនីមួយៗ ដែលបានកំណត់ពីខាងលើ ក្របខ័ណ្ឌពេលវេលានៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកានេះ ត្រូវបានបែងចែកជាពីរដំណាក់កាលធំៗ គឺដំណាក់កាលទី១ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២១ ដែលផ្តោតលើការកសាងមូលដ្ឋានចាំបាច់សម្រាប់ការចាប់ផ្តើមអនុវត្តថវិកាសមិទ្ធកម្មនិងដំណាក់កាលទី២ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ ដែលផ្តោតលើការអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម ដើម្បីឈានទៅអនុវត្តពេញលេញនូវប្រព័ន្ធថវិកាសមិទ្ធកម្មក្រោយឆ្នាំ២០២៥។ តាមទិសដៅនេះ ការកែទម្រង់ប្រព័ន្ធថវិកាគឺមានសង្គតិភាពពេលវេលាស្របទៅតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣(២០១៦-២០២០) គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងដំណាក់កាលទី៤(២០២១-២០២៥) គឺគណនេយ្យភាពសមិទ្ធកម្ម។

ដូចគ្នានឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែរ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ នឹងប្រើប្រាស់អភិក្រម "គ្រឿងបង្គុំ" ដោយធ្វើការកែទម្រង់សមាសធាតុគន្លឹះនីមួយៗក្នុងពេលដំណាលគ្នា ប៉ុន្តែមួយដំណាក់ម្តងៗ ដោយឈរលើលទ្ធផលដែលសម្រេចបានពីការអនុវត្តកន្លងមក ទន្ទឹមគ្នានឹងការត្រៀមរៀបចំមូលដ្ឋានគ្រឹះសម្រាប់ដំណាក់កាលបន្ទាប់។ ស្របតាមអភិក្រមនេះ ផែនទីចង្អុលផ្លូវលម្អិត ដែលបង្ហាញពីលំដាប់លំដោយនៃការងារកែទម្រង់ និងសកម្មភាពដែលនាំទៅដល់គោលដៅចុងក្រោយ មានលម្អិតនៅក្នុងឧបសម្ព័ន្ធ៣។

ដើម្បីប្រែក្លាយផែនទីចង្អុលផ្លូវនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ឱ្យទៅជាការអនុវត្តជាក់ស្តែង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទត្រូវរៀបចំផែនការសកម្មភាពជាក់លាក់ ទៅតាមពេលវេលាកំណត់ ដើម្បីអនុវត្តក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពរួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងដើរតួនាទីជាអ្នកត្រួតពិនិត្យវឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធថវិកា។ អគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ នឹងតាមដានការអនុវត្ត និងសម្របសម្រួលការអនុវត្តការកែទម្រង់ប្រព័ន្ធថវិកានិងការកែទម្រង់ដទៃទៀត។

## ៤.៤. ការវិភាគហានិភ័យ

ដោយសារការកែទម្រង់ថវិកាមានភាពទូលំទូលាយ ជាប់ជំពាក់នឹងការកែទម្រង់ផ្សេងៗច្រើននិងមានមុខសញ្ញាច្រើន ការអនុវត្តការងារកែទម្រង់អាចជួបហានិភ័យឬការពន្យារពេលក្នុងការអនុវត្ត។ មានកត្តាជាច្រើនដែលចូលរួមចំណែកធ្វើឱ្យហានិភ័យនេះកើតមានឡើង ដោយសារការងារកែទម្រង់ណាមួយនៃហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ក៏ដូចជាការកែទម្រង់មួយចំនួនទៀតនៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ត្រូវបានពន្យារពេលជាយថាហេតុដែលនាំឱ្យការកែទម្រង់ប្រព័ន្ធថវិកាត្រូវបានពន្យារពេលទៅតាមនោះដែរ។ ក្នុងន័យនេះ ការកែទម្រង់មួយចំនួនរួមមាន ការកៀរគរចំណូល ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងវិហ្វរសាច់ប្រាក់ ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ចាំបាច់ត្រូវតម្រឹមបន្ស៊ី និងប្រទាក់ក្រឡាគ្នា ពីព្រោះថា កិច្ចការទាំងនេះមានសារៈសំខាន់ក្នុងការសម្រេចបានជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា។

រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការកែទម្រង់ក្នុងវិស័យសំខាន់ៗផ្សេងទៀត ដែលនៅក្រៅអាណត្តិកិច្ចឬក្រៅដែនសមត្ថកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការដ្ឋានកែទម្រង់ទាំងនោះ មានដូចជា ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការកែទម្រង់សវនកម្មជាដើម នឹងមានបច្ច័យដល់ភាពជោគជ័យឬបរាជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា(សូមពិនិត្យមើលឧបសម្ព័ន្ធ២ ស្តីពីការកែទម្រង់សំខាន់ៗដែលមានភាពប្រទាក់ក្រឡាគ្នាជាមួយនឹងការកែទម្រង់ប្រព័ន្ធថវិកា)។ ការពន្យារឬពន្យឺតណាមួយនៃការដ្ឋានកែទម្រង់ទាំងនោះ នឹងធ្វើឱ្យថមថយប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធថវិកា។ បញ្ហានេះអាចបញ្ចៀសបាន ប្រសិនជាមានកិច្ចសហការនិងសម្របសម្រួលក្នុងចំណោមក្រសួង ស្ថាប័នដែលទទួលខុសត្រូវការដ្ឋាននីមួយៗ។

ការបោះឆ្នោតនៅឆ្នាំ២០១៨ គឺជារបត់នយោបាយមួយដែលនឹងធ្វើឱ្យការកែទម្រង់អាចនឹងទច់ដំណើរ ដោយសារកត្តាអត្តនោម័តនិងកត្តាសត្យានុម័តមួយចំនួន ជាពិសេស កត្តាសតិអារម្មណ៍បុគ្គលនិងកត្តាសម្ពាធពេលវេលា ហើយលើសពីនេះទៀត ការផ្លាស់ប្តូរជាយថាហេតុដែលកើតមានឡើងនៅក្រោយការបោះឆ្នោតនៃថ្នាក់ដឹកនាំក្រសួង ស្ថាប័ន មន្ត្រីជាន់ខ្ពស់ និងជំនាញពាក់ព័ន្ធមួយចំនួន គឺជាឧបសគ្គចម្បងដែលធ្វើឱ្យការកែទម្រង់មិនអាចប្រព្រឹត្តទៅបានតាមការរំពឹងទុក។

ការកែទម្រង់នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេស ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងឱ្យស៊ីចង្វាក់ទៅតាមរចនាសម្ព័ន្ធកម្មវិធី គឺជាកត្តាសំខាន់បំផុតមួយ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាសមិទ្ធកម្ម។ ការពន្យារពេលឬការរំអក់នៅក្នុងកិច្ចការនេះដោយសារការខ្វះសុឆន្ទៈ នឹងធ្វើឱ្យប៉ះពាល់ដល់ការសម្រេចគោលដៅនៃការកែទម្រង់ប្រព័ន្ធថវិកា។

ប្រសិទ្ធភាពនិងភាពគ្រប់ជ្រុងជ្រោយនៃកម្មវិធីកសាងសមត្ថភាពនិងប្រសិទ្ធភាពនៃកម្មវិធីគ្រប់គ្រង ការផ្លាស់ប្តូរនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ គឺស្ថិតក្នុងចំណោមកិច្ចការចាំបាច់បំផុត ដើម្បីបង្ការនិងដោះស្រាយនូវហានិភ័យខាងលើ។ ដូចនេះ ចាំបាច់ត្រូវមានការតាមដានឱ្យបានដិតដល់នៃកម្មវិធីទាំងពីរនេះ។ ទន្ទឹមនឹងនេះដែរ ចាំបាច់

ត្រូវមានការទទួលខុសត្រូវរួមក្នុងការអនុវត្ត ការសម្របសម្រួល និងតាមដានការងារកែទម្រង់ប្រព័ន្ធថវិកាដូចមានក្នុងផែនទីចង្អុលផ្លូវនឹងត្រូវធ្វើឡើងតាមរយៈ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការកំណត់ហានិភ័យទាំងអស់និងវិធានការដើម្បីសម្រាលហានិភ័យទាំងនេះនឹងត្រូវរៀបចំនៅក្នុងផែនការសកម្មភាពលម្អិត។ ការតាមដាននិងការធ្វើរបាយការណ៍ទៀងទាត់ពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាមានសារៈសំខាន់ណាស់។ ការងារនេះនឹងត្រូវតាមដានដោយជិតដល់និងត្រូវដោះស្រាយនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងនៅពេលធ្វើការសិក្សាពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

៙៙☸៚៚

# ជំពូកទី៥
## សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល១៣ឆ្នាំកន្លងមកនេះ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទទួលបានលទ្ធផលគួរជាទីពេញចិត្ត ជាពិសេស សម្រេចបានជាសារវន្តនូវការកែទម្រង់ជំហានទី១និងជំហានទី២ ព្រមទាំងមានវឌ្ឍនភាពល្អក្នុងការអនុវត្តជំហានទី៣។ សមិទ្ធផលដែលសម្រេចបានមកដល់ពេលនេះ គឺដោយសារការចូលរួមយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវក្នុងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន ព្រមទាំងមានការគាំទ្រជាប្រចាំ និងការប្តេជ្ញាចិត្តឥតងាករេពីថ្នាក់ដឹកនាំ និងស្ថាបនិកគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា។

បន្ទាប់ពីត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅឆ្នាំ២០០៤ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាមានវឌ្ឍនភាពយឺតក្នុងដំណើរព្យាសកម្មរយៈពេលពីរឬបីឆ្នាំដំបូង ដោយសារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវការពេលវេលាក្នុងការស្រូបយកទស្សនៈ និងចំណេះដឹងថ្មីៗ ត្រូវការការសិក្សាពីប្រព័ន្ធថ្មីស្របទៅតាមដំណើរវិវត្តនៃឧត្តមានុវត្តអន្តរជាតិ ដកស្រង់បទពិសោធជាក់ស្តែងពីការអនុវត្តខ្លួនឯងផ្ទាល់និងពីប្រទេសនានាដែលបោះជំហានមុនកម្ពុជា និងថ្លឹងថ្លែងឱ្យត្រូវនឹងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ ព្រមទាំងកំណត់ចក្ខុវិស័យឱ្យកាន់តែច្បាស់លាស់។ បន្ទាប់មក ការកែទម្រង់បានបោះជំហានទៅមុខកាន់តែលឿនឡើង ជាពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារបុរេលក្ខខណ្ឌនានាសម្រាប់ការអនុវត្តកម្មវិធី ដែលជាសមាសធាតុស្នូលនៃជំហានទី៣ ត្រូវបានត្រៀមរៀបចំរួចរាល់ជាសារវន្តនិងកំពុងមានវឌ្ឍនភាពក្នុងការធ្វើស្ថាប័ននីយកម្ម។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នកាន់តែយល់ជ្រួតជ្រាបនិងសម្របខ្លួនទៅនឹងទស្សនៈនិងគំនិតថ្មីៗ ជាពិសេស ទទួលស្គាល់ពីសារៈសំខាន់នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

នៅក្រោមចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ដោយប្រែក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចចាត់ទុកជាកត្តាកំណត់មួយ ហើយការកែទម្រង់ប្រព័ន្ធថវិកាគឺជាឧបករណ៍គន្លឹះ ដើម្បីអាចសម្រេចបាននូវចក្ខុវិស័យនោះ។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងនៅតែបន្តជាការដ្ឋានកែទម្រង់មួយដ៏មានសារៈសំខាន់និងមុតស្រួច ក្នុងការឈានឆ្ពោះទៅសម្រេចជំហានទី៤នៅឆ្នាំ២០២៥។

ទោះជាយ៉ាងនេះក្តី ទៅមុខទៀត ការកែទម្រង់ប្រព័ន្ធថវិកាអាចនឹងជួបបញ្ហាប្រឈមចម្បងៗមួយចំនួន គឺ ១)- របៀបវារៈនៃការកែទម្រង់ត្រូវបានកំណត់ដោយសុទិដ្ឋិនិយមពេកនិងមិនប្រាកដនិយម ហើយការយល់អំពីគុណតម្លៃនៃគោលបំណងនិងមាគ៌ាឆ្ពោះទៅសម្រេចគោលដៅនៃតួអង្គពាក់ព័ន្ធនៅមានកម្រិត ២)- ជំហានមិនសូវស៊ីចង្វាក់ល្អ និងក្នុងល្បឿនខុសគ្នានៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ ជាមួយនឹងការកែទម្រង់ធំៗ ដែលមានការពាក់ព័ន្ធនិងប្រទាក់ក្រឡាផ្សេងទៀត ៣)- ការកសាងធនធានមនុស្សនិងសមត្ថភាពស្ថាប័នមិនទាន់មានវឌ្ឍនភាពសមាមាត្រទៅនឹងកិច្ចការកែទម្រង់ដែលកំពុងពេញល្បឿន ដោយសារកិច្ចការនេះត្រូវការពេលវេលាយូរ ធនធានច្រើន និងឆន្ទៈរួម

នៃតួអង្គពាក់ព័ន្ធ ជាពិសេស ថ្នាក់ដឹកនាំគ្រប់កម្រិតនៃក្រសួង ស្ថាប័ន និង ៤)- ដំណើរការកែទម្រង់មានលក្ខណៈជីវភាព ដោយសារឧត្តមានុវត្តអន្តរជាតិមានការវិវត្តទៅក្នុងបរិការណ៍សាកលលោកដែលមានការប្រែប្រួលជាប្រចាំ។

ដោយសារបញ្ហាប្រឈមខាងលើ គោលដៅនៃការកែទម្រង់ឆ្ពោះទៅ**«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»** ដែលបានកំណត់នៅក្នុងឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ នឹងមិនអាចសម្រេចបាននៅឆ្នាំ២០២០ទេ។ ដូចនេះ ដោយផ្អែកលើការសិក្សាពីឧត្តមានុវត្តអន្តរជាតិនិងការអនុវត្តនៅប្រទេសដែលបានសិក្សាដកពិសោធ ជាពិសេស បទពិសោធនៃការអនុវត្តជាក់ស្តែងរបស់ខ្លួនផ្ទាល់ កម្ពុជាសម្រេចកែសម្រួលទិសដៅនៃការកែទម្រង់ ទៅជា **«ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម»** ដែលក្នុងឯកសារនេះហៅថា **«ថវិកាសមិទ្ធកម្ម»**។

ឯកសារនេះកំណត់បាននូវក្របខ័ណ្ឌយុទ្ធសាស្ត្រនិងផែនទីចង្អុលផ្លូវ ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនៃថវិកាសមិទ្ធកម្មដែលផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមជាមួយនឹងគណនេយ្យភាពសមិទ្ធកម្មនៅឆ្នាំ២០២៥។ ដោយឈរលើលទ្ធផលដែលសម្រេចបាននៅដំណាក់កាលទី១ ដំណាក់កាលទី២និងវឌ្ឍនភាពនៃដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងទិសដៅឆ្ពោះទៅសម្រេចជោគជ័យជំហានទី៤ គឺគណនេយ្យភាពសមិទ្ធកម្ម ក្របខ័ណ្ឌយុទ្ធសាស្ត្រ នេះផ្តោតលើសមាសធាតុគន្លឹះចំនួនបួននៃប្រព័ន្ធថវិកា រួមមាន ១)- ការធ្វើផែនការកម្រិតយុទ្ធសាស្ត្រដែលជាផែនការថវិការយៈពេលមធ្យមមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងសមាហរណកម្ម និងមានក្របខ័ណ្ឌគ្រប់គ្រងហានិភ័យច្បាស់លាស់ ២)- ការរៀបចំថវិកានិងការអនុម័តថវិកាប្រចាំឆ្នាំ ដោយផ្តោតទៅលើកម្មវិធីនិងគោលបំណងរបស់កម្មវិធី ៣)- ការអនុវត្តនិងការត្រួតពិនិត្យថវិកាដែលនឹងត្រូវពន្លឿននិងធ្វើទំនើបកម្មតាមរយៈការកាត់បន្ថយនីតិវិធីអនុវត្តនិងប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង៤)- ការតាមដាននិងវាយតម្លៃដោយផ្អែកលើក្របខ័ណ្ឌជាសារវន្ត សម្រាប់ការរៀបចំរបាយការណ៍ទាន់ពេលវេលា ត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ហើយជាបណ្តើរៗ នឹងឈានទៅរកប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានមុខងារពេញលេញ។

យុទ្ធសាស្ត្រនេះកំណត់ថា ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវធ្វើតាមរបៀបដូចគ្នាទៅនឹងប្រព័ន្ធថវិកាជាតិ ដោយសារមានគោលបំណងរួមតែមួយ គឺការសម្រេចបាននូវអាទិភាពនិងសមិទ្ធផលជាតិ។ ដូច្នេះប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគោលការណ៍ ក្របខ័ណ្ឌ និងអភិក្រមដែលមានសង្គតិភាពខ្ពស់ ជាមួយនឹងប្រព័ន្ធថវិកាជាតិ។ យុទ្ធសាស្ត្រនេះបានកំណត់នូវចំណុចសំខាន់ដែលត្រូវតម្រង់តម្រឹមនិងធ្វើសុខដុមនីយកម្មនឹងគ្នានៅក្នុងការធ្វើផែនការយុទ្ធសាស្ត្រនិងក្នុងវដ្តថវិកា មានដូចជាការរៀបចំ ការអនុម័ត ការអនុវត្ត និងត្រួតពិនិត្យនិងការតាមដាននិងវាយតម្លៃ។ ទាំងនេះគឺជាក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនទីចង្អុលផ្លូវដែលមានក្របខ័ណ្ឌពេលវេលាច្បាស់លាស់ ត្រូវបានរៀបចំឡើងដោយដាក់ចេញនូវសកម្មភាពកែទម្រង់តាមអភិក្រមសាមញ្ញ ជាក់ស្តែង តាមលំដាប់លំដោយ ដើម្បីសម្រេចបានគោលបំណងនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា និងការអនុវត្តត្រូវបានបែងចែកជាពីរដំណាក់កាលធំៗ គឺដំណាក់កាលទី១ពីឆ្នាំ២០១៨ដល់

ឆ្នាំ២០២១ គឺការសម្រេចបានជាសារវន្តនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងដំណាក់កាលទី២ពីឆ្នាំ ២០២២-២០២៥ គឺការសម្រេចបានប្រព័ន្ធថវិកាសមិទ្ធកម្មដែលមានសង្គតិភាពទៅនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣និងទី៤។

ជារួម យុទ្ធសាស្ត្រនេះបានដាក់ចេញគោលដៅដែលនៅតែមានមហិច្ឆតាខ្ពស់ និងបានកំណត់ឃើញនូវហានិភ័យសំខាន់ៗមួយចំនួន ដែលអាចជួបប្រទះនៅក្នុងពេលអនុវត្ត។ ទោះយ៉ាងនេះក្តី កម្ពុជាចាំបាច់ត្រូវពុះពារសម្រេចឱ្យបាននូវគោលដៅទាំងនោះជាសារវន្ត ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍កម្ពុជាដែលកំពុងឈានដល់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ក៏ដូចជា និន្នាការថ្មីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអន្តរជាតិ។

ភាពជាអ្នកដឹកនាំនិងភាពជាម្ចាស់នៃតួអង្គពាក់ព័ន្ធ ជាមួយនឹងការរួមវិភាគទានផ្នែកចំណេះដឹងដ៏មានតម្លៃពីដៃគូអភិវឌ្ឍ គឺជាកត្តាគន្លឹះក្នុងការធានាឱ្យបានជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា។ លើសពីនេះ ការគាំទ្រយ៉ាងមុតមាំនិងការណែនាំជាប្រចាំ ពីសំណាក់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមេបញ្ជាការតែមួយ ធ្លាប់បានធ្វើឱ្យការកែទម្រង់ហិរញ្ញវត្ថុសាធារណៈទទួលបានជោគជ័យគួរជាទីមោទនៈ និងកំពុងបន្តមានសន្ទុះទៅមុខ គឺជាកត្តាមិនអាចខ្វះបាន ដើម្បីផ្តល់ក្តីសង្ឃឹមដល់កម្ពុជាក្នុងការកែទម្រង់ប្រព័ន្ធថវិកា ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ឆ្ពោះទៅសម្រេចគោលដៅឆ្នាំ២០២៥ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ៕

## ឧបសម្ព័ន្ធទី១ : បទពិសោធអន្តរជាតិអំពីថវិកាសមិទ្ធកម្ម

**យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥** គឺជាឯកសារយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាក្នុងរយៈពេលវែង។ ជាគោលការណ៍ ការកែទម្រង់ប្រព័ន្ធថវិកាពុំមានបទដ្ឋានរួមតែមួយច្បាស់លាស់ឡើយ ពីព្រោះប្រទេសនីមួយៗធ្វើការកែទម្រង់ដោយផ្អែកជាសំខាន់ទៅតាមបរិការណ៍ប្រវត្តិសាស្ត្រ នយោបាយ និងស្ថាប័នរៀងៗខ្លួន។ ទោះជាយ៉ាងនេះក្តី ដើម្បីឱ្យការកែទម្រង់កាន់តែមានភាពជាក់ស្តែង និងប្រាកដនិយម ការរៀបចំឯកសារយុទ្ធសាស្ត្រនេះបានធ្វើឡើងដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើឧត្តមានុវត្តអន្តរជាតិ ជាពិសេស ការអនុវត្តជារួមនៅប្រទេសជឿនលឿនដែលជាសមាជិកOECDនិងការអនុវត្តដោយឡែកនៅប្រទេសស៊ុយអែត និងប្រទេសបារាំង ដែលមានប្រព័ន្ធថវិកាជឿនលឿនតាមម៉ូដែលពីរផ្សេងគ្នា និងប្រទេសក្នុងតំបន់គឺប្រទេសថៃនិងប្រទេសម៉ាឡេស៊ី ដែលបានឆ្លងកាត់ការកែទម្រង់ប្រព័ន្ធថវិកានិងអនុវត្តថវិកាសមិទ្ធកម្មមុនកម្ពុជា។

### ១.១. ប្រទេសសមាជិកអង្គការOECD

យោងតាមឯកសាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ប្រទេសសមាជិកOECD ស្ទើរទាំងអស់បានកសាងនិងប្រើប្រាស់សូចនាករសមិទ្ធកម្ម ហើយប្រទេសជាច្រើនខិតខំធ្វើសមាហរណកម្មព័ត៌មានសមិទ្ធកម្មចូលទៅក្នុងដំណើរការថវិកា។ ជាក់ស្តែង ចំនួន៦៧%នៃប្រទេសOECDសរុប ប្រើសូចនាករសមិទ្ធកម្មធៀបនឹងគោលដៅនៅក្នុងពេលចរចារកញ្ចប់ថវិកា ប៉ុន្តែមិនគ្រប់ក្រសួង ស្ថាប័នទេ។ ប្រទេសចំនួនប្រាំបីប្រើសូចនាករសមិទ្ធកម្មលើក្រសួង ស្ថាប័នជាង៨០% ហើយប្រទេសចំនួនប្រាំមួយផ្សេងទៀត ប្រើសូចនាករសមិទ្ធកម្មលើក្រសួង ស្ថាប័នតិចជាង២០%។ ចំនួន៦៧%នៃប្រទេសOECD ប្រើប្រាស់របាយការណ៍វាយតម្លៃសមិទ្ធកម្មជាមូលដ្ឋានសម្រាប់ការចរចាថវិកា ក្នុងនោះមានប្រទេសចំនួនប្រាំមួយបានប្រើរបាយការណ៍នេះលើក្រសួង ស្ថាប័នជាង៨០% ហើយមានប្រទេសប្រាំពីរផ្សេងទៀតប្រើរបាយការណ៍នេះដែរ លើក្រសួង ស្ថាប័នតិចជាង២០%។

ប្រទេសសមាជិកOECD មានប្រវត្តិដ៏យូរអង្វែងក្នុងការវាយតម្លៃកម្មវិធីនិងគោលនយោបាយ។ ក្រសួង ស្ថាប័ននីមួយៗភាគច្រើនបានប្រើប្រាស់ព័ត៌មានពីការវាយតម្លៃនេះ សម្រាប់គ្រប់គ្រងកម្មវិធី សម្រាប់កំណត់គោលដៅឆ្នាំបន្ទាប់ សម្រាប់ធ្វើយុត្តិកម្មនៃការវិភាជថវិកា ឬសម្រាប់ផ្លាស់ប្តូរកម្មវិធី និងកាត់បន្ថយចំណាយក្នុងករណីមួយចំនួនតូច។ នៅក្នុងប្រទេសដែលមានស្ថាប័នកណ្តាលទទួលបន្ទុកថវិកា ព័ត៌មាននៃការវាយតម្លៃភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងចំណាយ ការផ្លាស់ប្តូរកម្មវិធី ឬការវិភាជឡើងវិញនូវធនធានពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីក្រសួង ស្ថាប័នមួយទៅក្រសួង ស្ថាប័នមួយទៀត។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងនោះទទួលស្គាល់ថា ការប្រើប្រាស់សូចនាករសមិទ្ធកម្មក្នុងការរៀបចំថវិកានៅតែជួបប្រទះបញ្ហាប្រឈមជាច្រើន ហើយកត្តានយោបាយនៅតែដើរតួនាទីគន្លឹះមួយ។

### ១.២. ប្រទេសស៊ុយអែត

នៅដើមទសវត្សទី៩នៃសតវត្សទី២០ ប្រទេសស៊ុយអែតមានអតិរេកថវិកាខ្ពស់ជាងគេ ក្នុងចំណោមប្រទេសសមាជិកOECD ទាំងអស់។ ប៉ុន្តែពីឆ្នាំ១៩៩៣ដល់ឆ្នាំ១៩៩៥ ប្រទេសនេះបានជួបវិបត្តិសេដ្ឋកិច្ចដ៏ជ្រាលជ្រៅនិងជួបប្រទះនូវឱនភាពថវិកាដ៏ធំបំផុតមិនធ្លាប់មាន។ ដើម្បីដោះស្រាយវិបត្តិនេះ សភានៃប្រទេសស៊ុយអែតបានបង្កើតគណៈកម្មការស៊ើបអង្កេតស្រាវជ្រាវមួយ ហើយនៅចុងទសវត្សទី១០នៃសតវត្សទី២០ បានចាប់ផ្តើមការងារកែទម្រង់ថវិកាទ្រង់ទ្រាយធំ រហូតសម្រេចបានតុល្យភាពថវិកាជាតិឡើងវិញ។

ជាគុតគន្លឹះនៃការកែទម្រង់ រួមមាន ការអនុម័តក្របខ័ណ្ឌថវិកាពហុឆ្នាំ ដំណើរការរៀបចំថវិកាពីលើចុះក្រោមការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅថ្នាក់ក្រោម និងការពង្រឹងវិន័យថវិកា តាមរយៈការដាក់ចេញកញ្ចប់ថវិកាសរុបសម្រាប់វិស័យចំណាយធំៗ។ ប្រព័ន្ធថវិកាថ្មីនៅប្រទេសស៊ុយអែតចែកជាបីកម្រិតគឺ ទី១- ការរៀបចំគោលបំណងគោលនយោបាយហិរញ្ញវត្ថុសាធារណៈលើមូលដ្ឋានក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ទី២- ការកំណត់ទំហំចំណាយសរុបអតិបរមាសម្រាប់គោលបំណងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដោយផ្អែកលើសម្មតិកម្មសេដ្ឋកិច្ច ទី៣- ការបែងចែកថវិកាទៅតាមកញ្ចប់នីមួយៗនៃវិស័យចំណាយចំនួន២៧។ ចំណុចគន្លឹះមួយទៀតនៃប្រព័ន្ធថវិកាថ្មីនេះ គឺការរៀបចំថវិកាត្រូវធានាឱ្យបាននូវអតិរេក ដែលកំណត់ឡើងដោយច្បាប់ នៅក្នុងវដ្តនៃថវិកានីមួយៗ។

ប្រទេសស៊ុយអែតអនុវត្តដោយតឹងរ៉ឹងនូវដំណើរការរៀបចំថវិកាពីលើចុះក្រោម។ គណៈរដ្ឋមន្ត្រីពិចារណាលើសំណើថវិកាពីក្រសួងទាំងអស់ ហើយអនុម័តរួមគ្នាលើចំណាយសរុបប្រចាំឆ្នាំ និងសម្រាប់រយៈពេលពីរឆ្នាំទៅមុខទៀត ដោយញែកទៅតាមកញ្ចប់វិស័យចំណាយទាំង២៧ ក្នុងរង្វង់នៃថវិកាសរុបដែលបានអនុម័តនេះ។ មុនថ្ងៃទី១៥ ខែមេសា ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលដាក់សេចក្តីព្រាងច្បាប់ស្តីពីគោលនយោបាយហិរញ្ញវត្ថុសាធារណៈនិទាឃរដូវ (Spring Fiscal Policy Bill) ទៅរដ្ឋសភា ដើម្បីពិភាក្សានិងអនុម័តលើតួលេខសរុបសំខាន់ៗជាក្របខ័ណ្ឌថវិកាឱ្យចប់សព្វគ្រប់នៅចុងខែមិថុនា ដែលនេះគឺជាដំណើរការដែលត្រូវបានដាក់ចេញដើម្បីរក្សាបាននូវវិន័យថវិកា។ ការអនុម័តគឺធ្វើឡើងទៅតាមកញ្ចប់ចំណាយនីមួយៗ ក្នុងចំណោមកញ្ចប់វិស័យចំណាយទាំង២៧ ដោយមិនទាន់វិភាជលម្អិតជាងនេះនៅឡើយទេ ហើយទំហំចំណាយសរុបនៃឆ្នាំបន្ទាប់ និងឆ្នាំខាងមុខទៀត ត្រូវបានគ្រប់គ្រងដោយការកំណត់កម្រិតអតិបរមា ក្នុងក្របខ័ណ្ឌថវិកាពហុឆ្នាំ។

នៅពេលដែលតួលេខទៅតាមកញ្ចប់គោលនយោបាយទាំង២៧ត្រូវបានអនុម័តរួចហើយ ក្រសួងហិរញ្ញវត្ថុជាគោលការណ៍ មិនចូលរួមក្នុងដំណើរការរៀបចំថវិកាលម្អិតទេ ដោយរដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន ជាអ្នកទទួលខុសត្រូវក្នុងការវិភាជថវិកាលម្អិតនៅក្នុងរង្វង់ទឹកប្រាក់នៃកញ្ចប់គោលនយោបាយរៀងខ្លួន។ សេចក្តីព្រាងច្បាប់ថវិកាលម្អិតជាថ្មីម្តងទៀតត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រីនៅដើមខែកញ្ញា ហើយបន្ទាប់មក ច្បាប់នេះដែលមានសូចនាករសមិទ្ធកម្មទៅតាមកញ្ចប់គោលនយោបាយនីមួយៗ ត្រូវដាក់ជូនរដ្ឋសភានៅចុងខែកញ្ញា។ គណៈកម្មការជំនាញនៃរដ្ឋសភាដើរតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យពិនិស្ច័យ ហើយការងារគន្លឹះៗជាច្រើននៅក្នុងការពិនិត្យសំណើថវិកា គឺប្រព្រឹត្តទៅនៅ

គណៈកម្មការជំនាញទាំងនេះ។ គណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភាទទួលខុសត្រូវលើសេចក្តីព្រាងច្បាប់ថវិកាជារួម និងផ្តល់អនុសាសន៍ជូនរដ្ឋសភាទៅលើចំណាយសរុបជារួម និងចំណាយសរុបទៅតាមកញ្ចប់វិស័យចំណាយទាំង ២៧។ គណៈកម្មការជំនាញតាមវិស័យទទួលខុសត្រូវក្នុងការពិនិត្យពិនិស្ស័យលើការវិភាជថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់វិស័យ ចំណាយតាមសមត្ថកិច្ចរៀងៗខ្លួន។ នៅកម្រិតថ្នាក់ក្រោមជាតិ ប្រទេសស៊ុយអែតមានរដ្ឋបាលមូលដ្ឋាន ២៩០ប្រើប្រាស់ថវិកា៤៥%នៃថវិកាសរុប។

ចំពោះការតាមដាននិងវាយតម្លៃសមិទ្ធកម្ម ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(Budget Act)តម្រូវឱ្យរដ្ឋាភិបាលរាយការណ៍ទៅរដ្ឋសភាអំពីសមិទ្ធកម្ម/ផលបច្ច័យនៃការអនុវត្តគោលនយោបាយនិងវិធានការ។ ការងារទាំងអស់នេះភាគច្រើនត្រូវអនុវត្តដោយអាជ្ញាធរសវនកម្មជាតិ តាមរយៈការធ្វើសវនកម្មហិរញ្ញវត្ថុនិងសវនកម្មសមិទ្ធកម្ម។ នៅដើមឆ្នាំ ក្រសួងហិរញ្ញវត្ថុបានសង្កត់ធ្ងន់និងយកចិត្តទុកដាក់លើព័ត៌មានសមិទ្ធកម្ម ប៉ុន្តែបទពិសោធមិនទទួលបានជោគជ័យខ្លាំងទេ ដោយក្រសួង ស្ថាប័នមានប្រតិកម្មខ្លាំង ប្រឆាំងទៅនឹងការប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម។ម្យ៉ាងទៀត ការអនុវត្តបែបនេះបានបង្កើតឱ្យមានព័ត៌មានច្រើនពេក ហើយការដាក់ឆ្លងច្បាប់ថវិកាក៏មានឯកសារភ្ជាប់ច្រើនពេកដែរ ដែលធ្វើឱ្យក្រសួងហិរញ្ញវត្ថុមិនមានពេលគ្រប់គ្រាន់ ដើម្បីផ្ទៀងផ្ទាត់ និងចាត់ចែងការងារបានល្អឡើយ។ ដោយឡែករដ្ឋសភាក៏សម្តែងនូវក្តីបារម្ភអំពីគុណភាពនៃព័ត៌មានសមិទ្ធកម្មដែលភ្ជាប់ជាមួយនឹងសេចក្តីព្រាងច្បាប់ថវិកាដែរ។ នៅក្នុងន័យនេះ សារៈសំខាន់នៃព័ត៌មានសមិទ្ធកម្មចំពោះការវិភាជនិងអនុម័តថវិកា នៅតែមានកម្រិត ដោយមិនទាន់អាចឆ្លើយតបទៅនឹងទស្សនាទាននៃថវិកាសមិទ្ធកម្មនៅឡើយទេ។

### ១.២. ប្រទេសបារាំង

ប្រព័ន្ធថវិកាសមិទ្ធកម្មនៃប្រទេសបារាំងត្រូវបានដាក់ឱ្យអនុវត្តនៅខែមករា ឆ្នាំ២០០៦ នៅក្រោមច្បាប់អង្គការស្តីពីប្រព័ន្ធថវិកា (Constitutional by Law on Budget Acts)។ នៅក្រោមវិធាននៃច្បាប់ថ្មីនេះ រដ្ឋសភាអនុម័ត និងផ្តល់កញ្ចប់ថវិការួមដល់រដ្ឋមន្ត្រីទាំងអស់ ដោយភ្ជាប់ជាមួយនឹងគោលបំណង និងសូចនាករសម្រាប់វាស់វែងសមិទ្ធកម្ម។ រដ្ឋមន្ត្រីនិងនាយកកម្មវិធីត្រូវប្តេជ្ញាសម្រេចឱ្យបាននូវលទ្ធផល ដូចមាននៅក្នុងផែនការសមិទ្ធកម្មប្រចាំឆ្នាំ ដែលភ្ជាប់មកជាមួយនឹងសេចក្តីព្រាងច្បាប់ថវិកា។ ផែនការសមិទ្ធកម្មប្រចាំឆ្នាំ មានបង្ហាញអំពីការវិភាជថវិកាសម្រាប់កម្មវិធីនីមួយៗ សូចនាករសមិទ្ធកម្មនិងលទ្ធផលរំពឹងទុក។

នៅក្នុងការកែទម្រង់នេះ ថវិកាត្រូវរៀបចំឡើងទៅតាមគោលបំណងនៃចំណាយ ដើម្បីសម្រេចនូវគោលបំណងគោលនយោបាយ។ ការវិភាជថវិកាទៅតាមប្រភេទនៃចំណាយ ត្រូវបានជំនួសដោយការរៀបចំថវិកាក្នុងទម្រង់ជាគោលនយោបាយសាធារណៈទូលំទូលាយ ដែលហៅថា “បេសកកម្ម” (Mission)។ “បេសកកម្ម” ត្រូវបានអនុវត្តតាមរយៈចង្កោមនៃកម្មវិធី ដែលបានកំណត់យ៉ាងច្បាស់អំពីលទ្ធផលចុងក្រោយ លទ្ធផលក្នុងឆ្នាំ និងផែនការសកម្មភាពអនុវត្ត។ ផែនការសកម្មភាពអនុវត្តទាំងនោះគឺជាអនុកម្មវិធីឬចង្កោមសកម្មភាព។ ដំណើរការរៀបចំថវិកាប្រកាន់យកអភិក្រម

ពីលើចុះក្រោម ដែលលទ្ធផលត្រូវបានតម្រែតម្រង់និងទម្លាក់តាមថ្នាក់ពីលើចុះក្រោម ដោយផ្អែកលើអាទិភាពជាតិ (បេសកកម្ម)។ ដើម្បីឱ្យចំណាយសាធារណៈកាន់តែមានប្រសិទ្ធភាព គោលដៅនៃសមិទ្ធកម្មត្រូវបានកំណត់ ហើយលទ្ធផលត្រូវបានវាស់វែងនៅពីរកម្រិតគឺនៅកម្រិតរដ្ឋសភានិងកម្រិតរដ្ឋាភិបាល សម្រាប់ជាមូលដ្ឋានក្នុងការសម្រេចលើដំណើរការរៀបចំ និងបែងចែកថវិកាឱ្យបានល្អ និងនៅក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ន ដើម្បីគ្រប់គ្រងកម្មវិធីឱ្យមានប្រសិទ្ធភាព។ រចនាសម្ព័ន្ធថវិកានិងក្របខ័ណ្ឌសមិទ្ធកម្មត្រូវបានកំណត់ជាបីកម្រិត ដូចខាងក្រោម៖

- បេសកកម្ម : មានទាំងអស់ចំនួន៣១ដែលឆ្លើយតបទៅនឹងគោលនយោបាយសាធារណៈសំខាន់របស់ថ្នាក់ជាតិ។ បេសសកកម្មនីមួយៗមានកម្មវិធីមួយចំនួន ហើយរដ្ឋសភាអនុម័តថវិកាដល់កម្រិតកម្មវិធី។ ការអនុម័តធ្វើឡើងដោយការបោះឆ្នោតតែម្តងប៉ុណ្ណោះទៅលើថវិកាទូទៅ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេស។ ការអនុម័តគ្របដណ្តប់លើឥណទានថវិកាធានាចំណាយ ឥណទានថវិកាទូទាត់ និងឥណទានថវិកាបន្ទុកបុគ្គលិក។ រដ្ឋសភាអនុម័តសេចក្តីព្រាងច្បាប់ថវិកានៅកម្រិតបេសកកម្ម ប៉ុន្តែរដ្ឋសភាមានសិទ្ធិអំណាចអាចកែតម្រូវការវិភាជថវិកា ពីកម្មវិធីមួយទៅកម្មវិធីមួយទៀត នៅក្នុងបេសកកម្មតែមួយដែលមាននៅក្នុងសេចក្តីព្រាងច្បាប់។ រដ្ឋមន្ត្រីអាចធ្វើនិយ័តភាពថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយនៃថវិកាកញ្ចប់ក្រសួង ស្ថាប័នរបស់ខ្លួន ប៉ុន្តែទំហំថវិកាធ្វើនិយ័តភាពសរុបមិនអាចលើសពី២%នៃកញ្ចប់ថវិកាសរុបរបស់ក្រសួង ស្ថាប័នឡើយ។ ករណីនេះក៏អនុវត្តផងដែរទៅលើចំណាយបន្ទុកបុគ្គលិកសម្រាប់កម្មវិធីនីមួយៗ។ ក្រោយពីការអនុម័ត រដ្ឋាភិបាលចេញក្រឹត្យបែងចែកថវិកា និងបន្ទុកបុគ្គលិកទៅតាមកម្មវិធីរៀងៗខ្លួន។
- កម្មវិធី : មានទាំងអស់១២២ដែលបរិយាយអំពីការទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយដែលក្នុងនោះ កម្មវិធីនីមួយៗគាំទ្រដោយអនុកម្មវិធីឬចង្កោមសកម្មភាព ដែលគ្រប់គ្រងដោយអ្នកសម្របសម្រួលកម្មវិធី ដែលតែងតាំងដោយរដ្ឋមន្ត្រីពាក់ព័ន្ធ។ អ្នកសម្របសម្រួលកម្មវិធីទទួលបានឥណទានថវិកាជារួមដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ធនធានទាំងនោះ ធ្វើយ៉ាងណាអាចសម្រេចបាននូវគោលបំណងដែលបានកំណត់។
- អនុកម្មវិធី/ចង្កោមសកម្មភាព : មានចំនួន៥០០ដែលរៀបរាប់សេចក្តីលម្អិតនៃកម្មវិធី។ ចង្កោមសកម្មភាពផ្តល់ឱ្យអ្នកគ្រប់គ្រងកម្មវិធីនូវព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានថវិកា។ ដោយការពិពណ៌នាថវិកានៅកម្រិតគោលបំណង ធ្វើឱ្យបេសកកម្មរបស់រដ្ឋនិងគោលដៅនៃសេវាសាធារណៈ កាន់តែមានតម្លាភាពពេញលេញ។

រដ្ឋសភាទទួលបានឯកសារថវិកាគ្រប់ជ្រុងជ្រោយពីរដងក្នុងមួយឆ្នាំ រួមមានច្បាប់ទូទាត់ថវិកា(ឆ្នាំមុន) និងច្បាប់ថវិកាសម្រាប់ឆ្នាំបន្ទាប់។ ដើម្បីអាចពិនិត្យបានជាប្រព័ន្ធរវាងការគ្រោងថវិកាទៅនឹងការអនុវត្តជាក់ស្តែង ច្បាប់ស្តីពី

ប្រព័ន្ធថវិកា (LOLF) តម្រូវឱ្យដាក់របាយការណ៍សមិទ្ធកម្មឆ្នាំមុន និងច្បាប់ទូទាត់ឆ្នាំមុន ចូលក្នុងកិច្ចប្រជុំពេញអង្គសិន មុននឹងរដ្ឋសភាទទួលយកសេចក្ដីព្រាងច្បាប់ថវិកាឆ្នាំបន្ទាប់។ រដ្ឋសភានឹងមិនបោះឆ្នោតអនុម័តសេចក្ដីព្រាងច្បាប់ថវិកាថ្មីទេ លុះត្រាតែច្បាប់ទូទាត់ត្រូវបានពិភាក្សានិងបោះឆ្នោតអនុម័តសិន។

លទ្ធផលនៃការអនុវត្តពីឆ្នាំមុនត្រូវដាក់ជូនរដ្ឋសភានៅខែមេសានិងសេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវដាក់ជូនរដ្ឋសភានៅខែតុលា។ ការធ្វើបែបនេះ រដ្ឋសភាអាចពិនិត្យមើលពីរបាយការណ៍ឆ្នាំមុនៗសិន មុនពេលធ្វើការសម្រេចសម្រាប់ឆ្នាំបន្ទាប់។ យុទ្ធសាស្ត្រនៃកម្មវិធី គោលបំណង និងសូចនាករពាក់ព័ន្ធ ត្រូវដាក់ជូនរដ្ឋសភា នៅក្នុងផែនការសមិទ្ធកម្មប្រចាំឆ្នាំ ដែលភ្ជាប់ជាមួយនឹងសេចក្ដីព្រាងច្បាប់ថវិកា។ យុទ្ធសាស្ត្រនៃកម្មវិធីនិងគោលបំណងនីមួយៗត្រូវបានកំណត់ដោយរដ្ឋមន្ត្រី ដោយមានជំនួយពីអ្នកសម្របសម្រួលកម្មវិធី និងត្រូវជាកម្មវត្ថុនៃការជជែកដេញដោលនៅរដ្ឋសភា ដែលជាផ្នែកនៃដំណើរការអនុម័តថវិកា។

បន្ទាប់ពីច្បាប់ត្រូវបានអនុម័តរួច ប្រធានកម្មវិធី/អ្នកសម្របសម្រួលកម្មវិធី ត្រូវបានប្រគល់សិទ្ធិដែលអាចបត់បែនកម្រិតសមស្រប ក្នុងការសម្រេចនិងប្រើប្រាស់ធនធានវិភាជរបស់ខ្លួន សម្រាប់គ្រប់គ្រងកម្មវិធីឈានឆ្ពោះទៅសម្រេចគោលបំណងនៃកម្មវិធីដែលបានអនុម័ត។ ជាមួយនឹងស្វ័យភាពកម្រិតខ្ពស់ ប្រធាន/អ្នកសម្របសម្រួលកម្មវិធី ត្រូវទទួលខុសត្រូវចំពោះលទ្ធផល។ យោងតាមពិធីសារនៃការត្រួតពិនិត្យ(control protocol) ការធានាចំណាយត្រូវផ្អែកលើការពិភាក្សារវាងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ទៅតាមកម្រិតទឹកប្រាក់និងប្រភេទចំណាយ។ ប្រសិនបើទឹកប្រាក់មានទំហំលើសពីកម្រិតកំណត់ណាមួយ គឺតម្រូវឱ្យមានទិដ្ឋាការ(visa) ឬមតិយោបល់(avis) ជាមុនសិនពីអភិបាលហិរញ្ញវត្ថុ ទើបផ្ដល់ធានាចំណាយ។ ចំពោះការទូទាត់វិញ ក្នុងករណីលើសពីកម្រិតកំណត់ណាមួយ តម្រូវឱ្យមានទិដ្ឋាការជាការចាំបាច់ ទើបគណនេយ្យករសាធារណៈអាចធ្វើការទូទាត់បាន។

ក្នុងប្រព័ន្ធបារាំង នីតិវិធីនៃចំណាយបានបែងចែកច្បាស់លាស់រវាងអ្នកបញ្ជាចំណាយ(អាណាប័ក) និងអ្នកដែលកត់ត្រាទូទាត់(គណនេយ្យករ)។ គោលការណ៍នេះមានគោលដៅដើម្បីកាត់បន្ថយជាអតិបរមានូវការបន្លំ ការប្រើប្រាស់ថវិកាខុស និងបង្កើនអនុលោមភាពទៅនឹងច្បាប់ថវិកាប្រចាំឆ្នាំ។ អាណាប័ក គឺជាអ្នកគ្រប់គ្រងថវិកានិងទទួលខុសត្រូវការសម្រេចចិត្តលើចំណូល ឬ/និងចំណាយ ប៉ុន្តែមិនមានសិទ្ធិកាន់ថវិកាទាំងនោះទេ។ គណនេយ្យករមានតួនាទីអកម្ម (passive role) ដោយត្រួតពិនិត្យថវិកាទៅតាមការវិភាជនិងសម្រេចរបស់អាណាប័ក ធ្វើកិច្ចបញ្ជិកាគណនេយ្យ និងទូទាត់។ តួនាទីរបស់គណនេយ្យករសាធារណៈ ត្រូវបានកំណត់ច្បាស់នៅក្នុងមាត្រាទី៣១ នៃច្បាប់អង្គការស្ដីពីប្រព័ន្ធថវិកា។ គណនេយ្យករមិនត្រូវបានផ្ដល់សិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ក្នុងការប្រើប្រាស់ឬចាត់ចែងថវិកាទេ លើកលែងតែក្នុងករណីដែលមានការរំលោភបំពានច្បាប់។

នៅក្នុងម៉ូដែលបារាំង ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ផ្អែកជាសំខាន់ទៅលើភាពចាំបាច់ជាក់ស្ដែងក្នុងការធ្វើប្រតិភូកម្ម និងសមត្ថភាពរដ្ឋបាលថ្នាក់មូលដ្ឋាន ក្នុងការបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។ កម្មវិធីដែលពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រថ្នាក់ជាតិ គឺតែងតែត្រូវបានគ្រប់គ្រងតាមបែបមជ្ឈការ។ ជាក់ស្ដែង កម្មវិធីក្នុងវិស័យអប់រំ

និងសុខាភិបាល ត្រូវបានគិតគូរនិងអនុវត្តនៅថ្នាក់ជាតិ។ សមាសភាគគាំទ្រផ្សេងៗដូចជា ការគ្រប់គ្រងសម្ភារៈនិងអគារ ត្រូវបានធ្វើវិមជ្ឈការទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានគោលការណ៍ណែនាំជាក់លាក់។ នៅក្នុងវិស័យសុខាភិបាល មន្ទីរពេទ្យតំបន់ធំៗត្រូវបានគ្រប់គ្រងដោយថ្នាក់ជាតិ ដោយសារសកម្មភាពចូលរួមចំណែកដោយផ្ទាល់ទៅនឹងយុទ្ធសាស្ត្រ វិស័យសុខាភិបាលរបស់ជាតិជារួម។ ដោយឡែក គ្លីនិកតូចៗនិងមណ្ឌលសុខភាពនៅតាមស្រុក និងឃុំ ត្រូវបានធ្វើវិមជ្ឈការ។ ការសម្រេចចិត្តលើការធ្វើវិមជ្ឈការនិងវិសហមជ្ឈការ ប្រព្រឹត្តទៅតាមការពិភាក្សាគ្នា ទៅតាមករណីជាក់ស្តែងនីមួយៗ។

នៅពេលអនុវត្តថវិកា លទ្ធផលសមិទ្ធកម្មត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ដើម្បីភ្ជាប់ជាមួយនឹងច្បាប់ទូទាត់។ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវបានរៀបចំតាមលំនាំដូចគ្នានឹងផែនការសមិទ្ធកម្មប្រចាំឆ្នាំ ដើម្បីងាយស្រួលក្នុងការប្រៀបធៀបរវាងថវិកាអនុម័តនិងការអនុវត្តជាក់ស្តែង។ ការិយាល័យសវនកម្មរដ្ឋក៏រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផលនៃថវិកា ដោយមានការពិនិត្យឡើងវិញពីគោលបំណង និងសមិទ្ធកម្មនៃកម្មវិធី។ លើសពីនេះ គណៈកម្មការសវនកម្មអន្តរនាយកដ្ឋាន មានតួនាទីធ្វើសវនកម្មបន្ថែមទៀតទៅលើគុណភាពព័ត៌មានសមិទ្ធកម្ម។ ទោះបីជាមានការកែទម្រង់ដូចនេះ និងការកែសម្រួលនីតិវិធីការងារក៏ដោយ ក៏លទ្ធផលសមិទ្ធកម្មមិនសូវត្រូវបានប្រើប្រាស់ជាមូលដ្ឋានពិភាក្សានៅក្នុងរដ្ឋសភាទេ ពីព្រោះព័ត៌មានទាំងនោះមិនមានផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងការវិភាជធនធាន។ ខណៈដែលការកែទម្រង់បានផ្តល់នូវស្វ័យភាពកម្រិតខ្ពស់ទៅដល់ប្រធាន/អ្នកសម្របសម្រួលកម្មវិធី ក្នុងការប្រើប្រាស់ធនធានហើយក៏ដោយ ក៏នៅមានការលំបាកជាច្រើនក្នុងការជំរុញឱ្យអ្នកទាំងនោះទទួលខុសត្រូវចំពោះលទ្ធផល។

### ១.៣. ប្រទេសថៃ

ប្រទេសថៃបានផ្លាស់ប្តូរពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល ទៅជាប្រព័ន្ធថវិកាផែនការកម្មវិធីនៅក្នុងឆ្នាំ១៩៨២ ហើយបន្ទាប់មក បានផ្លាស់ប្តូរទៅប្រើប្រាស់ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មក្នុងឆ្នាំ១៩៨៩ និងក្រោយមកទៀត បានប្រែក្លាយទៅជាប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មយុទ្ធសាស្ត្រ (Strategic Performance-based Budgeting) ក្នុងឆ្នាំ២០០៣។ ប្រព័ន្ធថវិកាចុងក្រោយនេះ ផ្អែកទៅលើលទ្ធផលក្នុងឆ្នាំនិងលទ្ធផលចុងក្រោយ ច្រើនជាងទៅលើធាតុចូល ក្នុងគោលបំណងកែលម្អការគ្រប់គ្រងការងារសាធារណៈនិងការបំពេញបេសកកម្មរបស់ស្ថាប័នរដ្ឋ ទៅតាមកម្រិតធនធានដែលបានផ្តល់ឱ្យ។ ប្រព័ន្ធនេះផ្តល់ទម្ងន់ទៅលើគោលនយោបាយនិងការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ។ លក្ខណៈពិសេសនៃប្រព័ន្ធនេះ គឺការធ្វើវិសហមជ្ឈការនិងវិមជ្ឈការទៅថ្នាក់ខេត្តនិងក្រុង។

គំនិតផ្តួចផ្តើមសំខាន់នៅក្នុងប្រព័ន្ធនេះ រួមមាន ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈច្បាស់លាស់ គោលនយោបាយជាតិនិងអាទិភាពជាតិ តាមអភិក្រមពីលើចុះក្រោម និងយុទ្ធសាស្ត្រដែលជាមូលដ្ឋាននៃការវិភាជថវិកា។ តាមគំរូប្រទេសថៃ ក៏មានអភិក្រមពីក្រោមឡើងលើដែរ ដោយផ្អែកលើតម្រូវការនៅកម្រិតអនុវត្ត ដែលត្រូវច្របាច់បញ្ចូល

ជាមួយនឹងអភិក្រមពីលើចុះក្រោម។ ការគ្រប់គ្រងត្រូវបានធ្វើវិមជ្ឈការ និងផ្ដល់ភាពទន់ភ្លន់សមល្មម ដល់ប្រធានកម្មវិធី ក្នុងការគ្រប់គ្រងធនធានដោយខ្លួនឯង។ ការធ្វើវិមជ្ឈការនេះត្រូវបានផ្សារភ្ជាប់នឹងក្របខ័ណ្ឌអភិបាលកិច្ចល្អ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងល្អ និងការបង្ហាញព័ត៌មានប្រតិបត្តិការ។ ប្រទេសថៃបានប្រើប្រាស់ពិដានថវិកាជាឧបករណ៍ចម្បងក្នុងដំណើរការរៀបចំថវិកា និងបានផ្សារភ្ជាប់ក្របខ័ណ្ឌសមិទ្ធកម្ម រហូតទៅដល់កម្រិតអនុវត្ត។

ចាប់តាំងពីការអនុវត្តប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មយុទ្ធសាស្ត្រ (SPBB) នៅឆ្នាំ២០០៣មក មានបញ្ហាប្រឈមមួយចំនួនធំ។ ជាក់ស្ដែង ទោះបីជាគោលការណ៍ ប្រព័ន្ធថវិកាផ្ដោតជាសំខាន់លើលទ្ធផលក្នុងឆ្នាំនិងលទ្ធផលចុងក្រោយក្ដី នៅក្នុងការអនុវត្តជាក់ស្ដែង គឺដំណើរការរៀបចំថវិកានៅតែផ្អែកលើធាតុចូល ហើយការផ្ដោតទៅលើសមិទ្ធកម្មនៅតិចតួចនៅឡើយ។ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនៅមានភាពទន់ខ្សោយនិងត្រូវបានសម្រេចដោយថ្នាក់កណ្ដាល ដោយមានការពិចារណាតិចតួចទៅដល់អង្គភាពអនុវត្ត។ ទន្ទឹមនឹងនេះ ក៏មានការលំបាកក្នុងការកំណត់សូចនាករឱ្យបានត្រឹមត្រូវ ក្នុងការវាស់ស្ទង់សមិទ្ធកម្ម មានការខ្វះជំនាញបច្ចេកទេស មានបន្ទុកព័ត៌មានច្រើនហួសហេតុ មានបញ្ហាលំបាកនៅក្នុងការកសាងសមត្ថភាព ហើយមានការព្យាយាមបកត្រឡប់ទៅរកប្រព័ន្ធថវិកាតាមធាតុចូលវិញ ទាំងនៅក្នុងកម្រិតនីតិប្បញ្ញត្តិ ទាំងនៅក្នុងកម្រិតនីតិប្រតិបត្តិ។

ការវិភាជធនធាន/ថវិកាមិនផ្អែកទាំងស្រុងលើព័ត៌មានសមិទ្ធកម្មឬតាមលក្ខខណ្ឌនៃការសម្រេចបានគោលដៅសមិទ្ធកម្មនោះទេ ប៉ុន្តែក៏អាស្រ័យលើកត្តាសេដ្ឋកិច្ច នយោបាយ និងគោលនយោបាយផ្សេងៗទៀត ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្ត។

ការកែទម្រង់វិមជ្ឈការនៅក្នុងប្រទេសថៃបានចាប់ផ្ដើមនៅចុងទសវត្សឆ្នាំ១៩៩០ តាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧ ដែលក្នុងនោះបានកំណត់អំពីការផ្ទេរមុខងារ ការបែងចែកអំណាច សិទ្ធិក្នុងការប្រមូលពន្ធ និងអាករ និងការរៀបចំរដ្ឋបាលថ្នាក់តំបន់ (ខេត្ត) និងរដ្ឋបាលមូលដ្ឋាន។ នៅឆ្នាំ១៩៩៩ ច្បាប់ស្ដីពីវិមជ្ឈការត្រូវបានអនុម័ត។ រចនាសម្ព័ន្ធរដ្ឋបាលនៃប្រទេសថៃ រួមមាន២០ក្រសួង ស្ថាប័ន ៧៦ខេត្ត និងមានរដ្ឋបាលស្រុកចំនួន៨៧៧។ រដ្ឋបាលនេះបំបែកបន្តទៀតជា៧ ២៥៥ឃុំ និង៧៤ ៩៤៤ភូមិ។ រដ្ឋបាលមូលដ្ឋាន ត្រូវបានគ្រប់គ្រងតាមរយៈរដ្ឋបាលខេត្ត ក្រុង និងអនុស្រុក (sub-district)។ ច្បាប់វិមជ្ឈការបានកំណត់មុខងារចំនួន២៤៥ដែលត្រូវផ្ទេរ និងចែករំលែកចំណូលរហូតដល់២៥%ទៅរដ្ឋបាលមូលដ្ឋាន។ ច្បាប់នេះក៏បានផ្ដល់នូវលក្ខណវិនិច្ឆ័យសម្រាប់ការផ្ទេរបុគ្គលិកពីថ្នាក់ជាតិទៅថ្នាក់រដ្ឋបាលមូលដ្ឋានផងដែរ។

ប្រទេសថៃសម្រេចបាននូវវឌ្ឍនភាពល្អនិងបានផ្ដល់នូវបរិយាកាសអំណោយផលដល់ការធ្វើវិមជ្ឈការ ហើយការរៀបចំថវិកាត្រូវបានលម្អិតទៅដល់កម្រិតភូមិ។ ទោះបីជាយ៉ាងនេះក្ដី ដំណើរការនៃការធ្វើវិមជ្ឈការប្រឈមមុខនឹងបញ្ហាជាច្រើនទាំងក្នុងការអនុវត្តជាក់ស្ដែងនិងកម្រិតនយោបាយ។ បញ្ហានេះកើតឡើងដោយសារភាពទន់ខ្សោយនៃទំនាក់ទំនងអន្តរអភិបាលកិច្ច បទប្បញ្ញត្តិដែលរឹតត្បិតស្វ័យភាពមូលដ្ឋាន គម្លាតហិរញ្ញវត្ថុក្នុងចំណាយរដ្ឋបាលមូលដ្ឋាន និងបញ្ហាសមត្ថភាព ព្រមទាំងអភិបាលកិច្ច។

## ១.៤. ប្រទេសម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីបានឈានទៅរកប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល (Result-based Management) ដោយចាប់ផ្តើមអនុវត្តប្រព័ន្ធថវិកាផែនការនីយកម្មកម្មវិធីនៅក្នុងឆ្នាំ១៩៦៩។ បន្តបន្ទាប់មក ប្រព័ន្ធនេះត្រូវបានប្រែក្លាយទៅជាប្រព័ន្ធថវិកាកែតម្រូវ (Modified Budget System) រួចក៏វិវត្តក្លាយទៅជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផលចុងក្រោយ (Outcome-based Budgeting) នៅឆ្នាំ២០១៣ ក្រោយពីបានដាក់ឱ្យអនុវត្តសាកល្បងរយៈពេលមួយឆ្នាំកន្លងមក។ ប្រព័ន្ធនេះ ផ្តោតជាគន្លឹះលើការពង្រឹងការផ្សារភ្ជាប់អាទិភាពគោលនយោបាយជាតិទៅនឹងធនធាន ដោយប្រើឃ្នាស់នៃការផ្លាស់ប្តូរចំនួនប្រាំមួយ ដើម្បីធ្វើជាមគ្គុទ្ទេសក៍សម្រាប់ការរៀបចំប្រព័ន្ធថវិកាថ្មី ដែលផ្តោតសំខាន់លើសមិទ្ធកម្ម ការតម្រង់អាទិភាពតាមខ្សែឈរវាងអាទិភាពថ្នាក់ជាតិទៅនឹងសកម្មភាពរបស់ក្រសួង ការគ្រប់គ្រងគំនិតផ្តួចផ្តើមឆ្លងវិស័យ ការសម្របសម្រួលរវាងចំណាយមូលធននិងចំណាយចរន្ត ការធ្វើប្រតិភូកម្មអំណាចដោយភ្ជាប់នឹងគណនេយ្យភាពចំពោះលទ្ធផល និងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ។

នៅក្នុងប្រព័ន្ធថវិកាមុនៗ សូចនាករសមិទ្ធកម្ម (PIs) ត្រូវបានប្រើយ៉ាងទូលំទូលាយ ក្នុងដំណាក់កាលដំបូងនៃការវិភាជធនធាន។ ក្រោយៗមក នៅក្រោមប្រព័ន្ធថវិកាផ្អែកលើលទ្ធផល (OBB) សូចនាករសមិទ្ធកម្ម (PIs) ត្រូវបានប្រើប្រាស់នៅក្នុងការធ្វើផែនការ ដើម្បីលើកកម្ពស់ការផ្តល់សេវានិងការអនុវត្តកម្មវិធីឱ្យបានប្រសើរជាងមុន។ ការយកចិត្តទុកដាក់សំខាន់បំផុត គឺទៅលើការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម។ អ្នកគ្រប់គ្រងកម្មវិធីត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងសមិទ្ធកម្ម ដែលក្នុងកិច្ចព្រមព្រៀងនោះមានចែងលម្អិតអំពីវិស័យដែលត្រូវអនុវត្ត គោលដៅត្រូវសម្រេចបាន និងការវិភាជធនធាន។ គណនេយ្យភាពត្រូវបានកែលម្អច្រើននៅក្នុងដំណើរការរៀបចំបែបនេះ។ ទោះបីជាយ៉ាងនេះក្តី តម្លាភាពក្នុងដំណើរការរៀបចំថវិកានិងការប្រឹក្សាយោបល់ក្នុងចំណោមភាគីពាក់ព័ន្ធនៅមានការខ្វះខាតខ្លះ ដោយសារកត្តាពេលវេលា។

ជារួម ប្រទេសម៉ាឡេស៊ីទទួលបានជោគជ័យនៅក្នុងការអនុវត្តថវិកាសមិទ្ធកម្ម ធៀបនឹងប្រទេសនៅក្នុងតំបន់។ ស្រដៀងគ្នាទៅនឹងប្រទេសសមាជិក OECD និងប្រទេសថៃ ការវិភាជថវិកា/ធនធានមិនអាស្រ័យទៅលើសូចនាករសមិទ្ធកម្ម (PIs) តែមួយមុខទេ ដោយក្នុងនោះកត្តាសេដ្ឋកិច្ច នយោបាយ និងគោលនយោបាយផ្សេងៗទៀតត្រូវបានយកមកពិចារណាបន្ថែម មុនធ្វើការសម្រេចចិត្ត។

ក្នុងទិដ្ឋភាពនៃវិសហមជ្ឈការនិងវិមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងប្រទេសម៉ាឡេស៊ី គឺមានលក្ខណៈមជ្ឈការខ្ពស់។ កម្មវិធីសំខាន់ផ្តោតលើវិស័យសុខភាព ការអប់រំ កសិកម្ម ការអភិវឌ្ឍជនបទ ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ និងពាណិជ្ជកម្ម ត្រូវបានអនុវត្តក្រោមការគ្រប់គ្រងបែបមជ្ឈការដោយនាយកដ្ឋានថ្នាក់សហព័ន្ធដែលបោះទីតាំងនៅថ្នាក់ក្រោមជាតិ។

៙៙✳៙៙

## ឧបសម្ព័ន្ធទី២ : ការងារកែទម្រង់គន្លឹះៗពាក់ព័ន្ធផ្សេងទៀត

ការកែទម្រង់ប្រព័ន្ធថវិកាមិនអាចប្រព្រឹត្តទៅដាច់តែឯងនិងមិនធ្វើសមកាលកម្ម ជាមួយនឹងការដ្ឋានកែទម្រង់សំខាន់ៗដែលកំពុងដឹកនាំអនុវត្តដោយក្រសួង ស្ថាប័នផ្សេងទៀតបានឡើយ ជាពិសេស ការដ្ឋានកែទម្រង់រដ្ឋបាលសាធារណៈ និងការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ការកែទម្រង់ប្រព័ន្ធថវិកាត្រូវបានផ្សារភ្ជាប់ផងនិងត្រូវការការគាំទ្រផងពីការកែទម្រង់ទាំងនោះ ហើយប្រសិទ្ធភាពនៃការកែទម្រង់ មួយផ្នែកធំគឺអាស្រ័យទៅលើកម្រិតជិតស្និទ្ធនៃកិច្ចសហការគ្នារវាងស្ថាប័នទទួលបន្ទុកនានា និងកម្រិតនៃការតម្រឹមការកែទម្រង់ជាមួយគ្នា។ ឧបសម្ព័ន្ធនេះនឹងពិនិត្យមើលលើទំនាក់ទំនង និងហេតុបច្ច័យនៃការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់រដ្ឋបាលសាធារណៈ ទៅលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម និងដោយឡែកលើការកែទម្រង់ប្រព័ន្ធថវិកា។

បន្ថែមលើនេះ ឧបសម្ព័ន្ធនេះក៏នឹងលើកយកមកពិភាក្សាផងដែរ អំពីតួនាទីនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលមានចំណងទាក់ទងគ្នាយ៉ាងសំខាន់ជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា ដែលជាឧបករណ៍សម្រាប់ធានាប្រសិទ្ធភាពនៃសមាហរណកម្មថវិកានៅក្នុងដំណើរការធ្វើផែនការថវិកា។ ទន្ទឹមនឹងនេះ ក្នុងក្របខ័ណ្ឌនៃថវិកាសមិទ្ធកម្ម ដែលសិទ្ធអំណាចត្រូវបានផ្ទេរកាន់តែច្រើនឡើងទៅដល់ក្រសួង ស្ថាប័ន និងអង្គភាពប្រតិបត្តិផ្ទាល់ តួនាទីនៃសវនកម្មឯករាជ្យជាសមត្ថកិច្ចនៃអាជ្ញាធរសវនកម្មជាតិ ក៏ជាយន្តការដ៏មានសារៈសំខាន់មួយដែរ សម្រាប់ធានាគណនេយ្យភាពហិរញ្ញវត្ថុនិងសមិទ្ធកម្ម។ ដូចនេះ ការងារទាំងពីរនេះក៏មានការចាំបាច់ត្រូវកែទម្រង់ដើម្បីពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពសម្រាប់គាំទ្រដល់ការកែទម្រង់ប្រព័ន្ធថវិកា។

### ២.១. ការកែទម្រង់រដ្ឋបាលសាធារណៈ

ការលើកកម្ពស់សមិទ្ធកម្មនៅក្នុងវិស័យសាធារណៈ បានកែលម្អបន្តិចម្តងៗនិងយឺតៗ ដោយសារមន្ត្រី និងស្ថាប័នសាធារណៈរងនូវការបំផ្លាញស្ទើរទាំងស្រុង ក្នុងកំលុងសង្គ្រាមស៊ីវិល នាទសវត្សទី៨នៃសតវត្សទី២០ និងទសវត្សទី៩នៃសតវត្សទី២០។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្តី ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈនៅមិនទាន់អភិវឌ្ឍឱ្យបានគ្រប់គ្រាន់ ដើម្បីផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ដោយទទួលស្គាល់ពីឧបសគ្គនិងភាពចាំបាច់ក្នុងការធ្វើទំនើបកម្ម និងបង្កើនសក្តសិទ្ធិភាពនៃសេវាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តធ្វើការកែទម្រង់រដ្ឋបាលសាធារណៈ ដោយចាត់ទុកការងារនេះជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ នៅក្នុងន័យនេះ ក្រសួងមុខងារសាធារណៈត្រូវបានបង្កើតឡើង ដើម្បីអភិវឌ្ឍនិងពង្រឹងមុខងារសាធារណៈតាមរយៈកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ។ ក្រសួងមុខងារសាធារណៈនិងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានបង្កើតកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ដោយឈរលើសមិទ្ធផលនៃការកែទម្រង់រដ្ឋបាលសាធារណៈដែលសម្រេចបានពីមុនមក។

កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ មានគោលបំណងសំខាន់ៗចំនួន៣គឺ៖

- លើកកម្ពស់សេវាសាធារណៈឱ្យមានគុណភាព សាមញ្ញ ប្រសិទ្ធភាព អាចជឿទុកចិត្តបាន ឆាប់រហ័ស និងឆ្លើយតបទាន់ពេលវេលា និងងាយស្រួល ដោយមានការចូលរួមយ៉ាងសកម្មពីអ្នកប្រើប្រាស់សេវា
- ពង្រឹងការគ្រប់គ្រងធនធានមនុស្ស ដើម្បីលើកកម្ពស់សមិទ្ធកម្មរបស់មន្ត្រីសាធារណៈ ដោយប្រកាន់ខ្ជាប់នូវវប្បធម៌បម្រើសេវា ឆន្ទៈម្ចាស់ការ ភាពស្មោះត្រង់ និង មនសិការវិជ្ជាជីវៈ
- កែទម្រង់ប្រព័ន្ធបៀវត្ស ដែលធានានូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ក៏ដូចជាធានាឱ្យបាននូវសង្គតិភាព និងសិនិទ្ធភាពនៃបៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗរវាងមន្ត្រីសាធារណៈ និងកងកម្លាំងប្រដាប់អាវុធ ។

ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ មានវឌ្ឍនភាពល្អគួរឱ្យកត់សម្គាល់ ប៉ុន្តែបញ្ហាប្រឈមមួយចំនួន ទាមទារឱ្យមានការដោះស្រាយជាប្រព័ន្ធនិងប្រកបដោយភាពគ្រប់ជ្រុងជ្រោយ រួមមាន ការត្រួតពិនិត្យប្រតិបត្តិការនិងការវិភាគមុខងារក្រសួង ស្ថាប័ននិងអង្គភាព ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ការធ្វើវិចារណកម្មទំហំនៃមន្ត្រីសាធារណៈ និងរចនាសម្ព័ន្ធចាត់តាំងនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីក្នុងរដ្ឋបាលសាធារណៈ និងកង្វះសមាហរណកម្មនៃការងារកែទម្រង់នេះចូលទៅក្នុងផែនការសកម្មភាពនៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ជាដើម។ ទោះបីជាយ៉ាងនេះក្តី នៅដំណាច់ឆ្នាំ២០១៨ ក្រសួងមុខងារសាធារណៈនិងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈរំពឹងថានឹងសម្រេចបានបន្ថែមទៀតនូវវឌ្ឍនភាពចម្បងៗ តាមគោលដៅមួយចំនួន ដូចខាងក្រោម៖

- បៀវត្សរបស់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធត្រូវបានរៀបចំឱ្យមានសង្គតិភាពនឹងគ្នា ព្រមទាំងត្រូវបានដំឡើងលើសពីមួយលានរៀលសម្រាប់បៀវត្សអប្បបរមាក្នុងឆ្នាំ២០១៨
- បៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវបានបើកផ្តល់ទាន់ពេលវេលា យ៉ាងយូរក្នុងសប្តាហ៍ទីបួននៃខែនីមួយៗ តាមប្រព័ន្ធធនាគារ ព្រមទាំងការគ្រប់គ្រងប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យានិងប្រាក់ម៉ោងបន្ថែមរបស់គ្រូបង្រៀន តាមប្រព័ន្ធព័ត៌មានវិទ្យា
- អភិក្រមស្តីពីការគ្រប់គ្រងធនធានមនុស្ស ត្រូវបានរៀបចំឱ្យបានពេញលេញនិងដាក់ឱ្យអនុវត្តទូលំទូលាយ ទាំងរដ្ឋបាលថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មនឹងត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាដំណាក់កាលៗ សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការដាក់ឱ្យអនុវត្តការវាយតម្លៃអង្គភាពឆ្នើមក្នុងការផ្តល់សេវាសាធារណៈសម្រាប់វិស័យអប់រំនិងសុខាភិបាល។

ស្របតាមការផ្តោតការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលលើអភិក្រមផ្អែកលើលទ្ធផល ចំពោះការកែទម្រង់វិស័យសាធារណៈ និងការចាប់ផ្តើមថវិកាសមិទ្ធកម្ម ក្រសួងមុខងារសាធារណៈបានរៀបចំចក្ខុវិស័យ និងយុទ្ធសាស្ត្រកែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០២៨ ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាពនិងជាដៃគូអាចជឿទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។ យុទ្ធសាស្ត្រនេះមានគោលដៅមួយចំនួនដូចខាងក្រោម៖

- រៀបចំប្រព័ន្ធមុខងារសាធារណៈ ឆ្ពោះទៅរកការគ្រប់គ្រងធនធានមនុស្សបែបនិយោជន៏ ដោយផ្អែកលើគុណវុឌ្ឍិនៃមុខតំណែង
- កសាងប្រព័ន្ធផែនការក្របខ័ណ្ឌមន្ត្រីសម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យមានសង្គតិភាពទៅនឹងផែនការថវិកា
- ការធ្វើវិចារណកម្មទំហំនៃមន្ត្រីសាធារណៈនិងរចនាសម្ព័ន្ធស្ថាប័ន ឱ្យឆ្លើយតបទៅនឹងតម្រូវការការងារ
- រៀបចំនិងអនុវត្តកម្មវិធីកសាងសមត្ថភាពគ្រប់ជ្រុងជ្រោយនិងជាប្រព័ន្ធ ដើម្បីលើកកម្ពស់សមត្ថភាពដឹកនាំគ្រប់គ្រង និងជំនាញ
- រៀបចំនិងអនុវត្តប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម ដោយមានយន្តការផ្តល់ការលើកទឹកចិត្ត និងការកសាងសមត្ថភាព
- រៀបចំប្រព័ន្ធបៀវត្សគាំទ្រដល់ការលើកកម្ពស់ផលិតភាព ជំនាញវិជ្ជាជីវៈ និងសមត្ថភាពដឹកនាំនិងគ្រប់គ្រង
- បង្កើនសមត្ថភាពនិងរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្សឱ្យមានដំណើរការពេញលេញនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- លើកកម្ពស់គុណភាពសេវាសាធារណៈ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន យន្តការសមាហរណកម្មសេវា យន្តការច្រកចេញចូលតែមួយ។

យុទ្ធសាស្ត្រខាងលើ រួមចំណែកយ៉ាងសំខាន់ចំពោះយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ពិសេស ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មដែលមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់គណនេយ្យភាពសមិទ្ធកម្ម នៅក្រោមប្រព័ន្ធថវិកាសមិទ្ធកម្ម។ ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មនៅក្នុងវិស័យសាធារណៈ រួមបញ្ចូលទាំងថ្នាក់ក្រោមជាតិ ត្រូវតម្រឹមឱ្យស្អិតល្មួតគ្នា នៅក្នុងដំណើរឆ្ពោះទៅថវិកាសមិទ្ធកម្មនៅឆ្នាំ២០២៥ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។ នៅពេលនេះ ក្របខ័ណ្ឌពេលវេលានៃការអនុវត្តយុទ្ធសាស្ត្ររបស់ក្រសួងមុខងារសាធារណៈពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៨ នៅមិនទាន់វិលេចឱ្យច្បាស់នៅឡើយ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើការឱ្យបានច្រើនជាមួយនឹងក្រសួងមុខងារសាធារណៈ ដើម្បីជំរុញឱ្យរៀបចំនូវផែនទីគោលចរមួយដែលមានសមានគតិភាពទៅនឹងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

ការកសាងសមត្ថភាពនៃមន្ត្រីរាជការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវលើកកម្ពស់បន្ថែមទៀត ឱ្យសមស្រប ទៅតាមតម្រូវការធនធានមនុស្សនៅក្នុងប្រព័ន្ធថវិកាសមិទ្ធកម្ម។ ការងារនេះតម្រូវឱ្យមានការកំណត់នូវប្រភេទជំនាញនិងគុណវុឌ្ឍិ។ ការលើកកម្ពស់ចំណេះដឹងទូទៅនិងជំនាញទៅតាមមុខវិជ្ជាផ្សេងៗ គឺជាភារកិច្ចរបស់ក្រសួងមុខងារសាធារណៈ។ ដូចនេះការសហការនិងសហប្រតិបត្តិការរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយនឹងក្រសួងមុខងារសាធារណៈ គឺជាការចាំបាច់។

ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកានិងថវិកាសមិទ្ធកម្ម នឹងអាចជួយដល់ការកំណត់បានពីតម្រូវការនៃចំនួនមន្ត្រីរាជការនិងជំនាញ ជាពិសេសដើម្បីអនុវត្តកម្មវិធីទាំងឡាយដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ សមិទ្ធកម្មនៃកម្មវិធីនីមួយៗនឹងក្លាយជាមូលដ្ឋានក្នុងការវាយតម្លៃសមិទ្ធកម្មរបស់ប្រធានកម្មវិធី បុគ្គលិកក្រោមឱវាទ និងក្រសួងស្ថាប័នទាំងមូល។ ការដាក់បញ្ចូលទិដ្ឋភាពនៃថវិកាសមិទ្ធកម្មទៅក្នុងការកែទម្រង់រដ្ឋបាលសាធារណៈនឹងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការងារកែទម្រង់ទាំងពីរការដ្ឋាន គឺការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានការប្រទាក់ក្រឡាគ្នាយ៉ាងខ្លាំង។

នៅក្រោមប្រព័ន្ធថវិកាសមិទ្ធកម្ម អ្នកគ្រប់គ្រងកម្មវិធីនិង/ឬអង្គភាពថវិកា ត្រូវបានអនុញ្ញាតឱ្យមានភាពបត់បែនគ្រប់គ្រាន់ក្នុងការចាត់ចែងធនធានដើម្បីកែលម្អសមិទ្ធកម្ម ប៉ុន្តែត្រូវមានគណនេយ្យភាពចំពោះលទ្ធផល។ ធនធានទាំងនោះរួមមានទាំងផ្នែកបុគ្គលិក ទាំងផ្នែកហិរញ្ញវត្ថុ។ ទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុនឹងត្រូវបង្រួមឱ្យសាមញ្ញនិងពង្រឹងបន្ថែមនៅក្រោមគំនិតផ្តួចផ្តើមនៃការកែទម្រង់ប្រព័ន្ធថវិកា តាមរយៈការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅអ្នកគ្រប់គ្រងកម្មវិធី។ អាស្រ័យហេតុនេះ ការកែទម្រង់ការគ្រប់គ្រងមន្ត្រីរាជការដូចបានគូសបញ្ជាក់ពីខាងដើម និងការអនុវត្តការកែទម្រង់នេះឱ្យមានប្រសិទ្ធភាព នឹងគាំទ្រដល់ការសម្រេចបានជោគជ័យនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម ជាពិសេស យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា។

សរុបមក យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨ -២០២៥ និងចក្ខុវិស័យនិងយុទ្ធសាស្ត្រកែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០២៨ មានភាពប្រទាក់ក្រឡាគ្នាខ្លាំង ដែលត្រូវយកចិត្តទុកដាក់ ពីព្រោះថាទិសដៅដែលបានកំណត់ដោយការដ្ឋានកែទម្រង់ទាំងពីរមានសមានគិតភាពនិងស៊ីចង្វាក់គ្នា។ ទោះបីជាយ៉ាងនេះក្តី ក្របខ័ណ្ឌពេលវេលាក្នុងការតម្រឹមនិងការអនុវត្តយុទ្ធសាស្ត្រទាំងនេះឱ្យមានប្រសិទ្ធភាព នៅតែជាបញ្ហាប្រឈមក្នុងការអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្មឱ្យបានជោគជ័យ។

## ២.២. វិមជ្ឈការនិងវិសហមជ្ឈការ (D&D)

ក្របខ័ណ្ឌគតិយុត្តិសម្រាប់ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (D&D) ត្រូវបានកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឆ្នាំ២០០៨ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។ ច្បាប់ទាំងពីរនេះបានបើកនិងអនុញ្ញាតឱ្យមានការប្រគល់មុខងារ និងភារកិច្ចឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់នីមួយៗ។ ឯកសារយុទ្ធសាស្ត្រចំនួនពីរត្រូវបានរៀបចំឡើង ដើម្បីអនុវត្តច្បាប់អង្គការឆ្នាំ២០០៨ រួមមាន *ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ* (ឆ្នាំ ២០០៥) និង *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩* (ឆ្នាំ២០១០)។ ទោះបីកម្មវិធីជាតិឆ្នាំ២០១០បានផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រសមស្របក៏ដោយ ក៏លក្ខខណ្ឌមួយចំនួននៃ*"រដ្ឋបាលឯកភាព"* នៅមិនទាន់មានភាពច្បាស់លាស់ពេញលេញនៅឡើយ ហើយតួនាទីមុខងារ និងសិទ្ធិអំណាចទៅតាមលំដាប់ថ្នាក់នីមួយៗ គួរត្រូវបានកំណត់ឱ្យកាន់តែច្បាស់ថែមទៀត។

ការដ្ឋានកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានដឹកនាំអនុវត្តដោយក្រសួងមហាផ្ទៃនិងសម្របសម្រួលការងារកែទម្រង់ ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD)។ សារជាតិនៃការកែទម្រង់នេះមានភាពស្មុគស្មាញខ្លាំង ដោយសារតែពាក់ព័ន្ធនឹងរាជធានី ខេត្តច្រើន ដែលស្ថិតក្នុងស្ថានភាពខុសៗគ្នា និងជាប់ពាក់ព័ន្ធនឹងក្រសួង ស្ថាប័នច្រើន។ ទន្ទឹមនឹងនេះ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក៏ជាប់ពាក់ព័ន្ធផងដែរទៅនឹងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលកំពុងអនុវត្តដោយក្រសួងមុខងារសាធារណៈនិងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំពុងអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងបោះជំហានទៅមុខ ប៉ុន្តែជួបឧបសគ្គច្រើន ដោយសារកត្តាសមត្ថភាព។ ប៉ុន្តែឧបសគ្គទាំងនោះ ក៏ត្រូវបានរំពឹងទុកជាមុនរួចហើយដែរ ពីព្រោះថាការធ្វើវិមជ្ឈការតែងតែប្រព្រឹត្តទៅតាមដំណើរយឺតៗនិងព្យាសកម្ម។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យការងារនេះបន្តទៅមុខទៀត អភិបាលនុក្រមនិងសមត្ថភាពស្ថាប័នសម្រាប់ការកែទម្រង់ចាំបាច់ត្រូវពង្រឹងបន្ថែម។

ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាគោលការណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ទទួលបានការឧបត្ថម្ភធនឬផ្ទេរធនធាន ដើម្បីបំពេញចំណាយពីថវិកាថ្នាក់ជាតិ។ បច្ចុប្បន្ន ក្រុង ស្រុក ទាំងអស់មានចំនួន១៨៥និងឃុំ សង្កាត់សរុបទាំងអស់មានចំនួន១ ៦៤៦ ដែលទទួលបានការផ្តល់ហិរញ្ញប្បទានស្ទើរតែទាំងស្រុងដោយការផ្ទេរថវិកាពីរាជរដ្ឋាភិបាល។ ថវិការបស់រាជធានី ខេត្តមួយចំណែកធំ មានប្រភពមកពីចំណូលពន្ធ និងមិនមែនពន្ធ និងមួយចំណែកទៀតទទួលបានការផ្ទេរថវិកាពីរាជរដ្ឋាភិបាល ទៅតាមភាពចាំបាច់និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដូចបានកំណត់នៅក្នុងជំពូកទី៣ ចំណុច៣.៦នៃឯកសារនេះ គឺជាដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ដើម្បីកែលម្អគោលបំណងនៃការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដូចគ្នានឹងការកែទម្រង់វិសហមជ្ឈការដែរ ការផ្ទេរមុខងារតែងតែមានហានិភ័យ។ ការផ្តល់សេវាសាធារណៈនឹងកាន់តែមិនល្អ ប្រសិនបើមិនមានថវិកាសមស្របនិងខ្វះសមត្ថភាព ទាំងក្នុងកម្រិតស្ថាប័ន និងក្នុងកម្រិតធនធាន ហើយប្រការនេះនឹងជះឥទ្ធិពលទៅលើគុណភាពនៃរដ្ឋបាលទាំងមូល។ បទពិសោធជាអន្តរជាតិបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីហានិភ័យ ក្នុងការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ។ ដូចបានលើកឡើងពីខាងដើមរួចហើយ រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា មានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងប្រទេសបារាំង ដែលបទពិសោធនៃការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅទីនោះ គឺផ្អែកជាចម្បងទៅលើប្រភេទនៃមុខងារដែលត្រូវផ្ទេរនិងសមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលអាចយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។ ក្នុងន័យនេះ សមត្ថភាពរបស់ថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព គឺជាលក្ខខណ្ឌវិនិច្ឆ័យចម្បងក្នុងការកំណត់ពីការផ្ទេរមុខងារ។ មិនមានការផ្ទេរមុខងារណា ដែលអាចធ្វើបានដោយស្វ័យប្រវត្តិនោះទេ។ កម្មវិធីទាំងឡាយណាដែលមានចរិតជាយុទ្ធសាស្ត្រនិងវិវត្តនៅជុំវិញយុទ្ធសាស្ត្រជាតិនឹងត្រូវគ្រប់គ្រងដោយថ្នាក់ជាតិ។ ឧទាហរណ៍ កម្មវិធីយុទ្ធសាស្ត្រជាតិ ពាក់ព័ន្ធនឹងវិស័យសុខាភិបាល និងវិស័យអប់រំ ត្រូវបាននាំមុខ និងអនុវត្តនៅថ្នាក់ជាតិ។ កម្មវិធីគាំទ្រ ដូចជាការគ្រប់គ្រងបរិក្ខារ និងអាគារ អាចត្រូវធ្វើវិមជ្ឈការទៅថ្នាក់ខេត្ត ដោយមានគោលការណ៍ណែនាំច្បាស់លាស់។ ការសម្រេចចិត្តធ្វើវិមជ្ឈការឬវិសហមជ្ឈការកម្មវិធីត្រូវផ្អែកលើការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់ និងធ្វើមួយករណីម្តងៗ តាមលក្ខណវិនិច្ឆ័យខាងលើ។

អនុក្រឹតលេខ០៦អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរមុខងារដោយភ្ជាប់លក្ខខណ្ឌ គឺជាដំណោះស្រាយដោយការស្រុះស្រួលគ្នាពីភាគីពាក់ព័ន្ធទាំងអស់ ដែលបង្កើតបានជាយន្តការគ្រប់គ្រងហានិភ័យនៃការធ្វើប្រតិភូកម្មមុខងារទៅអាជ្ញាធរថ្នាក់ក្រោមជាតិ។ តែទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពនៅតែជាបញ្ហាប្រឈម។ ដើម្បីគាំទ្រដល់ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ កម្ពុជាអាចនឹងពិចារណាលើវិធានការរយៈពេលវែងមួយចំនួនជាអាទិភាពដូចខាងក្រោម៖

- ត្រៀមខ្លួនឱ្យរួចរាល់ និងឱ្យមានភាពចាស់ទុំនៃប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រង
- បង្កើនសមត្ថភាពនិងជំនាញគ្រប់គ្រាន់
- ជំរុញនិងរឹតបន្តឹងអនុលោមភាពផ្នែកហិរញ្ញវត្ថុ
- រៀបចំក្របខ័ណ្ឌឱ្យមានគណនេយ្យភាពនិងការទទួលខុសត្រូវច្បាស់លាស់

សរុបរួមមក ទោះបីជាមានបញ្ហាប្រឈមជាច្រើនក្នុងការអនុវត្តការងារកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលនឹងអាចមានបច្ច័យដល់ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្តី ប្រសិនបើអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ០៦ អនក្រ.បក ឱ្យមានប្រសិទ្ធភាព នោះនឹងមិនប៉ះពាល់ធ្ងន់ធ្ងរដល់យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ

២០១៨-២០២៥ឡើយ និងកាន់តែល្អថែមទៀត ប្រសិនបើក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះត្រូវបានអនុវត្ត។

### ២.៣. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ)

ការធ្វើផែនការគឺជាដំណាក់កាលដ៏សំខាន់មួយនៃការកសាងនិងការផ្តល់យុត្តិការលើថវិកា។ ការងារនេះត្រូវបានចាត់ទុកថាជាសមាសធាតុគន្លឹះមួយនៃប្រព័ន្ធថវិកាសមិទ្ធកម្ម ទាំងនៅស្ថាប័នកណ្តាលទទួលបន្ទុកថវិកា ទាំងនៅតាមក្រសួង ស្ថាប័ន។ ប្រទេសកំពុងអភិវឌ្ឍភាគច្រើនបានរៀបចំនិងប្រើប្រាស់ផែនការអភិវឌ្ឍន៍ជាតិរយៈពេលមធ្យមធ្វើជាមគ្គុទ្ទេសក៏សម្រាប់ការរៀបចំផែនការតាមវិស័យ ការផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ចំពោះអាទិភាពតាមវិស័យ និងធ្វើជាមគ្គុទ្ទេសក៍សម្រាប់កម្រិតអនុវត្ត តម្រែតម្រង់ការផ្តល់សេវារបស់ខ្លួនឱ្យឆ្លើយតបទៅនឹងអាទិភាពជាតិ។ គោលបំណងនៃផែនការយុទ្ធសាស្ត្រថវិកានៅក្នុងថវិកាសមិទ្ធកម្ម គឺដើម្បីពង្រឹងនិងកែលម្អការផ្សារភ្ជាប់ជាយុទ្ធសាស្ត្ររវាងផែនការអភិវឌ្ឍន៍ជាតិរយៈពេលមធ្យមនិងផែនការថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ គុណភាពនិងភាពគ្រប់ជ្រុងជ្រោយនៃផែនការអភិវឌ្ឍន៍ជាតិរយៈពេលមធ្យមមានសារៈសំខាន់និងចាំបាច់សម្រាប់ការវិភាជថវិកា។

នៅកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.)២០១៤-២០១៨ ដែលផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់និងការសហការពីភាគីពាក់ព័ន្ធសំខាន់ៗ និងបានកំណត់អាទិភាព និងលទ្ធផលអភិវឌ្ឍធំៗក្នុងរយៈពេលមធ្យម ដោយភ្ជាប់ជាមួយលទ្ធផលចុងក្រោយនិងសូចនាករសមិទ្ធកម្មគន្លឹះ(KPIs)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏បានគិតគូរផងដែរ ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) ស្របតាមបរិការណ៍កម្ពុជាឬហៅថាគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាពរបស់កម្ពុជា (CSDGs) ផងដែរ។ ការធ្វើផែនការជាតិបែបនេះអាចជួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- កំណត់អាទិភាពរបស់ខ្លួនបានច្បាស់លាស់ ហើយរៀបចំផែនការ កម្មវិធី និងគម្រោង (ផែនការវិនិយោគសាធារណៈរួមទាំងគម្រោងផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ)ដើម្បីសម្រេចបានគោលដៅអាទិភាពទាំងនោះ
- ក្រសួង ស្ថាប័នជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើសុខដុមនីយកម្ម និងផ្សារភ្ជាប់សមិទ្ធកម្មរបស់ខ្លួនឆ្ពោះទៅសម្រេចបានអាទិភាពជាតិ
- ឆ្លុះបញ្ចាំងឱ្យឃើញសមិទ្ធផលរួមដែលមានលក្ខណៈឆ្លងវិស័យ ដើម្បីលើកកម្ពស់ការគ្រប់គ្រងឱ្យបានល្អប្រសើរជៀសវាងការត្រួតការងារគ្នា និងការខ្ជះខ្ជាយធនធាន និង
- ផ្តោតសំខាន់លើលទ្ធផលដែលបង្កលក្ខណៈឱ្យក្រសួង ស្ថាប័នវិភាជធនធានខ្លួនបានល្អប្រសើរជាងមុន និងលើកកម្ពស់ការគ្រប់គ្រងកម្មវិធីនិងគម្រោងឱ្យកាន់តែល្អ។

បច្ចុប្បន្ន ការផ្សារភ្ជាប់រវាងផែនការតាមវិស័យជាមួយនឹង ផ.យ.អ.ជ. នៅមិនទាន់រឹងមាំនៅឡើយ។ ម្យ៉ាងដោយសារ ផ.យ.អ.ជ. មិនគ្របដណ្តប់បានគ្រប់អាទិភាពការងាររបស់ក្រសួង ស្ថាប័ន ជាហេតុធ្វើឱ្យសកម្មភាពខ្លះ

ដែលអនុវត្តដោយក្រសួង ស្ថាប័ន មិនមាននៅក្នុងផែនការនេះ។ ផ្ទុយទៅវិញ សកម្មភាពខ្លះដែលមាននៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ តែបែរជាមិនស្របតាមអាទិភាពនៃ ផ.យ.អ.ជ. ទៅវិញ។ម្យ៉ាងមួយទៀត ផ.យ.អ.ជ. មិនបានផ្តោតការយកចិត្តទុកដាក់លើអាទិភាពឱ្យបានច្បាស់លាស់ ក្នុងករណីខ្លះមិនជាក់ស្តែង និងករណីខ្លះទៀតមានលក្ខណៈសម្របសម្រួលឬធ្វូរលុងពេកជាមួយនឹងក្រសួង ស្ថាប័ន។ នៅក្នុងជំហានដែលប្រព័ន្ធថវិកាជាតិផ្លាស់ប្តូរទៅរកប្រព័ន្ធថវិកាសមិទ្ធកម្ម ការពង្រឹងកិច្ចសហការ និងការសម្របសម្រួលក្នុងចំណោមស្ថាប័នកណ្តាលសំខាន់ៗគឺជាការចាំបាច់ដើម្បីលើកកម្ពស់គុណភាពនៃការរៀបចំ ផ.យ.អ.ជ. មួយ ដែលអាចផ្តល់ជាមូលដ្ឋានសម្រាប់ការផ្សារភ្ជាប់ឱ្យបានរឹងមាំរវាងអាទិភាពតាមវិស័យនិងលទ្ធផល។ ចំពោះក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទពាក់ព័ន្ធ កម្មវិធីនីមួយៗត្រូវរៀបចំដោយតម្រឹមឱ្យឆ្លើយតបតាមអាទិភាពនៃវិស័យ ដូចមាននៅក្នុង ផ.យ.អ.ជ. ហើយលទ្ធផល ក្នុងឆ្នាំទាំងអស់ដែលចូលរួមចំណែកដល់ការសម្រេចបានលទ្ធផលចុងក្រោយ ត្រូវឆ្លុះបញ្ចាំងទៅតាមកម្មវិធីរៀងៗខ្លួន។ ប្រការនេះតម្រូវឱ្យមានដំណើរការនិងនីតិវិធីដែលមានសុខដុមភាពមួយរវាងអគ្គនាយកដ្ឋានដែលពាក់ព័ន្ធ និងស្ថាប័នកណ្តាលដែលទទួលបន្ទុករៀបចំ ផ.យ.អ.ជ.។ ប្រសិនបើគ្មានការកែលម្អនោះទេ ផែនការយុទ្ធសាស្ត្រថវិកានៅតែមិនសូវមានសមានគតិភាពនិងប្រសិទ្ធភាព។

ជារួម ផ.យ.អ.ជ.គឺជាផ្នែកមួយយ៉ាងសំខាន់ និងមិនអាចខ្វះបាននៃថវិកាសមិទ្ធកម្ម ហើយគុណភាពនិងភាពច្បាស់លាស់នៃការងារនេះនឹងជួយកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលជាឯកសារផែនការយុទ្ធសាស្ត្រគន្លឹះនៅកម្រិតវិស័យ។ ផ.យ.អ.ជ. នឹងត្រូវធ្វើវិចារណកម្ម ដោយផ្តោតទៅលើគោលបំណង/អាទិភាពជាតិសំខាន់ៗដែលអាចកំណត់មុខសញ្ញាវាស់វែងបានច្បាស់លាស់ និងក្នុងគោលបំណងកាត់បន្ថយអាទិភាពដែលមិនមានភាពជាក់ស្តែង។ គោលបំណងនិងកម្មវិធីទាំងអស់នៅកម្រិតវិស័យត្រូវរៀបចំលម្អិត និងតម្រឹមជាមួយគ្នាឆ្ពោះទៅរកអាទិភាពជាតិទាំងនោះ។ ការពង្រឹងយន្តការសម្របសម្រួល និងស្ថាប័នសម្រាប់ការរៀបចំផ.យ.អ.ជ. ដើម្បីបន្សីគ្នាឱ្យបានល្អជាមួយថវិកាសមិទ្ធកម្ម គឺជាការចាំបាច់។

## ២.៤. សវនកម្មឯករាជ្យក្នុងប្រព័ន្ធថវិកាសមិទ្ធកម្ម

អាជ្ញាធរសវនកម្មជាតិត្រូវបានបង្កើតឡើងដោយច្បាប់ រាយការណ៍ផ្ទាល់ទៅអង្គនីតិប្បញ្ញត្តិ និងធ្វើសវនកម្មឯករាជ្យលើប្រតិបត្តិការរបស់រដ្ឋាភិបាល ដែលជាទូទៅផ្តោតសំខាន់លើបញ្ហាអនុលោមភាព រួមមាន ផ្នែកហិរញ្ញវត្ថុ ផ្នែកបទប្បញ្ញត្តិ និងផ្នែកនីតិវិធី។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនុវត្តថវិកាកម្មវិធី និងថវិកាសមិទ្ធកម្មពេលខាងមុខ សវនកម្មឯករាជ្យត្រូវពង្រីកវិសាលភាពឱ្យគ្របដណ្តប់សវនកម្មសមិទ្ធកម្ម ក្នុងគោលបំណងបង្កើនគណនេយ្យភាព សុចរិតភាព និងអភិបាលកិច្ចល្អ។ បច្ចុប្បន្ននេះ អាជ្ញាធរសវនកម្មជាតិកំពុងចាប់ផ្តើមធ្វើសវនកម្មសមិទ្ធកម្មខ្លះៗ ជាបណ្តើរៗ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មហិរញ្ញវត្ថុ ដោយមានសក្តិកម្មច្បាស់លាស់ ទៅតាមគណនេយ្យសាធារណៈមុនពេលបញ្ជូនរបាយការណ៍ទៅកាន់ស្ថាប័ននីតិប្បញ្ញត្តិ។ សវនកម្មការគ្រប់គ្រង រួមបញ្ចូលទិដ្ឋភាពនៃការរៀបចំអង្គការ

ចាត់តាំង ការត្រួតពិនិត្យថវិកា ការគ្រប់គ្រងចំណាយនិងចំណូល ការគ្រប់គ្រងកម្ចីនិងវិនិយោគ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិនិងឃ្លាំងសន្និធិ។ លទ្ធផលនៃការធ្វើសវនកម្មនេះត្រូវបានចែករំលែកផ្ទាល់ទៅរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធមុនគេ ដើម្បីប្រមូលមតិ និងការបំភ្លឺ។ សវនកម្មសមិទ្ធកម្មនឹងពិនិត្យឡើងវិញទៅលើសមិទ្ធកម្មនៃកម្មវិធីនិងគម្រោង ធៀបនឹងគោលដៅ និងគោលបំណងដែលបានគ្រោងទុក។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើន ការធ្វើសវនកម្មសមិទ្ធកម្មមិនធ្វើដោយទូលំទូលាយទេ ដោយសារមួយផ្នែកគឺបណ្តាលមកពីកង្វះធនធាន និងបញ្ហាសមត្ថភាព។

អាជ្ញាធរសវនកម្មជាតិនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយច្បាប់ នៅខែមីនា ឆ្នាំ២០០០ មានសិទ្ធិអំណាចធ្វើសវនកម្មឯករាជ្យលើស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា លើការកត់ត្រាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រង ប្រព័ន្ធត្រួតពិនិត្យ និងកម្មវិធីនានា។ ចាប់តាំងពីការបង្កើតស្ថាប័ននេះមកសមត្ថភាពស្ថាប័ននេះត្រូវបានពង្រឹងនិងផ្តោតជាសំខាន់ទៅលើសវនកម្មហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល។ ក្នុងខណៈដែលប្រព័ន្ធថវិកាឈានឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្ម អាជ្ញាធរសវនកម្មជាតិនឹងដើរតួនាទីកាន់តែសំខាន់ក្នុងការធ្វើសវនកម្មសមិទ្ធកម្ម។

ផែនការយុទ្ធសាស្ត្រថវិកានឹងផ្តល់ព័ត៌មានសមិទ្ធកម្ម ទៅតាមក្រសួង ស្ថាប័ន តាមកម្មវិធី និងតាមអនុកម្មវិធី។ សំខាន់ជាងនេះទៅទៀត ផែនការយុទ្ធសាស្ត្រថវិកាផ្អែកលើតក្កភាពកម្មវិធី ដែលចងភ្ជាប់រវាងការប្រើប្រាស់ធនធាន (ធាតុចូល)ទៅនឹងលទ្ធផល។ នៅពេលព័ត៌មានសមិទ្ធកម្មមានកាន់តែច្រើន ការធ្វើសវនកម្មសមិទ្ធកម្មទៅលើគោលបំណង គោលនយោបាយ កម្មវិធី និងអនុកម្មវិធី នឹងមានលទ្ធភាពអនុវត្តបានកាន់តែខ្ពស់។

អាជ្ញាធរសវនកម្មជាតិបានធ្វើការកែទម្រង់ខ្លួនឯង ឆ្ពោះទៅសវនកម្មសមិទ្ធកម្ម នៅក្រោមដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយសមត្ថភាពត្រូវបានបង្កើនជាបន្តបន្ទាប់បន្ថែមទៀត នៅពេលអនុវត្តដំណាក់កាលទី៤ស្តីពីគណនេយ្យភាពសមិទ្ធកម្ម។ ដូចនេះ នៅក្នុងដំណាក់កាលដំបូង សវនកម្មសមិទ្ធកម្មនឹងអនុវត្តទៅតាមការជ្រើសរើស។ ក្នុងន័យនេះ អាជ្ញាធរសវនកម្មជាតិនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើការសម្របសម្រួលឱ្យបានជិតស្និទ្ធ ដោយកំណត់នូវលំដាប់លំដោយនៃការងារកែទម្រង់ ដោយទុកពេលវេលាគ្រប់គ្រាន់ឱ្យអាជ្ញាធរសវនកម្មជាតិបង្កើនសមត្ថភាពនិងអនុវត្តសកម្មភាពខ្លួន ទៅតាមពេលវេលានៃការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាសមិទ្ធកម្មចាប់ពីឆ្នាំ២០២១ដល់២០២៥។

សង្ខេបជារួម ការកែទម្រង់របស់អាជ្ញាធរសវនកម្មជាតិ ឆ្ពោះទៅសវនកម្មសមិទ្ធកម្មកំពុងស្ថិតនៅក្នុងទិសដៅនិងក្របខ័ណ្ឌពេលវេលាត្រឹមត្រូវ ដើម្បីសម្រេចបានគោលដៅនៃគណនេយ្យភាពសមិទ្ធកម្ម នៅក្នុងដំណាក់កាលទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ នៅក្នុងដំណាក់កាលទី៣ ការពង្រឹងសមត្ថភាពស្ថាប័នរបស់អាជ្ញាធរសវនកម្មជាតិ គឺមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេស ការធ្វើសវនកម្មសមិទ្ធកម្មម្តងម្កាលនិងដោយការជ្រើសរើស។ ការកែទម្រង់មុខងារសវនកម្មផ្ទៃក្នុងនឹងត្រូវធ្វើស្ថាប័ននីយកម្មតាមរយៈការពិនិត្យឡើងវិញ និងការជំរុញ

មុខងារនេះឱ្យមានការធ្វើសវនកម្មផ្ទៃក្នុងលើសមិទ្ធកម្ម និងការបណ្តុះបណ្តាលជំនាញគ្រប់ជ្រុងជ្រោយដើម្បីកែលម្អសមត្ថភាពស្ថាប័ន។ ដូចបានពន្យល់ខាងដើមរួចហើយ ក្របខ័ណ្ឌនៃការងារកែទម្រង់របស់អាជ្ញាធរសវនកម្មជាតិនិងការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងត្រូវធ្វើឱ្យមានសមានគតិភាព និងសង្គតិភាពទៅតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

## ឧបសម្ព័ន្ធទី៣ : ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រ២០២៥(ពីថវិកាកម្មវិធីឆ្ពោះទៅថវិកាសមិទ្ធកម្ម)

| ល.រ. |ការងារកែទម្រង់ | អង្គភាព ទទួលខុស ត្រូវអនុវត្ត | ចាប់ ផ្តើម | បញ្ចប់ | គោលបំណង |
|---|---|---|---|---|---|
| I | ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ | | | | |
| ១ | ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | ក.ស.ហ.វ. | ២០១៨ | ២០២១ | • កែលម្អគុណភាពនិងភាពអាចទុកចិត្តបាននៃការព្យាករម៉ាក្រូសេដ្ឋកិច្ច ដោយប៉ាន់ស្មានចំណូលនិងចំណាយពហុឆ្នាំ ដែលអាចជឿទុកចិត្តបាន<br>• ស្ថាប័ននីយកម្មយន្តការរៀបចំក្របខ័ណ្ឌម៉ាក្រូនិងហិរញ្ញវត្ថុសាធារណៈ<br>• ក្លាយទៅជាមូលដ្ឋានមានប្រសិទ្ធភាពសម្រាប់រៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមនៅកម្រិតវិស័យ។ |
| | | | ២០២១ | ២០២៥ | • ដាក់ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈជូនទៅគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច |
| ២ | ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) | ក.ស.ហ.វ. | ២០១៨ | ២០២១ | • ក្លាយជាមូលដ្ឋានមានប្រសិទ្ធភាពនិងច្បាស់លាស់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាប្រចាំឆ្នាំ<br>• លើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព តាមរយៈការវិភាជថវិកាឱ្យកាន់តែមានស្ថិរភាពនិងអាចព្យាករបានតាមមូលដ្ឋានពហុឆ្នាំរហូតដល់កម្រិតវិស័យនិងក្រសួង ស្ថាប័ន។ |
| ៣ | ផែនការយុទ្ធសាស្ត្រថវិកា (BSP) | ក.ស.ហ.វ.និងក្រសួង ស្ថាប័ន | ២០១៨ | ២០២០ | • កែលម្អគុណភាពនិងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា<br>- ពង្រឹងការផ្សារភ្ជាប់គោលនយោបាយនិងកម្មវិធីពាក់ព័ន្ធ |

| | | | | | |
|---|---|---|---|---|---|
| | | | | | - សមាហរណកម្មចំណាយចរន្តនិងចំណាយមូលធន<br>- ផ្អែកលើពិដានថវិកាកំណត់ដោយក្របខ័ណ្ឌថវិការយៈពេលមធ្យម |
| | | | ២០១៨ | ២០២២ | • ពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីឈានទៅចាប់ផ្ដើមអនុវត្តថវិកាសមិទ្ធកម្ម |
| **II** | **ការរៀបចំនិងការអនុម័តថវិកា** | | | | |
| ១ | **ការរៀបចំថវិកាប្រចាំឆ្នាំ** | ក.ស.ហ.វ. / ក្រសួង ស្ថាប័ន /រដ្ឋបាលរាជធានី ខេត្ត | ២០១៨ | ២០២០ | • ពង្រីកការរៀបចំថវិកាកម្មវិធីនៅគ្រប់ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៨និងរដ្ឋបាលរាជធានី ខេត្ត នៅឆ្នាំ២០២០ |
| | | ក.ស.ហ.វ. / ក្រសួង ស្ថាប័ន | ២០១៨ | ២០២១ | • ធ្វើសមាហរណកម្មចំណាយចរន្តនិងចំណាយវិនិយោគ ដើម្បីឱ្យថវិកាមានភាពគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងចំណូល ចំណាយគ្រប់ប្រភេទនៅក្នុងថវិកា |
| | | | ២០១៨ | ២០២៥ | • កំណត់ពិដានថវិកាសម្រាប់ក្រសួង ស្ថាប័ន |
| | | | ២០១៩ | ២០២៥ | • ភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ |
| | | | ២០១៩ | ២០២០ | • ភ្ជាប់ផែនការរដ្ឋទេយ្យបុរេប្រទានជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ |
| | | | ២០២១ | ២០២៥ | • ចាប់ផ្ដើមអនុវត្តថវិកាសមិទ្ធកម្មនៅគ្រប់ក្រសួង ស្ថាប័ន |
| ២ | **ការចរចា និងការអនុម័តថវិកា** | ក.ស.ហ.វ. / ក្រសួង ស្ថាប័ន | ២០១៨ | ២០២១ | • កែលម្អក្របខ័ណ្ឌចរចាថវិកាដោយផ្ដល់ទម្ងន់លើលទ្ធផលក្នុងឆ្នាំ<br>• ចាប់ផ្ដើមផ្ដល់ទម្ងន់លើព័ត៌មានសមិទ្ធកម្មចាប់ពីឆ្នាំ២០២១ |
| | | | ២០២១ | ២០២៥ | • បញ្ជូនសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទៅគណៈរដ្ឋមន្ត្រី តាមកម្មវិធីនិងចំណាត់ថ្នាក់សេដ្ឋកិច្ចបំប្រួញ |

| | | | | | |
|---|---|---|---|---|---|
| | | | ២០២២ | ២០២៥ | • បញ្ជូនសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទៅអង្គនីតិប្បញ្ញត្តិតាមកម្មវិធី និងតាមចំណាត់ថ្នាក់សេដ្ឋកិច្ចបំប្រួញ |
| | | | ២០១៩ | ២០២៥ | • រៀបចំឱ្យមានកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ<br>• រៀបចំឱ្យមានកិច្ចព្រមព្រៀងរួមបញ្ចូលលទ្ធផលចុងក្រោយចាប់ពីឆ្នាំ ២០២៣ |
| | | | ២០២២ | ២០២៥ | • បញ្ជូនសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទៅគណៈរដ្ឋមន្ត្រី ដោយភ្ជាប់នឹងព័ត៌មានសមិទ្ធកម្ម |
| | | | ២០២៤ | ២០២៥ | • បញ្ជូនសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទៅអង្គនីតិប្បញ្ញត្តិដោយមានភ្ជាប់ព័ត៌មានសមិទ្ធកម្ម |
| **III** | **ការអនុវត្តនិងការត្រួតពិនិត្យថវិកា** | | | | |
| ១ | **ការត្រួតពិនិត្យការអនុវត្តថវិកា** | ក.ស.ហ.វ. | ២០១៨ | ២០២១ | • រៀបចំបទដ្ឋានគតិយុត្តិសម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម សម្រាប់ដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២២ |
| | | | ២០២២ | ២០២៥ | • សាកល្បងយន្តការគ្រប់គ្រងការអនុវត្តថវិកា ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្ម ដោយដាក់ឱ្យនៅអមក្រសួង ស្ថាប័ន |
| ២ | **កិច្ចលទ្ធកម្ម** | ក.ស.ហ.វ. | ២០១៨ | ២០២៥ | • បង្កើនសិទ្ធិសម្រេចនិងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជាបណ្តើរៗជូនក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពសាធារណៈប្រហាក់ប្រហែល ទន្ទឹមនឹងការពង្រឹងសវនកម្មលទ្ធកម្ម |
| | | | ២០១៨ | ២០១៨ | • រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ២០១៨-២០២៥ ដែលមានរួមបញ្ចូលការធ្វើសុខដុមនីយកម្មនីតិវិធីប្រតិបត្តិស្តង់ដាសុខដុមនីយកម្មមួយ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការត្រួតពិនិត្យការបើកផ្តល់ | ក.ស.ហ.វ. / ក្រសួង ស្ថាប័ន | ២០១៨ | ២០២៥ | • បង្រួមនិងពន្លឿននីតិវិធីនៃការបើកផ្តល់ តាមរយៈបទដ្ឋានគតិយុត្ត សម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម ដើម្បីឈានទៅអនុវត្តស្វ័យប្រវត្តិកម្ម តាមប្រព័ន្ធ FMIS នៅឆ្នាំ២០២៥ |
| | | | ២០១៨ | ២០២០ | • រៀបចំក្របខណ្ឌគតិយុត្តរួម គ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ សម្រាប់ចំណាយរដ្ឋទេយ្យបុរេប្រទាន |
| | | | ២០២២ | ២០២៥ | • រៀបចំ និងដាក់ឱ្យអនុវត្តផែនការប្រតិបត្តិថវិការបស់ក្រសួង ស្ថាប័ន |
| IV | **ការតាមដាននិងការវាយតម្លៃ** | | ២០១៩ | ២០២២ | • រៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃជាសារវ័ន្តមួយនឹងត្រូវរៀបចំចាប់ពីឆ្នាំ២០១៩ និងដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២៣។ |
| | | | ២០២១ | ២០២៥ | • ធ្វើស្ថាប័ននីយកម្មរបាយការណ៍ហិរញ្ញវត្ថុ<br>○ ផ្អែកលើស្តង់ដាគណនេយ្យបច្ចុប្បន្នចាប់ពី២០២១<br>○ ផ្អែកលើ Modified Cash-IPSAS ចាប់ពីឆ្នាំ២០២៥ |
| V | **ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់** | | | | |
| ១ | ក្របខណ្ឌគតិយុត្តិនៃថវិកា | ក.ស.ហ.វ. | ២០១៨ | ២០២០ | • ធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដើម្បីឱ្យការអនុវត្តថវិកាសមិទ្ធកម្ម មានក្របខណ្ឌគតិយុត្តច្បាស់លាស់ |
| ២ | ក្របខណ្ឌគណនេយ្យភាព | ក.ស.ហ.វ. | ២០១៨ | ២០២១ | • រៀបចំនិងដាក់បញ្ចូលគោលការណ៍ណែនាំនិងនីតិវិធីការងារសវនកម្មសមិទ្ធកម្ម ទៅក្នុងក្របខ័ណ្ឌសវនកម្មផ្ទៃក្នុង សម្រាប់អនុវត្តចាប់ពីឆ្នាំ២០២២ |
| ៣ | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) | ក.ស.ហ.វ. / ក្រសួង ស្ថាប័ន | ២០១៨ | ២០២០ | • ពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង ស្ថាប័ន |
| | | | ២០១៨ | ២០២២ | • ពង្រីកការដាក់ចំណាត់ថ្នាក់ថវិកាទាំង៧ នៅក្នុងប្រព័ន្ធ FMIS |
| | | | ២០២១ | ២០២៥ | • ដាក់បញ្ចូលមុខងាររៀបចំថវិកាក្នុងប្រព័ន្ធ FMIS និងដាក់ឱ្យអនុវត្តនៅ |

| | | | | | |
|---|---|---|---|---|---|
| | | | | | តាមក្រសួង ស្ថាប័ន |
| | | | ២០២២ | ២០២៥ | • ដាក់ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងទៅក្នុងប្រព័ន្ធFMIS ឱ្យមានមុខងារត្រួតពិនិត្យនិងតាមដាន |
| | | | ២០២៤ | ២០២៥ | • អនុវត្តស្វ័យប្រវត្តិកម្មពេញលេញការបើកផ្តល់តាមប្រព័ន្ធ FMIS |
| ៤ | **កម្មវិធីកសាងសមត្ថភាពនិងបណ្តុះបណ្តាលថវិកាសមិទ្ធកម្ម** | ក.ស.ហ.វ. / ក្រសួង ស្ថាប័ន | ២០២០ | ២០២៥ | • ផ្តល់ការបណ្តុះបណ្តាលលើគោលការណ៍និងនីតិវិធីពាក់ព័ន្ធសម្រាប់ការរៀបចំថវិកាសមិទ្ធកម្ម |
| | | | ២០២២ | ២០២៥ | • ផ្តល់ការបណ្តុះបណ្តាលលើគោលការណ៍និងនីតិវិធីចំណាយថវិកាសមិទ្ធកម្ម |
| | | | ២០២០ | ២០២៥ | • លើកកម្ពស់ជំនាញផ្នែកវិភាគថវិកានិងអ្នកគ្រប់គ្រងថវិកានៅក្នុងការគ្រប់គ្រងថវិកាសមិទ្ធកម្ម |

៧៧*៣៣